**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics


**សារណាបញ្ចប់ការសិក្សា**

# ប្រាក់ឈ្នួលរបស់កម្មករនិយោជិត នៅក្នុងប្រទេសកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ពុយ មុយស៊ាម**

សាស្ត្រាចារ្យណែនាំ
លោក **ម៉ៅ មុន្នីណា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៣ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

៚៚📖៙៙

នាងខ្ញុំឈ្មោះ **ពុយ មុយស៊ាម** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២៣ ថ្នាក់អាហារូបករណ៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ សូមលំឱនកាយវាចារចិត្តដើម្បីសម្តែងការគោរព ការដឹងគុណ និងកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

លោកឪពុក **ពុយ សុខហៃ និង**អ្នកម្តាយ **ជឹម លាងហេង** ដែលបានផ្តល់កំណើតភាពកក់ក្តៅ និងផ្គត់ផ្គង់ការសិក្សា ទំនុកបំរុងថវិកា និងសិក្ខាបករណ៍ដល់កូនរហូតទទួលបានការបញ្ចប់ការសិក្សាដោយជោគជ័យ។ គុណូបការៈរបស់លោកទាំងពីរមានទំហំធំធេង ពលីកម្មគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ ថែរក្សា សេចក្តីស្រឡាញ់ ការអនុគ្រោះ ព្រហ្មវិហារធម៌ និងអប់រំទូន្មានអោយដើរតាមគន្លងធម៌។

**ក្រសួងអប់រំ យុវជន និងកីឡា** ព្រមទាំង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់អាហារូបករណ៍រយៈពេលបួនឆ្នាំដល់រូបនាងខ្ញុំ និងជាកន្លែងបានផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋគ្រប់រូប ដោយយកចំណេះ និងជំនាញទាំងនោះមកអភិវឌ្ឍខ្លួន និងបំពេញការងារប្រកបដោយសុចរិតភាព និង តម្លាភាពចំពោះមុខច្បាប់។

ចំពោះ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និង លោក លោកស្រីសាស្ត្រាចារ្យ**ទាំងអស់ដែលបានបង្ហាត់បង្រៀន អប់រំទូន្មាន និងលះបង់ពេលវេលាដ៏មានតម្លៃ ព្រមទាំងកម្លាំងកាយកម្លាំងចិត្តក្នុងរយៈពេល៤ឆ្នាំ ដើម្បីអោយនាងខ្ញុំមានសមត្ថភាពយល់ដឹងផ្នែកនីតិសាស្ត្រ និងសម្រេចបានស្នាដៃមួយនេះឡើង។

ជាពិសេសចំពោះលោកសាស្ត្រាចារ្យ **ម៉ៅ បុណ្ណារ** ដែលបានផ្តល់កិត្តិយសធ្វើជាសាស្ត្រាចារ្យណែនាំសារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំ ដោយបានចំណាយពេលវេលាដ៏មានតម្លៃ ព្រមទាំងលះបង់កម្លាំងកាយ និងកម្លាំងចិត្តមិនខ្លាចនឿយហត់ធ្វើការណែនាំផ្តល់យោបល់ និងកែតម្រូវកំហុសនានា ដើម្បីជួយអោយសារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំប្រសូតចេញជារូបរាងឡើង និងទទួលបានជោគជ័យ ។

ជាចុងបញ្ចប់នាងខ្ញុំ សូមថ្លែងអំណរអរគុណ និងសូមប្រសិទ្ធិពរជ័យដល់វត្ថុសក្តិសិទ្ធិ សិរីមង្គល វិបុលសុខគ្រប់ប្រការក្នុងលោក សូមជួយថែរក្សាអ្នកមានគុណទាំងឡាយដូចបានរៀបរាប់ខាងលើ អោយជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានចំណាយពេលវេលាដ៏មានតម្លៃបួនឆ្នាំក្រោមការបណ្ដុះបណ្ដាល បង្ហាត់បង្រៀនពីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងដើម្បីឆ្លើយតបនឹងការខិតខំប្រឹងប្រែង ការលះបង់របស់សាស្ត្រាចារ្យ ក៏ដូចជាតម្រូវការចាំបាច់របស់សាកលវិទ្យាល័យ និងវិស័យការងារ នាងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទ "**ប្រាក់ឈ្នួលរបស់កម្មករនិយោជិតនៅក្នុងប្រទេសកម្ពុជា**" ធ្វើជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។

ការចងក្រងសារណានេះឡើងកើតចេញពីការខិតខំប្រឹងប្រែង យកចិត្តទុកដាក់អស់ពីសមត្ថភាពក្នុងការស្រាវជ្រាវ និងស្វែងរកឯកសារនានា រួមទាំងចំណេះដឹងដែលបានក្រេបជញ្ជក់ក៏ដូចជាការពិគ្រោះពិភាក្សាសុំមតិយោបល់ពីលោក-លោកស្រីសាស្ត្រាចារ្យទាំងអស់។

ការលើកយកប្រធានបទនេះឡើងមកបកស្រាយក្នុងគោលបំណងបង្ហាញពី ការបំពេញការងាររបស់កម្មករនិយោជិតក្នុងគ្រឹះស្ថាន រោងចក្រ សហគ្រាសនានាសមស្របនឹងការទទួលបានអត្រាប្រាក់ឈ្នួល ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅរបស់កម្មករនិយោជិតនៅក្នុងសង្គមកម្ពុជា និងការចែករំលែកពុទ្ធិចំណេះដឹង ទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយៗទៀតយកទៅសិក្សារៀនសូត្របំពេញបន្ថែម។

នាងខ្ញុំមានសេចក្ដីសោមនស្សរីករាយជាខ្លាំង ដែលបានសរសេរ និងរៀបរៀងសារណាបញ្ចប់ការសិក្សានេះឡើង ក្រោមការណែនាំពីសាស្ត្រាចារ្យ **មៅ បុណ្ណា** ស្នាដៃមួយនេះ នាងខ្ញុំសង្ឃឹមថា នឹងចូលរួមចំណែកក្នុងការជួយដល់និស្សិត និងមិត្តអ្នកអាន ក្នុងការពង្រីកចំណេះដឹង និងផ្ដល់គំនិតបន្ថែមទៀត។

ជាទីបញ្ចប់ នាងខ្ញុំសង្ឃឹមថា មិត្តនិស្សិត និងមិត្តអ្នកអានទាំងអស់ ចូលរួមវាយតម្លៃ និងបញ្ចេញមតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីបំពេញចន្លោះខ្វះខាត លើកំហុសដោយអចេតនា ទាំងអក្ខរាវិរុទ្ធ ទាំងការប្រើពាក្យពេចន៍ខ្លឹមសារ ឬអត្ថន័យនៅក្នុងសារណាបញ្ចប់ការសិក្សានេះ។

# មាតិកា

ទំព័រ


**តារាងសម្គាល់អក្សរកាត់**.......................................................................................iv

**សេចក្តីផ្តើម**.......................................................................................................១

**ជំពូក១៖ សញ្ញាណទូទៅនៃប្រាក់ឈ្នួល**.....................................................................៣

**ផ្នែកទី១៖ ប្រាក់ឈ្នួលសុទ្ធសាធ**..............................................................................៣

១.១ ការងារពេលថ្ងៃ...............................................................................................៤

១.២ ការងារពេលយប់...............................................................................................៤

១.៣ ការងារប្រចាំខែ...............................................................................................៥

១.៤ ការងារប្រចាំអឌ្ឍមាស.......................................................................................៥

១.៥ ការងារប្រចាំសប្តាហ៍.........................................................................................៥

១.៦ ការងារប្រចាំថ្ងៃ...............................................................................................៥

១.៧ ការងារប្រចាំម៉ោង.............................................................................................៦

**ផ្នែកទី២៖ ប្រាក់ឈ្នួលបន្ទាប់បន្សំ**..............................................................................៦

២.១ ប្រាក់បន្ថែមម៉ោង.............................................................................................៦

២.២ ប្រាក់កម្រៃជើងសា...........................................................................................៨

២.៣ ប្រាក់បុព្វលាភ និងប្រាក់បំណាច់..........................................................................៩

២.៤ សោហ៊ុយជម្ងឺចិត្ត...........................................................................................១១

២.៥ ភាគកម្មក្នុងប្រាក់ចំណេញ...................................................................................១៣

២.៦ ប្រាក់ធនានុគ្រោះ...........................................................................................១៣

២.៧ ប្រាក់បើកជារង្វាន់...........................................................................................១៣

២.៨ តម្លៃអត្ថប្រយោជន៍ជាវត្ថុ...................................................................................១៥

២.៩ ប្រាក់ទទួលបានក្នុងពេលបាត់បង់សមត្ថភាពពលកម្ម...............................................១៥

២.១០ ប្រាក់ទទួលបានក្នុងពេលលំហែមាតុភាព...............................................................២០

**ផ្នែកទី៣៖ ប្រាក់វិភាជន៍ផ្តល់ដោយនិយោជក** ........ ២១
៣.១ ប្រាក់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់ ........ ២១
៣.២ ប្រាក់វិភាជន៍ឈប់សម្រាក ឬប្រាក់បំណាច់សម្រាប់ទូទាត់ការឈប់សម្រាក ........ ២២
ក. ការឈប់សម្រាកថ្ងៃបុណ្យមានប្រាក់ឈ្នួល ........ ២២
ខ. ការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល ........ ២៤
គ. ការឈប់សម្រាកពិសេសមានប្រាក់ឈ្នួល ........ ២៥
**ផ្នែកទី៤៖ ប្រាក់មិនរាប់បញ្ចូលជាប្រាក់ឈ្នួល** ........ ២៦
៤.១ ការព្យាបាលសុខភាព ........ ២៦
៤.២ វិភាជន៍គ្រួសារតាមច្បាប់ ........ ២៧
៤.៣ សោហ៊ុយធ្វើដំណើរ ........ ២៨
៤.៤ អត្ថប្រយោជន៍ដើម្បីសម្រួលការបំពេញការងារ ........ ២៨
**ផ្នែកទី៥៖ ប្រាក់ឈ្នួលអប្បបរមាត្រូវធានា** ........ ២៩
៥.១ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិត ........ ២៩
ក. ការងារសាកល្បង ........ ៣០
ខ. កូនជាង ........ ៣១
គ. កម្មករពេញសិទ្ធិ ........ ៣២
៥.២ ប្រាក់ឈ្នួលការងារម៉ៅការ ឬតាមបរិមាណផលិតផល ........ ៣២
**ជំពូក២ ៖ ការអនុវត្តប្រាក់ឈ្នួល** ........ ៣៤
**ផ្នែកទី១ ៖ ការកំណត់ប្រាក់ឈ្នួល** ........ ៣៤
១.១ កត្តាសេដ្ឋកិច្ច ........ ៣៦
១.២ កត្តាសង្គម ........ ៣៧
១.៣ សមភាពប្រាក់ឈ្នួល ........ ៣៧
**ផ្នែកទី២ ៖ ការបើកប្រាក់ឈ្នួល** ........ ៣៧
២.១ លក្ខខណ្ឌនៃការបើកប្រាក់ឈ្នួល ........ ៣៨

២.២ ទីកន្លែងបើកប្រាក់ឈ្នួល ........ ៣៨
២.៣ ពេលវេលាបើកប្រាក់ឈ្នួល ........ ៣៨
**ផ្នែកទី៣៖ សិទ្ធិ និងការធានាប្រាក់ឈ្នួល** ........ ៣៩
៣.១ ការកាត់ប្រាក់ឈ្នួល និងការទូទាត់ប្រាក់ឈ្នួល ........ ៣៩
៣.២ ការកាត់ប្រាក់ឈ្នួល និងភាគទានសហជីព ........ ៤០
៣.៣ ការរឹបអូស និងការផ្ទេរប្រាក់ឈ្នួល ........ ៤០
៣.៤ ឯកសិទ្ធិនៃប្រាក់ឈ្នួលដែលនៅជំពាក់ ........ ៤១
៣.៥ សិទ្ធិទាមទារបើកប្រាក់ឈ្នួល ........ ៤២
**សេចក្តីសន្និដ្ឋាន** ........ ៤៣
**អនុសាសន៍** ........ ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# តារាងសម្គាល់អក្សរកាត់

- កបក = កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ
- ធល = ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ
- បឈម = ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ
- ប.ស.ស = បេឡាជាតិរបបសន្តិសុខសង្គម
- មតប = មេគុណតម្លៃបច្ចុប្បន្ន
- វបក = វិភាជន៍បាត់បង់សមត្ថភាពការងារ

# សេចក្តីផ្តើម

នៅក្នុងឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានបង្កើតច្បាប់ការងារជាលើកដំបូង ប៉ុន្តែច្បាប់ការងារឆ្នាំ១៩៥៣នេះ ត្រូវបានបំផ្លាញ និងលុបបំបាត់ចោលទាំងស្រុងនៅក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ បន្ទាប់បានរួចផុតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម និងការរួចផុតពីសង្គ្រាមរ៉ាំរ៉ៃជាច្រើនលើកច្រើនសារ នៅក្នុងឆ្នាំ១៩៩២រាជរដ្ឋាភិបាលប្រទេសកម្ពុជាបានរៀបចំក្រមការងារថ្មីមួយដោយយកលំនាំតាមក្រមការងារចាស់ៗដែលធ្លាប់បានបង្កើតឡើងពីមុន។ ជាចុងក្រោយច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ក៏ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដោយមានជំនួយពីអង្គការពលកម្មអន្តរជាតិ (ILO) ពីអ្នកមានជំនាញផ្នែកច្បាប់របស់បារាំង ព្រមទាំង Asian American Free Labor Institute (AAFLI) ហើយក៏បានចូលជាធរមានរហូតមកដល់សព្វថ្ងៃនេះ។

ជាមួយគ្នានេះដែរ បើយើងក្រឡេកមើលប្រទេសកម្ពុជាវិញ ប្រមាណឆ្នាំចុងក្រោយនេះយើងសង្កេតឃើញថាកម្ពុជាមានការរីកចម្រើនគ្រប់វិស័យទាំងអស់ ជាពិសេសវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងដែលទទួលបានការវិនិយោគពីសំណាក់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស ដូចជាប្រទេសជប៉ុន ប្រទេសកូរ៉េខាងត្បូង ប្រទេសចិន សហរដ្ឋអាមេរិក ប្រទេសប៉ែកអឺរ៉ុបជាដើម ដែលធ្វើអោយវិស័យមួយនេះដំណើរការបានយ៉ាងរលូន និងបានផ្តល់ឱកាសការងារដល់ប្រជាជនខ្មែរដោយកាត់បន្ថយការធ្វើចំណាកស្រុក។ នៅក្នុងនោះដែរ កត្តាដែលធ្វើអោយវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងមានការរីកចម្រើនគឺដោយសារមានការជួយជ្រោមជ្រែង ការចូលរួមជាកម្លាំង ប្រាជ្ញា ស្មារតី ក្រមសីលធម៌ វិជ្ជាជីវៈពីសំណាក់កូនជាង កម្មករ និយោជិត បុគ្គលិករួមផ្សំ និងការសហការជាមួយនិយោជក ឬម្ចាស់គ្រឹះស្ថានរោងចក្រ សហគ្រាស ដោយកម្មករនិយោជិតសន្យាថានឹងប្រឹងប្រែងបំពេញការងារតាមចំណេះ ជំនាញ វិជ្ជាជីវៈរបស់ខ្លួនដែលមាន ហើយនិយោជកក៏សន្យាថានឹងផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតរបស់គ្រឹះស្ថាន រោងចក្រ សហគ្រាសទាំងអស់អោយរស់នៅបានសមរម្យ និងថ្លៃថ្នូរ។ ចំពោះប្រាក់ឈ្នួលរបស់កម្មករនិយោជិតនៅក្នុងប្រទេសកម្ពុជានេះ មានការវិវត្តន៍កើនឡើងជារៀងរាល់ឆ្នាំដោយឆ្លងកាត់តាមការប្រជុំពិភាក្សារវាងស្ថាប័នត្រីភាគី ដោយផ្តោតលើកត្តាសេដ្ឋកិច្ច និងកត្តាសង្គមកិច្ច ក៏ដូចជាជីវភាពរស់នៅរបស់កម្មករនិយោជិត និងការទទួលបានផលចំណេញរបស់និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសមានន័យថាការកំណត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតទាំងអស់ គឺធ្វើយ៉ាងណាធានាឲ្យបានថាទាំងនិយោជក និងកម្មករនិយោជិតទទួលបានផលចំណេញសមាមាត្រគ្នានៅក្នុងវិស័យការងារ។ ដូចនេះប្រាក់ឈ្នួលពិតជាមានសារៈសំខាន់ណាស់សម្រាប់កម្មករនិយោជិត និងនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសក្នុងវិស័យការងារ ដើម្បីធានាដល់ការអភិវឌ្ឍ ភាពដែលអាចប្រកួត

ប្រជែងនៅលើឆាកអន្តរជាតិ ការរក្សាស្ថេរភាព គ្រឹះស្ថាន រោងចក្រ សហគ្រាសក៏ដូចជាការផ្តល់សុវត្ថិភាព ការធានាសិទ្ធិ ការការពារផ្នែកសង្គម និងការរក្សាទំនាក់ទំនងរវាងភាគីទាំងពីរ។

មួយវិញទៀត ប្រាក់ឈ្នួលរបស់កម្មករនិយោជិតនៅក្នុងប្រទេសកម្ពុជា ស្ថិតនៅក្រោមការគ្រប់ដណ្តប់នៃបទបញ្ញត្តិច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ដែលបានចងក្រងឡើងនៅក្នុងជំពូកទី៦ (លក្ខខណ្ឌទូទៅនៃការងារ) ផ្នែកទី១ (ប្រាក់ឈ្នួល) ក៏ដូចជាគោរពតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ប្រកាស និងសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

តើប្រាក់ឈ្នួលមានន័យដូចម្តេច? ប្រាក់ឈ្នួលត្រូវបានបែងចែកជាប៉ុន្មានប្រភេទ? អ្វីទៅជាប្រាក់ឈ្នួលអប្បបរមាត្រូវបានធានា? ហើយគេបែងចែកប្រាក់ឈ្នួលអតិប្បរមាជាប៉ុន្មានប្រភេទ? តើការអនុវត្តប្រាក់ឈ្នួលរបស់កម្មករនិយោជិតនៅក្នុងប្រទេសកម្ពុជា ត្រូវគោរពតាមលក្ខខណ្ឌអ្វីខ្លះ? កម្មករនិយោជិត និងនិយោជកមានសិទ្ធិដូចម្តេចខ្លះលើប្រាក់ឈ្នួលនេះ?

នៅក្នុងសារណានេះ នាងខ្ញុំនឹងធ្វើការពន្យល់បកស្រាយសំណួរខាងលើដោយធ្វើការបែងចែកជាពីរជំពូកធំៗ ដោយជំពូក១ បង្ហាញអំពីសញ្ញាណទូទៅនៃប្រាក់ឈ្នួល ដោយផ្តោតសំខាន់លើប្រាក់ឈ្នួលសុទ្ធសាធ ប្រាក់ឈ្នួលបន្ទាប់បន្សំ ប្រាក់វិភាជន៍ផ្តល់ដោយនិយោជក ប្រាក់មិនរាប់បញ្ចូលជាប្រាក់ឈ្នួល និងប្រាក់ឈ្នួលអប្បបរមាត្រូវបានធានា។ ចំណែកឯជំពូក២ នឹងបង្ហាញអំពីការអនុវត្តប្រាក់ឈ្នួល ដោយស្វែងយល់ពីការកំណត់ប្រាក់ឈ្នួល ការបើកប្រាក់ឈ្នួល និងសិទ្ធិ និងការធានាប្រាក់ឈ្នួល។

## ជំពូក១៖ សញ្ញាណទូទៅនៃប្រាក់ឈ្នួល

ប្រាក់ឈ្នួល ឬអាចហើយបានថាឈ្នួលការងារ ឬឈ្នួលសេវា គឺសំដៅលើប្រាក់កម្រៃដែលកម្មករនិយោជិតទទួលបានពីនិយោជក ឬនិយោជកបានផ្តល់អោយកម្មករនិយោជិត បន្ទាប់ពីកម្មករនិយោជិតបានបំពេញការងារតាមលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា ឬក៏បានធ្វើការក្រោមអធិនភាពរបស់បុគ្គលម្នាក់ទៀត(និយោជក)។ និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតតាមការព្រមព្រៀងគ្នា ឬតាមតម្លៃដែលមានចែងនៅក្នុងកិច្ចសន្យាការងារ។ ចំពោះអត្ថន័យដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការងារឆ្នាំ១៩៩៧របស់ព្រះរាជាណាចក្រកម្ពុជា បានអោយនិយមន័យថា ប្រាក់ឈ្នួល ជាឈ្នួលការងារ ឬឈ្នួលសេវាដែលអាចគិតជាប្រាក់បាន ឬជាការព្រមព្រៀងគ្នាដោយនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសត្រូវបើកអោយកម្មករនិយោជិត ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ដែលកើតចេញតាមរយៈកិច្ចសន្យាការងាររវាងនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស និងកម្មករនិយោជិត[១]។ សញ្ញាណទូទៅនៃប្រាក់ឈ្នួល បានគ្របសណ្តប់លើប្រាក់ឈ្នួលសុទ្ធសាធ ប្រាក់ឈ្នួលបន្ទាប់បន្សំ និងប្រាក់មិនរាប់បញ្ចូលជាប្រាក់ឈ្នួល។

### ផ្នែកទី១៖ ប្រាក់ឈ្នួលសុទ្ធសាធ

ប្រាក់ឈ្នួលសុទ្ធសាធ ឬអាចហើយម្យ៉ាងទៀតបានថាជាប្រាក់ឈ្នួលគោល ឬប្រាក់ឈ្នួលមូលដ្ឋាន គឺសំដៅលើប្រាក់ឈ្នួល ឬប្រាក់កម្រៃដែលកម្មករនិយោជិតទទួលបានពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបន្ទាប់ពីខ្លួនបានបំពេញការងារក្រោមអធិនភាពរបស់និយោជក។ និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសត្រូវផ្តល់ប្រាក់ឈ្នួលសុទ្ធសាធដល់កម្មករនិយោជិតតាមការកំណត់នៅក្នុងកិច្ចសន្យាការងារ ឬតាមការព្រមព្រៀងគ្នារវាងកម្មករនិយោជិត និងនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសជាប្រចាំខែ(សម្រាប់កម្មករនិយោជិតធ្វើការគិតជាខែ) ជាប្រចាំអឌ្ឍមាស ប្រចាំសប្តាហ៍(សម្រាប់កម្មករនិយោជិតធ្វើការគិតជាសប្តាហ៍) ប្រចាំម៉ោង(សម្រាប់កម្មករនិយោជិតធ្វើការគិតជាម៉ោង) ឬតាមការគិតជាបរិមាណផលិតផល(ដេរស៊ីបុង)ដែលកម្មករនិយោជិតសម្រេចបានជាក់ស្តែង។ ចំពោះប្រាក់ឈ្នួលសុទ្ធសាធនេះ យ៉ាងហោចណាស់ក៏ត្រូវស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានធានា[២] ពោលគឺជាប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិត

[១] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១០២។

[២] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១០៤។

ទទួលបានក្នុងមួយខែៗដោយមានការកំណត់សមរម្យតាមរយៈស្ថាប័នត្រីភាគី គឺភាគីរាជរដ្ឋាភិបាលកម្ពុជាចំនួន១៨រូប ភាគីតំណាងនិយោជកចំនួន០៧រូប(សមាគមនិយោជក) និងភាគីតំណាងកម្មករនិយោជិតចំនួន០៧រូប(សហជីព)ដើម្បីអោយអ្នកធ្វើការងារទាំងអស់នោះអាចរស់នៅបានសមរម្យ។ ប្រាក់ឈ្នួលសុទ្ធសាធត្រូវបានធ្វើការបែងចែកជាពីរ គឺប្រាក់ឈ្នួលសុទ្ធសាធចំពោះការងារពេលថ្ងៃ និងប្រាក់ឈ្នួលសុទ្ធសាធចំពោះការងារពេលយប់។

## ១.១ ការងារពេលថ្ងៃ

នៅក្នុងគ្រឹះស្ថាន រោងចក្រ សហគ្រាសប្រភេទណាក៏ដោយ កម្មករនិយោជិតទាំងពីរភេទមានថិរវេលាធ្វើការពេញលេញគឺ ៨(ប្រាំបី)ម៉ោងក្នុងមួយថ្ងៃ ឬ៤៨(សែសិបប្រាំបី)ម៉ោងក្នុងមួយសប្តាហ៍ មានន័យថាកម្មករនិយោជិតទាំងអស់មិនអាចធ្វើការលើសពី ៨(ប្រាំបី)ម៉ោងក្នុងថ្ងៃ ឬ៤៨(សែសិបប្រាំបី)ម៉ោងក្នុងមួយសប្តាហ៍បានឡើយ[៣] ហើយកម្មករនិយោជិតត្រូវបំពេញការងារនៅក្នុងថិរវេលាពេលថ្ងៃដើម្បីទទួលបានប្រាក់ឈ្នួលសុទ្ធសាធសម្រាប់ការងារពេលថ្ងៃ។ ឧទាហរណ៍ជាក់ស្តែង **ក្រុមហ៊ុន ធី និង ខេ ហ្គាមេនអ៊ីនដាស្រ្ទី ២ (T & K GARMENT INDUSTRY 2)** តម្រូវអោយកម្មករនិយោជិតចូលធ្វើការសម្រាប់ថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ លើកលែងថ្ងៃបុណ្យជាតិចាប់ពីម៉ោង ៧:០០(ប្រាំពីរ)ព្រឹក ដល់ម៉ោង ១១:០០(ដប់មួយ)ព្រឹក និងពីម៉ោង ១២:០០(ដប់ពីរ)រសៀល ដល់ម៉ោង ៤:០០(បួន)ល្ងាច។ ដូចនេះថិរវេលាធ្វើការងាររបស់ក្រុមហ៊ុននេះមានរយៈពេល៨(ប្រាំបី)ម៉ោងក្នុងមួយថ្ងៃ ឬ៤៨(សែបសិបប្រាំបី)ម៉ោងក្នុងមួយសប្តាហ៍ **(ឧបសម្ព័ន្ធទី១)**។

## ១.២ ការងារពេលយប់

ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ក៏បានបែងចែកពីភាពខុសគ្នារវាងពាក្យថា យប់ និងការងារវេនយប់ ដោយពាក្យថាយប់ មានន័យថា រយៈពេល១១(ដប់មួយ)ម៉ោងបន្តបន្ទាប់គ្នាយ៉ាងតិច រួមបញ្ចូលទាំងចន្លោះពីម៉ោង២២:០០(ម្ភៃពីរ) រហូតដល់ម៉ោង៥:០០(ប្រាំ)ទៀបភ្លឺ។ ចំណែកការងារវេនយប់វិញគិតម៉ោងធ្វើការងារចាប់ពីម៉ោង២២:០០(ម្ភៃពីរ) រហូតដល់ម៉ោង៥:០០(ប្រាំ)ទៀបភ្លឺ[៤] មានន័យថា កម្មករនិយោជិតនៃរោងចក្រសហគ្រាសនីមួយៗ ដែលបានបំពេញការងារនៅចន្លោះថិរវេលាពេលយប់ដោយគិតចាប់ពីម៉ោង២២:០០(ម្ភៃពីរ) រហូតដល់ម៉ោង៥:០០(ប្រាំ)ទៀបភ្លឺ នឹងទទួលបានប្រាក់ឈ្នួលសុទ្ធសាធសម្រាប់ការងារពេលយប់។ មួយវិញទៀត បើកម្មករនិយោជិតធ្វើការបន្តបន្ទាប់គ្នាយ៉ាង

[៣] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១៣៧។

[៤] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១៤៤ថ្មី កថាខណ្ឌទី១។

តិចរយៈពេល ១១(ដប់មួយ)ម៉ោង ទោះបីជាការងារនោះធ្វើដោយផ្លាស់វេនគ្នាធ្វើការ ជូនថ្ងៃ ជូនយប់ ឬបានធ្វើការជាអចិន្ត្រៃយ៍ក៏ដោយ នោះកម្មករនិយោជិតទាំងអស់នឹងទទួលបានប្រាក់ឈ្នួលសុទ្ធសាធដែលស្មើនឹង ១៣០%(មួយរយសាមសិបភាគរយ)នៃប្រាក់ឈ្នួលធម្មតា[៥]។

### ១.៣ ការងារប្រចាំខែ

និយោជកនៃគ្រឹះស្ថាន រោងចក្រ សហគ្រាសទាំងអស់ត្រូវផ្តល់ប្រាក់ឈ្នួល ឬប្រាក់កម្រៃដល់កម្មករនិយោជិតរបស់ខ្លួនជាប្រចាំខែតាមការកំណត់ក្នុងកិច្ចសន្យាការងារ ឬអត្រាប្រាក់ឈ្នួលដែលច្បាប់តម្រូវ។ ជាក់ស្តែង ប្រកាសលេខ៣៩៦ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៨ បានកំណត់ប្រាក់ឈ្នួលគោលសម្រាប់កម្មករនិយោជិតចំនួន១៧០(មួយរយចិតសិប)ដុល្លារអាមេរិកក្នុងមួយខែ។

### ១.៤ ការងារប្រចាំអឌ្ឍមាស

កម្មករនៃគ្រឹះស្ថាន រោងចក្រ សហគ្រាសដែលធ្វើការងារជាប្រចាំអឌ្ឍមាស ត្រូវទទួលបានប្រាក់ឈ្នួលពីនិយោជកពីរដងក្នុងមួយខែ ឬអាចហៅម្យ៉ាងទៀតបានថាប្រាក់ឈ្នួលប្រចាំអឌ្ឍមាស។ ឧទាហរណ៍ កម្មករនៃរោងចក្រផលិតឥដ្ឋទទួលបានប្រាក់ឈ្នួល ៩៥(កៅសិបប្រាំ)ដុល្លារអាមេរិកក្នុងមួយអឌ្ឍមាស (ការសម្ភាសន៍ផ្ទាល់)។

### ១.៥ ការងារប្រចាំសប្តាហ៍

ចំពោះបុគ្គលិក ឬកម្មករដែលបំពេញការងារគិតជាសប្តាហ៍ ត្រូវទទួលបានប្រាក់ឈ្នួលពីនិយោជកតាមអត្រាប្រាក់ឈ្នួលគិតជាសប្តាហ៍។ ឧទាហរណ៍ បុគ្គលិកក្រុមហ៊ុនបោសសំអាតទទួលបានប្រាក់ឈ្នួលចំនួន១០ដុល្លារអាមេរិកក្នុងមួយសប្តាហ៍ ដោយសំអាតការិយាល័យមួយសប្តាហ៍មួយដង (ការសម្ភាសន៍ផ្ទាល់)។

### ១.៦ ការងារប្រចាំថ្ងៃ

ជាក់ស្តែង អ្នកបម្រើការងារនៅក្នុងវិស័យសំណង់ ទទួលបានប្រាក់ឈ្នួលជាប្រចាំថ្ងៃពីនិយោជិក ឬថៅកែ ឬអ្នកម៉ៅការសំណង់។ បើតាមការបញ្ជាក់របស់អ្នកស្រី **សួន ស្រីយ៉ា** ជាកម្មករសំណង់ការដ្ឋានសំណង់ផ្សារទំនើបAEON សែនសុខ ទទួលបានប្រាក់ឈ្នួលចាប់ពី ៧(ប្រាំពីរ)

[៥] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១៩៥ថ្មី កថាខណ្ឌទី២។

ដុល្លារអាមេរិកឡើងទៅក្នុងមួយថ្ងៃសម្រាប់កម្មករបុរស ស្របពេលដែលកម្មករជាស្ត្រីទទួលបានប្រាក់ឈ្នួលចំនួន៥(ប្រាំ) ទៅ៦(ប្រាំមួយ)ដុល្លារអាមេរិកក្នុងមួយថ្ងៃ (**ឧបសម្ព័ន្ធទី២**)។

### ១.៧ ការងារប្រចាំម៉ោង

ជាធម្មតាបុគ្គលិកបម្រើការងារនៅហាងកាហ្វេ ឬម៉ាតលក់សម្ភារៈមួយចំនួនធំក្នុងរាជធានីភ្នំពេញ ធ្វើការតាមម៉ោងទំនេររបស់ខ្លួនទទួលបានអត្រាប្រាក់ឈ្នួលប្រចាំម៉ោង ស្របនឹងលក្ខខណ្ឌការងាររវាងនិយោជក ឬម្ចាស់ហាង និងនិយោជិត។ ឧទាហរណ៍ បុគ្គលិករត់តុហាងកាហ្វេមួយទទួលបានប្រាក់ឈ្នួល០,៧០(ចិតសិបសេន)ក្នុងមួយម៉ោង (ការសម្ភាសន៍ផ្ទាល់)។

## ផ្នែកទី២៖ ប្រាក់ឈ្នួលបន្ទាប់បន្សំ

ប្រាក់ឈ្នួលបន្ទាប់សន្សំ គឺជាប្រាក់ឈ្នួល ឬប្រាក់កម្រៃដែលកម្មករនិយោជិតនៃរោងចក្រសហគ្រាសនីមួយៗទទួលបានពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបន្ថែមពីលើប្រាក់ឈ្នួលគោលជារៀងរាល់ខែ។ ប្រាក់ឈ្នួលបន្ទាប់បន្សំ មានដូចជា ប្រាក់បន្ថែមម៉ោង ប្រាក់កម្រៃជើងសា ប្រាក់បុព្វលាភ និងប្រាក់បំណាច់ សោហ៊ុយជម្ងឺចិត្ត ភាគកម្មក្នុងប្រាក់ចំណេញ ប្រាក់ធនានុគ្រោះ ប្រាក់បើកជារង្វាន់ តម្លៃអត្ថប្រយោជន៍ជាវត្ថុ ប្រាក់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់ ប្រាក់វិភាជន៍ឈប់សម្រាក ឬបំណាច់សម្រាប់ទូទាត់ការឈប់សម្រាក ប្រាក់វិភាជន៍ឈប់សម្រាកថ្ងៃបុណ្យ ប្រាក់បាត់បង់សមត្ថភាពពលកម្ម និងប្រាក់ទទួលបានក្នុងពេលលំហែមាតុភាព[៦]។

### ២.១ ប្រាក់បន្ថែមម៉ោង

ប្រាក់បន្ថែមម៉ោង ឬប្រាក់ម៉ោងបន្ថែម គឺសំដៅលើប្រាក់ឈ្នួល ឬប្រាក់កម្រៃដែលកម្មករនិយោជិតម្នាក់ៗបានធ្វើការងារបន្ថែមម៉ោង លើសម៉ោងការងារធម្មតា(លើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោងក្នុងមួយសប្តាហ៍) ដោយហេតុថារោងចក្រសហគ្រាសមានការងារជន់ទទួលបានការបញ្ជាទិញច្រើន ឬបំពេញតាមតម្រូវការរបស់គ្រឹះស្ថាន រោងចក្រ សហគ្រាសនីមួយៗ ឬក៏គ្រឹះស្ថាន រោងចក្រ សហគ្រាសមានកិច្ចការប្រញាប់ខុសពីធម្មតាជាដើម ដែលជាគោលការណ៍តម្រូវអោយកម្មករនិយោជិតស្ម័គ្រចិត្តធ្វើការងារបន្ថែមម៉ោង ដោយមិនទទួលការគំរាមកំហែង ការបង្ខិតបង្ខំ ឬការដាក់ពិន័យផ្សេងៗពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសឡើយ។ នៅ

---

[៦] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១០៣។

ក្នុងនោះដែរ និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសត្រូវមានលិខិតអនុញ្ញាតពីការងារបន្ថែមម៉ោងចេញដោយស្ថាប័នមានសមត្ថកិច្ចទាក់ទងនឹងវិស័យការងារ ហើយកម្មករនិយោជិតនោះនឹងទទួលបានកម្រៃបន្ថែមលើប្រាក់ឈ្នួលគោល។

ចំពោះប្រាក់បន្ថែមម៉ោងសម្រាប់ការងារពេលថ្ងៃ គឺជាប្រាក់កម្រៃដែលកម្មករនិយោជិតបានស្ម័គ្រចិត្តធ្វើការងារបន្ថែមម៉ោងក្នុងចន្លោះពេលចាប់ពីម៉ោង៤:០០(បួន) ឬម៉ោង៥:០០(ប្រាំ)ល្ងាចរហូតដល់ម៉ោង ១០:០០(ដប់)យប់ (ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍) បន្ទាប់ពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានជូនដំណឹងដល់កម្មកររោងចក្រសហគ្រាស ព្រមទាំងត្រូវមានលិខិតអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការងារថែមម៉ោងនេះ។ ឧទាហរណ៍ រោងចក្រកាត់ដេរសំលៀកបំពាក់ "ក" បានស្នើអោយកម្មករនិយោជិតរបស់ខ្លួនធ្វើការងារបន្ថែមម៉ោងចំនួន២(ពីរ)ម៉ោងក្នុងមួយថ្ងៃ ចំពោះម៉ោងធ្វើការធម្មតាចូលម៉ោង៧:០០(ប្រាំពីរ)ព្រឹក (សម្រាកបាយថ្ងៃត្រង់មួយម៉ោង) ចេញម៉ោង៤:០០(បួន)ល្ងាច។ ដូចនេះកម្មករនិយោជិតអាចធ្វើការងារបន្ថែមម៉ោងចាប់ពីម៉ោង ៥:០០(ប្រាំ)ល្ងាច ដល់ម៉ោង៧:០០(ប្រាំពីរ)យប់ បន្ទាប់ពីសម្រាក ឬក៏អាចធ្វើការងារបន្ថែមម៉ោងបន្ទាប់ពីចប់ម៉ោងការងារធម្មតា គឺពីម៉ោង៤:០០(បួន)រហូតដល់ម៉ោង៦:០០(ប្រាំមួយ)ល្ងាចក៏បាន។ ម្យ៉ាងទៀតនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសត្រូវគិតអត្រានៃប្រាក់ឈ្នួលបន្ថែមម៉ោងសម្រាប់ការងារពេលថ្ងៃនេះស្មើនឹងអត្រាដំឡើង ៥០%(ហាសិបភាគរយ)នៃប្រាក់ឈ្នួលការងារធម្មតា ឬស្មើនឹង១៥០%(មួយរយហាសិបភាគរយ) ឬមួយដងកន្លះនៃប្រាក់ឈ្នួលការងារធម្មតា[៧]។

មួយវិញទៀត ប្រាក់បន្ថែមម៉ោងសម្រាប់ការងារពេលយប់ គឺជាប្រាក់ឈ្នួលដែលកម្មករនិយោជិតបានស្ម័គ្រចិត្តធ្វើការងារបន្ថែមម៉ោងក្នុងចន្លោះពេលចាប់ពីម៉ោង១០:០០(ដប់)យប់ រហូតដល់ម៉ោង៥:០០(ប្រាំ)ទៀបភ្លឺ បន្ទាប់ពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានជូនដំណឹងដល់កម្មករនិយោជិត ហើយនិយោជកត្រូវគិតអត្រានៃប្រាក់ឈ្នួលបន្ថែមម៉ោងសម្រាប់ការងារថែមម៉ោងពេលយប់ ស្មើនឹងអត្រាដំឡើងប្រាក់ឈ្នួល១០០%(មួយភាគរយ)លើប្រាក់ឈ្នួលការងារធម្មតា ឬស្មើនឹង ២០០%(ពីររយភាគរយ) ឬ២(ពីរ)ដងនៃប្រាក់ឈ្នួលការងារធម្មតា[៨]។

ចំណែកប្រាក់បន្ថែមម៉ោងសម្រាប់ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ឬថ្ងៃបុណ្យនានាក្តី ពេលគឺនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសត្រូវដំឡើងអត្រាប្រាក់ឈ្នួល១០០%(មួយភាគ

[៧] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១៣៩ថ្មី វាក្យខណ្ឌទី១។

[៨] សារាចរលេខ១៨៥ កប/សរ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីប្រាក់ឈ្នួលការងារពេលយប់។

រយ)លើប្រាក់ឈ្នួលការងារធម្មតា[៩] ដោយមិនគិតពីថិរវេលាធ្វើការងារបន្ថែមម៉ោងសម្រាប់ការងារពេលថ្ងៃ ឬសម្រាប់ការងារពេលយប់ឡើយ។ ការបន្ថែមម៉ោងសម្រាប់ការងារថ្ងៃឈប់សម្រាកនេះលុះត្រាតែគ្រឹះស្ថាន រោងចក្រ សហគ្រាសមានកិច្ចការប្រញាប់ខុសពីធម្មតា ហើយនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសត្រូវគោរពតាមគោលការណ៍ស្ម័គ្រចិត្តរបស់កម្មករនិយោជិតម្នាក់ៗ ដោយមិនអាចគម្រាមកំហែង ឬបង្ខិតបង្ខំកម្មករនិយោជិតបានឡើយ រួមទាំងមានលិខិតអនុញ្ញាតពីក្រសួងមានសមត្ថកិច្ចការងារបន្ថែមម៉ោងនេះផង។

ក្នុងករណីដែលកម្មករនិយោជិតបានយល់ព្រមស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងតាមសំណើរបស់និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស នោះកម្មករនិយោជិតនោះនឹងទទួលបានប្រាក់ថ្លៃបាយចំនួន ២ ០០០(ពីរពាន់)រៀលក្នុងមួយថ្ងៃសម្រាប់ថ្លៃអាហារ ឬកម្មករនិយោជិតអាចទទួលបានអាហារមួយពេលដោយឥតគិតថ្លៃពីនិយោជកបាន[១០]។

## ២.២ ប្រាក់កម្រៃជើងសា

ប្រាក់កម្រៃជើងសា ជាប្រាក់ដែលកម្មករនិយោជិតទទួលបានបន្ថែមលើប្រាក់ឈ្នួលគោលប្រចាំខែ បន្ទាប់ពីកម្មករនិយោជិតនោះបានធ្វើការ ខិតខំប្រឹងប្រែងលក់ទំនិញ ឬផលិតផលដែលនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានអោយលក់ មានន័យថាប្រាក់កម្រៃជើងសានេះ កម្មករនិយោជិតបានមកពីការគណនាជាភាគរយនៃការលក់ទំនិញ ឬផលិតផល ហើយក៏ជាប្រាក់លើកទឹកចិត្តដល់កម្មករនិយោជិតអោយខិតខំលក់ទំនិញ បើការលក់ទំនិញនោះបានច្រើននោះភាគរយនៃប្រាក់កម្រៃក៏បានច្រើនដែរ តែបើការលក់ទំនិញបានតិច នោះភាគរយនៃប្រាក់កម្រៃក៏បានតិចដែរ។ ដូច្នេះប្រាក់កម្រៃជើងសានេះ គឺអាស្រ័យលើការខិតខំប្រឹងប្រែងលក់ទំនិញ ឬផលិតផលរបស់ពួកគេ ដើម្បីទទួលបានប្រាក់ចំណូលបន្ថែមពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស។ ជាឧទាហរណ៍រោងចក្រផលិតស្បែកជើងធ្វើពីក្រុមា "ក" បានអោយកម្មករនិយោជិតរបស់ខ្លួនប្រឹងលក់ស្បែកជើងរបស់ខ្លួនដែលបានផលិតអោយទៅអតិថិជន ហើយបានសន្យាថាបើកម្មករនិយោជិតណាលក់បាន២០០(ពីររយ)គូក្នុងមួយខែ នោះកម្មករនិយោជិតនឹងទទួលបានប្រាក់កម្រៃជើងសា១៥%(ដប់ប្រាំភាគរយ)នៃការលក់ផលិតផល។

[៩] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១៣៩ថ្មី វាក្យខណ្ឌទី២។

[១០] សេចក្តីជូនដំណឹងលេខ០៤១/១១ ក.ប/ស/ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១។

### ២.៣ ប្រាក់បុព្វលាភ និងប្រាក់បំណាច់

ប្រាក់បុព្វលាភ ជាផ្នែកមួយនៃប្រាក់ឈ្នួលបន្ទាប់បន្សំ[១១]។ ប្រាក់បុព្វលាភ គឺជាប្រាក់ដែលនិយោជកចេញថ្លៃទិញធានារ៉ាប់រងឲ្យកម្មករនិយោជិត។ ជាក់ស្តែងនិយោជកមានកាតព្វកិច្ចបង់ភាគទានផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត អោយបេឡាជាតិរបបសន្តិសុខសង្គម។

ចំណែកប្រាក់បំណាច់ សំដៅដល់ប្រាក់ឈ្នួលដែលនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសផ្តល់ទៅអោយកម្មករនិយោជិតសម្រាប់ករណីមួយចំនួនដូចជា ប្រាក់បំណាច់បណ្តេញចេញ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ និងប្រាក់ទូទាត់ចំពោះការមិនជូនដំណឹងមុន។

ប្រាក់បំណាច់បណ្តេញចេញ ត្រូវបានយកមកអនុវត្តចំពោះកិច្ចសន្យាការងារមាន និងគ្មានកំណត់ថិរវេលាមានន័យថា បើកិច្ចសន្យាការងារត្រូវបានបញ្ចប់ ឬរំលាយដោយឆន្ទៈរបស់ភាគីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសតែម្ខាង ដោយកម្មករនិយោជិតមិនបានប្រព្រឹត្តកំហុសធ្ងន់ប៉ះពាល់ដល់គ្រឹះស្ថាន រោងចក្រ សហគ្រាស ឬមិនមានការយល់ព្រមពីកម្មករនិយោជិត នោះនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសត្រូវផ្តល់អត្ថប្រយោជន៍នៃការមិនបានជូនដំណឹងជាមុន ក្រៅពីនេះកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់បំណាច់បណ្តេញចេញដែលបានកំណត់ដូចជា[១២]៖

- ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួន៧(ប្រាំពីរ)ថ្ងៃ ចំពោះកម្មករនិយោជិតដែលបានធ្វើការជាប់ជានិច្ច ចាប់ពី៦(ប្រាំមួយ)ខែ ទៅដល់១២(ដប់ពីរ)ខែ។
- ចំពោះថិរវេលាធ្វើការងារចាប់ពី១២(ដប់ពីរ)ខែឡើងទៅ ប្រាក់បំណាច់បណ្តេញចេញត្រូវគណនាស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួន១៥(ដប់ប្រាំ)ថ្ងៃក្នុងមួយឆ្នាំនៃការងារ។ មួយវិញទៀត ប្រាក់បំណាច់បណ្តេញចេញអតិបរមាមិនអាចលើសពីប្រាក់ឈ្នួលគោល រួមទាំងប្រាក់បន្ទាប់សន្សំចំនួន៦(ប្រាំមួយ)ខែនោះទេ។ ក្នុងករណីថិរវេលាធ្វើការងារលើសពី១២(ដប់ពីរ)ខែ ហើយមានប្រភាគថិរវេលាធ្វើការងារចាប់ពី៦(ប្រាំមួយ)ខែឡើងទៅប្រាក់បំណាច់បណ្តេញចេញត្រូវគិតស្មើនឹង១ឆ្នាំពេញ មានន័យថាបើកម្មករនិយោជិតធ្វើការបាន១ឆ្នាំ ៦ខែនោះនឹងទទួលបានប្រាក់បំណាច់បណ្តេញចេញស្មើនឹង ប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួន១៥ថ្ងៃគុណនឹង២ឆ្នាំ។

[១១] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១០៣។

[១២] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៨៩។

បុគ្គល "ក" ធ្វើការងារបាន ១ឆ្នាំ និង៦ខែ នោះថិរវេលាធ្វើការរបស់ "ក" ស្មើ២ឆ្នាំ។
ប្រាក់បំណាច់បណ្តេញចេញ = (ប្រាក់ឈ្នួលចំនួន១៥ថ្ងៃ x ២ឆ្នាំ) + (ប្រាក់បន្ទាប់បន្សំចំនួន១៥ថ្ងៃ x ២ឆ្នាំ)

ចំពោះប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ មានអានុភាពចំពោះកិច្ចសន្យាការងារដែលមានថិរវេលាកំណត់តែប៉ុណ្ណោះ ពោលគឺជាប្រភេទប្រាក់បំណាច់មួយ ដែលតម្រូវអោយនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសផ្តល់អោយកម្មករនិយោជិតបន្ទាប់ពីបានបញ្ចប់កិច្ចសន្យាការងារ ដោយហេតុថាការងារដល់កាលបរិច្ឆេទផុតកំណត់តាមផ្លូវច្បាប់ ឬដោយការព្រមព្រៀងគ្នារបស់ភាគីទាំងពីរដែលបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខានៅចំពោះមុខអធិការការងារ[១៣]។ នៅពេលដែលកិច្ចសន្យាការងារមានថិរវេលាកំណត់ត្រូវបានបញ្ចប់ ទោះបីស្ថិតក្នុងហេតុផលមួយណាខាងលើក៏ដោយ ក៏និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសត្រូវតែផ្តល់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាដូចមានចែងនៅក្នុងអនុសញ្ញារួម។ ប៉ុន្តែបើមិនមានចែងនៅក្នុងអនុសញ្ញារួមទេនោះ កម្មករនិយោជិតត្រូវទទួលបានប្រាក់បំណាច់បញ្ចប់កិច្ចសន្យាយ៉ាងតិចស្មើនឹង ៥%(ប្រាំភាគរយ)នៃប្រាក់ឈ្នួល ដែលបានបើកនៅក្នុងរយៈពេលនៃកិច្ចសន្យាការងារដែលបានធ្វើរួចមក[១៤]។

ជាមួយគ្នានេះប្រាក់ទូទាត់ចំពោះការមិនជូនដំណឹងមុន មានអានុភាពចំពោះកិច្ចសន្យាការងារទាំងពីរប្រភេទ ព្រោះថាកិច្ចសន្យាការងារអាចរំលាយ ឬបញ្ចប់បានដោយឆន្ទៈភាគីតែម្ខាងបាន ប៉ុន្តែការរំលាយកិច្ចសន្យាការងារនេះ ត្រូវអនុវត្តតាមការជូនដំណឹងជាលាយលក្ខណ៍អក្សរ[១៥]។ ថិរវេលានៃការជូនដំណឹងជាមុនត្រូវបានកំណត់ជាអប្បបរមាដូចជា៖

- ៧(ប្រាំពីរ)ថ្ងៃ បើកម្មករនិយោជិតធ្វើការជាប់ក្នុងសហគ្រាសតិចជាង ៦(ប្រាំមួយ)ខែ។
- ១៥(ដប់ប្រាំ)ថ្ងៃ បើកម្មករនិយោជិតធ្វើការជាប់ក្នុងសហគ្រាសចាប់ពី ៦(ប្រាំមួយ)ខែ ទៅដល់ ២(ពីរ)ឆ្នាំ។
- ១(មួយ)ខែ បើកម្មករនិយោជិតធ្វើការជាប់ក្នុងសហគ្រាសលើសពី ២(ពីរ)ឆ្នាំ ដល់៥(ប្រាំ)ឆ្នាំ។

[១៣] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៧៣ កថាខណ្ឌទី១ និងកថាខណ្ឌទី២។

[១៤] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៧៣ កថាខណ្ឌទី១ និងកថាខណ្ឌទី៦។

[១៥] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៧៥។

- ២(ពីរ)ខែ បើកម្មករនិយោជិតធ្វើការជាប់ក្នុងសហគ្រាសលើសពី៥(ប្រាំ)ឆ្នាំ ដល់១០(ដប់)ឆ្នាំ។
- ៣(បី)ខែ បើកម្មករនិយោជិតធ្វើការជាប់ក្នុងសហគ្រាសចាប់ពី ១០(ដប់)ឆ្នាំឡើងទៅ[១៦]។

ថ្វីបើនៅក្នុងច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៧៣ កថាខណ្ឌទី៥ បានចែងថា និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសត្រូវជូនដំណឹងជាមុនអំពីការផុតរលត់នៃកិច្ចសន្យាការងារដល់កម្មករនិយោជិតក៏ដោយ ក៏កម្មករនិយោជិតដែលបានចុះកិច្ចសន្យាការងារមានថិរវេលាកំណត់មិនអាចទទួលបានប្រាក់បំណាច់ក្នុងការមិនបានជូនដំណឹងជាមុនដែរ ព្រោះថាបើនិយោជកមិនបានជូនដំណឹងជាមុនអំពីការផុតរលត់នៃកិច្ចសន្យាការងារ នោះកម្មករនិយោជិតអាចបន្តកិច្ចសន្យាការងារស្វ័យប្រវត្តិក្នុងថិរវេលាពិតប្រាកដ ដូចដែលបានចុះកិច្ចសន្យាលើកដំបូងជាមួយនិយោជក។ មួយវិញទៀត កិច្ចសន្យាការងារមានថិរវេលាកំណត់អាចរំលាយមុនកាលកំណត់បានតែក្នុងករណីមានកំហុសធ្ងន់ ឬករណីប្រធានស័ក្តិប៉ុណ្ណោះ។ ប៉ុន្តែផ្ទុយមកវិញ កម្មករនិយោជិតនៅតែមានសិទ្ធិទទួលប្រាក់ទូទាត់ការមិនបានជូនដំណឹងជាមុននេះដដែល។

ដូចនេះចំពោះកម្មករនិយោជិត ដែលបានចុះកិច្ចសន្យាការងារមាន និងគ្មានកំណត់ថិរវេលា ហើយមិនបានទទួលការជូនដំណឹងជាមុនជាលាយលក្ខណ៍អក្សរពីការបញ្ចប់កិច្ចសន្យាការងារនោះ និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសត្រូវទូទាត់ប្រាក់បំណាច់តាមរូបមន្តៈ

ប្រាក់ទូទាត់ចំពោះការមិនបានជូនដំណឹង = (ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ + ប្រាក់អត្ថប្រយោជន៍ផ្សេងៗក្នុងមួយថ្ងៃ) x ថិរវេលាដែលត្រូវជូនដំណឹងមុន

## ២.៤ សោហ៊ុយជម្ងឺចិត្ត

សោហ៊ុយជម្ងឺចិត្ត គឺជាប្រាក់ដែលនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស ឬកម្មករនិយោជិតត្រូវសងអោយភាគីណាមួយ នៅពេលដែលខ្លួនបានរំលាយកិច្ចសន្យាការងារតាមឆន្ទៈតែម្ខាងដោយគ្មានហេតុផលត្រឹមត្រូវ ឬមិនបានប្រព្រឹត្តិកំហុសធ្ងន់ធ្វើអោយប៉ះពាល់ដល់គ្រឹះស្ថាន រោងចក្រ សហគ្រាស[១៧]។ សោហ៊ុយជម្ងឺចិត្តនេះអាចទាមទារបានចំពោះ ការរំលាយកិច្ចសន្យាការងារមាន

[១៦] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៧៥។

[១៧] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៩១។

ថិរវេលាកំណត់ និងកិច្ចសន្យាការងារគ្មានថិរវេលាកំណត់បាន ដោយមិនត្រូវច្រឡំគ្នាជាមួយនឹងប្រាក់បំណាច់បណ្តេញចេញ ឬប្រាក់បំណាច់ទូទាត់ជួសការមិនជូនដំណឹងមុននោះទេ។

ចំពោះការរំលាយកិច្ចសន្យាការងារគ្មានថិរវេលាកំណត់ ដោយឆន្ទៈតែម្ខាងរបស់និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស កម្មករនិយោជិតមានសិទ្ធិទាមទារសោហ៊ុយជម្ងឺចិត្តស្មើនឹងប្រាក់បំណាច់បណ្តេញចេញ។ ឧទាហរណ៍៖ បុគ្គល "ក" បម្រើការក្រុមហ៊ុននាំចេញនាំចូលមួយ ត្រូវបាននិយោជកបណ្តេញចេញពីការងារដោយគាត់មិនបានប្រព្រឹត្តកំហុសធ្ងន់។ បើប្រាក់បំណាច់បណ្តេញចេញទទួលបាន ៥០០(ប្រាំរយ)ដុល្លារអាមេរិកនោះបុគ្គល "ក" មានសិទ្ធិទទួលបានសោហ៊ុយជម្ងឺចិត្តចំនួន៥០០(ប្រាំរយ)ដុល្លារអាមេរិក[១៨]។

ចំពោះការរំលាយកិច្ចសន្យាការងារមានថិរវេលាកំណត់ ដោយឆន្ទៈតែម្ខាងរបស់និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស កម្មករនិយោជិតមានសិទ្ធិទាមទារសោហ៊ុយជម្ងឺចិត្តដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលដែលកម្មករនិយោជិតទទួលបាន រហូតដល់ពេលចប់កិច្ចសន្យា[១៩]។ ចំណែកនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសក៏មានសិទ្ធិទាមទារជម្ងឺចិត្តស្មើនឹងការខូចខាតដែលខ្លួនបានផ្តល់អោយកម្មករនិយោជិត បើការរំលាយកិច្ចសន្យាការងារមានថិរវេលាកំណត់នោះបង្កឡើងតាមឆន្ទៈតែម្ខាងរបស់កម្មករនិយោជិត[២០]។ លើកលែងតែកិច្ចសន្យាការងារដល់កាលបរិច្ឆេទផុតកំណត់ ឬមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាង ដោយធ្វើឡើងជាលាយលក្ខណ៍អក្សរ អមជាមួយហត្ថលេខាគូភាគី និងនៅចំពោះមុខអធិការការងារ[២១]។

ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ត្រង់ មាត្រា៩៤បានចែងថា បើមិនយកតាមបទប្បញ្ញត្តិទាំងឡាយនៃមាត្រា៨៩ និងមាត្រា៩១ទេក្នុងការផ្តាច់កិច្ចសន្យាការងារ តុលាការមានសមត្ថកិច្ចសម្រេចសោហ៊ុយជម្ងឺចិត្តដោយផ្អែកតាមទំលាប់ស្រុក តាមប្រភេទ និងទំហំនៃសេវាដែលបានចុះកិច្ចសន្យាការងារតាមអតីតភាព តាមអាយុនៃកម្មករនិយោជិត តាមប្រាក់ដែលកាត់ទុក ឬសម្រាប់សោធននិវត្តន៍ និងទំហំនៃការខូចខាតនោះ។

[១៨] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៩១ កថាខណ្ឌទី៣។

[១៩] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៧៣។

[២០] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៧៣ កថាខណ្ឌទី៤។

[២១] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៧៣ កថាខណ្ឌទី១។

### ២.៥ ភាគកម្មក្នុងប្រាក់ចំណេញ

ភាគកម្មក្នុងប្រាក់ចំណេញ គឺជាប្រាក់អត្ថប្រយោជន៍មួយបែប ដែលកម្មករនិយោជិតអាចទទួលបានពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសនៅពេលដែលក្រុមហ៊ុនទទួលបានប្រាក់ចំណេញពីការលក់ ឬចែកចាយផលិតផលនានា ហើយភាគកម្មក្នុងប្រាក់ចំណេញត្រូវបានកំណត់ថាជាធាតុផ្សំមួយនៃប្រាក់ឈ្នួលបន្ទាប់បន្សំ មានន័យថាបើនិយោជកទទួលបានប្រាក់ចំណេញនៃការលក់ទំនិញ ឬផលិតផល នោះនិយោជកអាចធ្វើការបែងចែកចំនួន១%(មួយភាគរយ) នៃប្រាក់ចំណេញណាមួយ ផ្តល់ជូនកម្មករនិយោជិតសម្រាប់ជាប្រយោជន៍ដល់ការខំប្រឹងប្រែងរបស់ពួកគេ។

### ២.៦ ប្រាក់ធនានុគ្រោះ

យោងតាមច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ពីមាត្រា១៣៤ ដល់មាត្រា១៣៦ បានកំណត់ពីប្រាក់ធនានុគ្រោះជាកម្រៃដែលបុគ្គលិកនៃគ្រឹះស្ថាន សហគ្រាសខ្លះដូចជា សណ្ឋាគារ ភោជនីយដ្ឋាន ហាងកាហ្វេ ហាងលក់ភេសជ្ជៈ ហាងកាត់សក់ទទួលបានពីអតិថិជន ហើយនិយោជកបានទទួលជាភាគរយ ដែលត្រូវបន្ថែមលើការកំណត់ទារប្រាក់ពីអតិថិជនក្រោមចំណាំសម្គាល់ថា "សម្រាប់សេវាការងារ"។ ប្រាក់ធនានុគ្រោះ ពោលគឺមានលក្ខណៈស្របច្បាប់ មិនដូចជាកម្រៃដែលអតិថិជនបានផ្តល់អោយកម្មករនិយោជិតដោយផ្ទាល់ដៃតាមសន្តានចិត្តនោះទេ។ និយោជកត្រូវប្រមូលប្រាក់ធនានុគ្រោះទាំងអស់រួចធ្វើការបែងចែកឲ្យបុគ្គលិក ឬកម្មករនិយោជិតដែលបានបម្រើសេវាដល់អតិថិជន ឬមានទំនាក់ទំនងផ្ទាល់ជាមួយអតិថិជន តាមការកំណត់និងទំលាប់វិជ្ជាជីវៈ ឬបើមិនបានកំណត់តាមទំលាប់វិជ្ជាជីវៈទេ និយោជកត្រូវកម្រិតតាមប្រកាសរបស់ក្រសួងការងារ។ ឧទាហរណ៍ជាក់ស្តែង នៅក្នុងឆ្នាំ២០១៣ **ហាងនំប៉ុងធូរ ឡេ ហ្សូរ (TOUR LES JOUR)** បានកំណត់ពន្ធបន្ថែម១០% (ដប់ភាគរយ)លើតម្លៃសរុបសម្រាប់សេវាការងារបុគ្គលិក។

### ២.៧ ប្រាក់បើកជារង្វាន់

ប្រាក់បើកជារង្វាន់ សំដៅដល់ប្រាក់ដែលនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសផ្តល់អោយកម្មករនិយោជិតចំពោះការងារទៀងទាត់ និងរង្វាន់សម្រាប់អតីតភាពការងារ ហើយនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស និងកម្មករនិយោជិតអាចពិភាក្សាគ្នា ដើម្បីកំណត់ពីបរិមាណប្រាក់បើកជារង្វាន់បាន។ ប្រាក់បើកជារង្វាន់បែងចែកជាពីរ គឺប្រាក់បើកជារង្វាន់សម្រាប់ការងារទៀងទាត់ និងប្រាក់បើកជារង្វាន់សម្រាប់អតីតភាពការងារ។

នៅក្នុងវិស័យវាយនភណ្ឌកាត់ដេរ និងស្បែកជើងនៃព្រះរាជាណាចក្រកម្ពុជា និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានព្រមព្រៀងផ្តល់ប្រាក់រង្វាន់សម្រាប់ការងារទៀងទាត់

ចំពោះកម្មករនិយោជិតណា ដែលបានមកធ្វើការទៀងទាត់តាមចំនួនថ្ងៃនៃថ្ងៃធ្វើការធម្មតាក្នុងខែនីមួយៗដោយមិនអវត្តមាន យ៉ាងតិចចំនួន១០(ដប់)ដុល្លារអាមេរិកក្នុងមួយខែ ហើយចំពោះគ្រឹះស្ថាន រោងចក្រ សហគ្រាសណាដែលបានផ្តល់ប្រាក់រង្វាន់លើសពីការកំណត់នេះ ត្រូវរក្សាទុកប្រាក់រង្វាន់ដែលលើសនោះនៅដដែល[២២]។ ជាក់ស្តែង **ក្រុមហ៊ុន ធី និង ខេ ហ្គាមេនអ៊ីនដាស្ទ្រី ២ (T & K GARMENT INDUSTRY 2)** បានផ្តល់ប្រាក់រង្វាន់ទៀងទាត់ដល់កម្មករនិយោជិតក្នុងមួយខែចំនួន ១០(ដប់)ដុល្លារអាមេរិក **(ឧបសម្ព័ន្ធទី១)**។

មួយវិញទៀត យោងតាមសេចក្តីណែនាំនៃប្រកាសលេខ៣១៧ ក.ប/ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី "ការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗ" លេខ០០១/១៤ ក.ប/ស.ណ.ន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ បានកំណត់ថា កម្មករនិយោជិតទាំងឡាយដែលបម្រើការងារក្នុងគ្រឹះស្ថាន រោងចក្រ សហគ្រាសចាប់ពីឆ្នាំទី២(ពីរ)ឡើង ដល់ឆ្នាំទី១១(ដប់មួយ) ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួនពី២(ពីរ)ដុល្លារអាមេរិក ដល់១១(ដប់មួយ)ដុល្លារអាមេរិកក្នុងមួយខែ មានន័យថាកម្មករនិយោជិតដែលបានបំពេញការងារក្នុងគ្រឹះស្ថាន រោងចក្រ សហគ្រាសមួយចាប់ពី២(ពីរ)ឆ្នាំឡើងនឹងទទួលបានប្រាក់រង្វាន់ចំនួន២(ពីរ)ដុល្លារអាមេរិកសម្រាប់ការធ្វើការងារបាន២(ពីរ)ឆ្នាំ ៣(បី)ដុល្លារអាមេរិកសម្រាប់ការធ្វើការងារបាន៣(បី)ឆ្នាំ ៤(បួន)ដុល្លារអាមេរិកសម្រាប់ការធ្វើការងារបាន៤(បួន)ឆ្នាំ រហូតដល់១១(ដប់មួយ)ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់ការធ្វើការងារបានចាប់ពី១១(ដប់មួយ)ឆ្នាំឡើងទៅ ហើយចាប់ពីឆ្នាំទី១២(ដប់ពីរ)បន្តទៅទៀតក៏កម្មករនិយោជិតនៅតែទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន១១(ដប់មួយ)ដុល្លារអាមេរិកក្នុងមួយខែដដែល។ ខាងក្រោមនេះជាតារាងកំណត់អំពីប្រាក់រង្វាន់អតីតភាពការងារ ដកស្រង់ចេញពីសេចក្តីជូនដំណឹងលេខ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១៖

| អតីតភាពការងារគិតជាឆ្នាំ | ០១ | ០២ | ០៣ | ០៤ | ០៥ | ០៦ | ០៧ | ០៨ | ០៩ | ១០ | ១១ |
|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនទឹកប្រាក់ទទួលបានក្នុងមួយខែ គិតជាដុល្លារអាមេរិក | ០$ | ២$ | ៣$ | ៤$ | ៥$ | ៦$ | ៧$ | ៨$ | ៩$ | ១០$ | ១១$ |

[២២] សេចក្តីណែនាំលេខ០០១/១៤ ក.ប/ស.ណ.ន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តប្រកាសលេខ៣១៧ ក.ប/ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗ។

## ២.៨ តម្លៃអត្ថប្រយោជន៍ជាវត្ថុ

តម្លៃអត្ថប្រយោជន៍ជាវត្ថុ គឺសំដៅដល់ប្រភេទប្រាក់កម្រៃដែលត្រូវរាប់បញ្ចូលបានវត្ថុមួយចំនួនដែលនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានផ្តល់អោយកម្មករនិយោជិតជាភាគឈ្នួលមួយ ហើយកម្មករនិយោជិតអាចយកវត្ថុនោះទៅប្រើប្រាស់សម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន។ ជាក់ស្តែងសេចក្តីជូនដំណឹងលេខ០៦ សកអ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៧ កថាខណ្ឌទី១៣ ចំណុច "ឃ" បានចែងថា និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានឯកភាពផ្តល់ឲ្យកម្មករនិយោជិតណាដែលបានធ្វើការចាប់ពី០៦(ប្រាំមួយ)ខែឡើងទៅ ដោយគិតទាំងរយៈពេលធ្វើការងារសាកល្បងដូចជាសំលៀកបំពាក់ពលកម្ម២(ពីរសំរាប់)ម្នាក់ក្នុងមួយឆ្នាំដោយឥតគិតថ្លៃ។

## ២.៩ ប្រាក់ទទួលបានក្នុងពេលបាត់បង់សមត្ថភាពពលកម្ម

ប្រាក់ទទួលបានក្នុងពេលបាត់បង់សមត្ថភាពពលកម្ម សំដៅដល់ប្រាក់កម្រៃមួយប្រភេទដែលកម្មករនិយោជិតទទួលបាន ពេលដែលខ្លួនជួបហានិភ័យការងារ(គ្រោះថ្នាក់ការងារ)។ ហានិភ័យការងារ(គ្រោះថ្នាក់ការងារ) គឺជាហេតុការណ៍ ឬព្រឹត្តការណ៍ដែលកើតមានឡើងចំពោះកម្មករនិយោជិតដែលបម្រើការងារនៅក្នុងគ្រឹះស្ថាន រោងចក្រ សហគ្រាស ពោលទោះបីគ្រោះថ្នាក់នោះកើតឡើងដោយកំហុស ឬមិនមែនជាកំហុសរបស់កម្មករនិយោជិតគឺជា គ្រោះថ្នាក់ដែលកើតឡើងនៅក្នុងម៉ោងការងារ ចំពោះសិស្សវិជ្ជាជីវៈទោះបីមាន ឬមិនមានប្រាក់ឈ្នួលក្តី មានមុខតំណែងជាអ្វីក៏ដោយ ឬនៅទីកន្លែងណាក៏ដោយ ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ។ គ្រោះថ្នាក់ដែលកើតមានឡើងលើកម្មករនិយោជិតពេលធ្វើដំណើរចេញពីគ្រឹះស្ថាន រោងចក្រ សហគ្រាសត្រលប់ទៅលំនៅដ្ឋាន ឬចេញពីលំនៅដ្ឋានឆ្ពោះទៅកន្លែងការងារដោយគ្មានឈប់ ឬគ្មានធ្វើដំណើរវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីកន្លែងការងារដែលតម្រូវអោយទៅ។ ជម្ងឺទាំងឡាយណាដែលកើតមានឡើងលើកម្មករនិយោជិតដែលបណ្តាលមកពីវិជ្ជាជីវៈទាំងអស់ដូចមានបញ្ជាក់ក្នុងច្បាប់ ក៏ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ឬគេអាចហៅម្យ៉ាងទៀតបានថាជាជម្ងឺវិជ្ជាជីវៈ[២៣]។

នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)ត្រូវបានបង្កើតឡើងដោយស្ថិតនៅក្រោមអនុក្រឹត្យលេខ១៦ អនក្រ.បក និងត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពី "របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ" ហើយបេឡាជាតិរបបសន្តិសុខសង្គមគឺជានីតិបុគ្គលសាធារណៈដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ។ និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសទាំងអស់តម្រូវអោយចុះបញ្ជិកាក្នុងបេឡាជាតិ

[២៣] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា២៤៨។

របបសន្តិសុខសង្គម ហើយមានកាតព្វកិច្ចបង់ភាគទានផ្នែកហានិភ័យការងារ ស្មើនឹង០,៨%(សូន្យក្បៀសប្រាំបីភាគរយ)នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទាន នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត មុនកាត់ពន្ធ និងកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាព ត្រូវបានកំណត់ស្មើនឹង២,៦%(ពីរក្បៀសប្រាំមួយភាគរយ)នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទាន នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតមុនកាត់ពន្ធ[២៤] សម្រាប់ជាប្រយោជន៍ដល់កម្មករនិយោជិតរបស់ខ្លួននៅពេលដែលគ្រោះថ្នាក់ការងារកើតមានឡើង។

ចំពោះកម្មករនិយោជិតដែលជាសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គម នៅពេលដែលមានគ្រោះថ្នាក់ការងារកើតឡើងលើខ្លួន រាល់ការចំណាយលើការសង្គ្រោះជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ដោយកម្មករនិយោជិតទាំងនោះ(ជនរងគ្រោះដោយគ្រោះថ្នាក់ការងារ)ត្រូវទទួលបានការពិនិត្យព្យាបាល ការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ផ្អែកតាមកិច្ចព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គមជាមួយនឹងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលទាំងនោះ។ ដោយឡែកការផ្តល់តាវកាលិកដល់កម្មករនិយោជិតដែលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់ការបាត់បង់សមត្ថភាពពលកម្មបែងចែកចេញជាពីរ គឺការផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្ន និងការផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍។

ការផ្តល់តាវកាលិក ឬប្រាក់ទទួលបានសម្រាប់ការបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្ន មានន័យថាកម្មករនិយោជិត ឬជនរងគ្រោះដោយសារគ្រោះថ្នាក់ការងារបណ្តាលអោយអាក់ខានធ្វើការងារមិនកើតមួយរយៈពេលខ្លី ឬនៅក្នុងស្ថានភាពនៃការសម្រាកព្យាបាលមុខរបួស ឬជម្ងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ការសម្រាកក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា។ ការអាក់ខានធ្វើការងារថ្ងៃដំបូង ជនរងគ្រោះទទួលបានប្រាក់ឈ្នួលដូចធម្មតា(ជាបន្ទុករបស់និយោជក) ការអាក់ខានធ្វើការងារលើសពី០២(ពីរ)ថ្ងៃឡើងទៅ[២៥] ជនរងគ្រោះទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃស្មើនឹង៧០%(ចិតសិបភាគរយ)នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ហើយបើកម្មករនិយោជិតមានរបួសធ្ងន់ធ្ងរតម្រូវអោយមានអ្នកមើលថែទាំនៅមន្ទីរពេទ្យ ប្រាក់ឧបត្ថម្ភសម្រាប់អ្នក

[២៤] ប្រកាសលេខ៩៩៩ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់វិភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

[២៥] សេចក្តីជូនដំណឹងលេខ០១៥/១៥ ប.ស.ស ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥។

ថៃទាំស្មើនឹង៥០%(ហាសិបភាគរយ)នៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ ដែលស្ថិតនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។ មួយវិញទៀត ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារជាបណ្ដោះអាសន្ន បេឡាជាតិរបបសន្តិសុខសង្គមផ្ដល់ជូនជនរងគ្រោះហានិភ័យការងាររហូតដល់ជាសះស្បើយ[២៦]។

ចំណែកឯការផ្ដល់តាវកាលិក ឬប្រាក់ទទួលបានសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍វិញ គឺកម្មករនិយោជិតដែលទទួលរងហានិភ័យការងារធ្វើអោយបាត់បង់សមត្ថភាពការងារជាអន្ត្រៃយ៍តិចជាង២០%(ម្ភៃភាគរយ) មានសិទ្ធិទទួលបានប្រាក់វិភាជន៍តែម្ដងគត់ដោយត្រូវគណនាតាមរូបមន្តៈ

| |
|---|
| វបក = បឈម x កបក x ២០%មតប |
| • វបក ៖ វិភាជន៍បាត់បង់សមត្ថភាពការងារ |
| • បឈម ៖ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ |
| • កបក ៖ កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ |
| • មតប ៖ មេគុណតម្លៃបច្ចុប្បន្ន |

ចំពោះកម្មករនិយោជិតដែលទទួលរងហានិភ័យការងារ ដែលបណ្ដាលអោយបាត់បង់សមត្ថភាពការងារចាប់ពី២០%(ម្ភៃភាគរយ)ឡើងទៅ មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ដោយត្រូវគណនាតាមរូបមន្តៈ

| |
|---|
| ធល = បឈម x ៧0% x [ កបក - ១/៥ កបក ] x មតប |
| • ធល ៖ ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ |
| • បឈម ៖ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ |
| • កបក ៖ កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ |
| • មតប ៖ មេគុណតម្លៃបច្ចុប្បន្ន |

[២៦] ប្រកាសលេខ១៤០ កប/ប្រ.ក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្ដីពីការកែសម្រួលប្រការ៧ និងប្រការ៩ នៃប្រកាសលេខ ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីតាវកាលិកហានិភ័យការងារ ប្រការ៧ថ្មី។

ជាមួយគ្នានេះដែរ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ត្រូវចាត់ទុកជាបណ្ដោះអាសន្នជានិច្ច ហើយកម្មករនិយោជិត ឬជនរងគ្រោះដែលទទួលបានប្រាក់ធនលាភនេះមានកាតាព្វកិច្ចទៅពិនិត្យសុខភាព និងសមត្ថភាពការងារឡើងវិញយ៉ាងយូរ០១(មួយ)ឆ្នាំម្ដងតាមការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម។ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំតាមអនុលោមអត្រាអតិផរណា ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំណែកការកម្រិតនៃការបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ ត្រូវបានកំណត់នៅក្នុង**ឧបសម្ព័ន្ធ២** និងមេគុណតម្លៃបច្ចុប្បន្ន ត្រូវបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ៣** នៃប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពី "តាវកាលិកហានិភ័យការងារ"។ មួយវិញទៀត អ្នកចាំថែទាំកម្មករនិយោជិត ឬជនរងគ្រោះដោយហានិភ័យការងារ បណ្ដាលអោយបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភបន្ថែមស្មើ៥០%(ហាសិបភាគរយ)នៃប្រាក់ធនលាភរបស់ជនរងគ្រោះ ប៉ុន្តែសិទ្ធិទទួលបានអ្នកចាំថែទាំនេះ ត្រូវសម្រេចដោយនាយកបេឡាជាតិរបបសន្តិសុខសង្គម អនុលោមតាមការវាយតម្លៃរបស់គណៈកម្មការវេជ្ជសាស្ត្រ[២៧]។

ចំពោះកម្មករនិយោជិតណាដែលទទួលរងហានិភ័យការងារ រហូតដល់បាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍មានសិទ្ធិទទួលបានឧបករណ៍ ឬអវៈយវៈសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម និងទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកាយសម្បទាឡើងវិញ។

ក្នុងករណីកម្មករនិយោជិត ឬជនរងគ្រោះដោយហានិភ័យការងារ រហូតបណ្ដាលអោយបាត់បង់ជីវិត នោះអ្នកទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសព នឹងទទួលបានប្រាក់ភោជន៍ជាសោហ៊ុយបូជាសពជនរងគ្រោះចំនួន៤ ០០០ ០០០(បួនលាន)រៀល[២៨]។ ចំណែកអ្នកនៅក្នុងបន្ទុកនៃជនរងគ្រោះរហូតដល់ស្លាប់នេះ ឬហៅថាឧត្តរជីវីនៃជនរងគ្រោះដោយហានិភ័យការងារមានសិទ្ធិទទួលបានតាវកាលិកឧត្តរជីវី(ប្រាក់ធនលាភដែលត្រូវផ្ដល់អោយសិទ្ធិវន្តនៃជនរងគ្រោះ)តាមអត្រាៈ
១. ក្នុងករណីសិទ្ធិវន្ត មានទាំងប្រពន្ធ ឬប្ដី កូននិងឪពុកម្ដាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក

[២៧] ប្រកាសលេខ១៤០ កប/ប្រ.ក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្ដីពីការកែសម្រួលប្រការ៧ និងប្រការ៩ នៃប្រកាសលេខ ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីតាវកាលិកហានិភ័យការងារ ប្រការ៩ថ្មី។

[២៨] ប្រកាសលេខ២៣៣ កប.ប្រ.ក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្ដីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីតាវកាលិកហានិភ័យការងារ ប្រការ១០។

- ប្រពន្ធ ឬប្តី = ៣/៥ × ៦៣% បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ × ៦៣% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក = ៧% បឈម

២. ក្នុងករណីសិទ្ធិវន្តមានតែ ប្រពន្ធ ឬប្តី និង/ឬកូន

- ប្រពន្ធ ឬប្តី = ៣/៥ × ៧០% បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ × ៧០% បឈម

៣. ក្នុងករណីសិទ្ធិវន្ត មានតែឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក

- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក = ២៨% បឈម

៤. ក្នុងករណីសិទ្ធិវន្ត មានតែកូន និងឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក = ២៨% បឈម

៥. ក្នុងករណីសិទ្ធិវន្តមានតែ ប្រពន្ធ ឬប្តី និងឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក

- ប្រពន្ធ ឬប្តី = ២៨% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក = ២៨% បឈម

សិទ្ធិវន្តរបស់សមាជិកនៃបេឡាជាតិសន្តិសុខសង្គមដែលត្រូវទទួលតាវកាលិកឧត្តរជីវីមានលក្ខណៈសម្បត្តិដូចជា៖

- ប្រពន្ធ ឬប្តីស្របច្បាប់ដោយមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ និងមិនមានការលែងលះគ្នារហូតដល់ថ្ងៃគ្រោះថ្នាក់។
- កូនមានអាយុត្រឹម១៨ឆ្នាំចុះ ដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ហើយជាកូនស្របច្បាប់ ឬកូនចញ្ចឹមរបស់ជនរងគ្រោះ។ ម្យ៉ាងទៀតក៏អាចឧបត្ថម្ភរហូតដល់កូនជនរងគ្រោះមានអាយុ២១ឆ្នាំ បើកូននោះកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬកំពុងរៀននៅតាមគ្រឹះស្ថានសិក្សាដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច និងមានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ និងកូនពិការ ឬមានជម្ងឺរ៉ាំរ៉ៃមិនមានលទ្ធភាពធ្វើការងារ។
- ឪពុកម្តាយ ឬមនុស្សចាស់ជរាដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់ជនរងគ្រោះ។

ចំពោះគ្រឹះស្ថាន រោងចក្រ សហគ្រាសណាដែលមិនទាន់បានចុះបញ្ជិកានៅក្នុងបេឡាជាតិសន្តិសុខសង្គម ការផ្តល់តាវកាលិកសម្រាប់ហានិភ័យការងារ ត្រូវអនុវត្តតាមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧របស់ព្រះរាជាណាចក្រកម្ពុជា មានន័យថា បើកម្មករនិយោជិត ឬជនរងគ្រោះដោយហានិភ័យការងារកើតឡើងមកលើខ្លួន នោះការផ្តល់តាវកាលិកជាបន្ទុករបស់និយោជក ឬ

ម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសផ្ទាល់[២៩]។ អ្នករងគ្រោះដែលបានបង្កគ្រោះថ្នាក់ដោយចេតនារបស់ខ្លួន មិនមានសិទ្ធិទទួលបានប្រាក់បំណាច់អ្វីឡើយ។ តុលាការមានសមត្ថកិច្ចអាចធ្វើការបន្ថយប្រាក់បំណាច់សម្រាប់ជួសជុលនេះបាន កាលណាបើរកឃើញថាគ្រោះថ្នាក់ការងារបណ្តាលមកពីកំហុសធ្ងន់នៃជនរងគ្រោះ ឬអាចបន្ថែមប្រាក់បំណាច់នេះបាន កាលណាបើរកឃើញថាគ្រោះថ្នាក់ការងារបណ្តាលមកពីកំហុសធ្ងន់នៃនិយោជក ឬអ្នកជំនួសនិយោជកក្នុងការដឹកនាំការងារ[៣០]។

## ២.១០ ប្រាក់ទទួលបានក្នុងពេលលំហែមាតុភាព

ប្រាក់ទទួលបានក្នុងពេលលំហែមាតុភាពគឺជាប្រាក់ឈ្នួលមួយប្រភេទដែលកម្មករនិយោជិតជាស្ត្រីទទួលបាននៅពេលដែលខ្លួនឈប់សម្រាក៩០(កៅសិប)ថ្ងៃដើម្បីសម្រាលកូន មានន័យថាកម្មករនិយោជិតជាស្ត្រីដែលបានបំពេញការងារនៅក្នុងគ្រឹះស្ថាន រោងចក្រ សហគ្រាសបានយ៉ាងតិច០១(មួយ)ឆ្នាំមានសិទ្ធិទទួលបានប្រាក់ឈ្នួលស្មើនឹងពាក់កណ្តាលនៃប្រាក់ឈ្នួលធម្មតា បូករួមទាំងប្រាក់បន្ទាប់បន្សំផងក្នុងរយៈពេលនៃការសម្រាកដើម្បីសម្រាលកូននេះ[៣១]។

ចំពោះកម្មករនិយោជិតជាស្ត្រីនៃគ្រឹះស្ថាន រោងចក្រ សហគ្រាសដែលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ត្រូវទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃដូចមានចែងនៅក្នុងប្រកាសលេខ១០៩ កប.ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីតារាកាលិកថែទាំសុខភាព គឺស្មើនឹង៧០%(ចិតសិបភាគរយ)នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីជន សម្រាប់រយៈពេល៩០(កៅសិប)ថ្ងៃនៃការឈប់សម្រាកមុន និងក្រោយសម្រាលកូន ក្នុងករណីដែលគាត់បានបង់ភាគទានយ៉ាងតិច០៩(ប្រាំបួន)ខែជាប់គ្នាទៅអោយបេឡាជាតិរបបសន្តិសុខសង្គម[៣២]។

---

[២៩] ប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតារាកាលិកហានិភ័យការងារ។

[៣០] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា២៥២ កថាខណ្ឌទី២។

[៣១] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១៨២ និងមាត្រា១៨៣។

[៣២] សេចក្តីជូនដំណឹងលេខ០១៤/១៧ ក.ប/ស.ជ.ណ.ក.ប.ក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការផ្តល់ប្រាក់ឈ្នួល និងប្រាក់បំណាច់ប្រចាំថ្ងៃចំពោះកម្មករនិយោជិតជាស្ត្រីសម្រាប់រយៈពេលនៃការឈប់សម្រាកមាតុភាព។

ជាមួយគ្នានេះដែរគោលការណ៍របស់ប្រមុខរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សម្រាប់កម្មករនិយោជិតជាស្ត្រីមានផ្ទៃពោះ (សមាជិកបេឡាជាតិរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព) និងក្នុងពេលលំហែមាតុភាពមានសិទ្ធិទទួលបាន[៣៣]៖

- សេវាពិនិត្យសុខភាពមុន និងក្រោយការសម្រាកមាតុភាពដោយឥតគិតថ្លៃ។
- ការអនុញ្ញាតចេញមុនម៉ោងការងារយ៉ាងតិច១៥នាទី។
- ប្រាក់ឈ្នួលសរុប ១២០%(មួយរយម្ភៃភាគរយ) ដោយ៥០%(ហាសិបភាគរយ)ទទួលបានពីនិយោជក និង៧០%(ចិតសិបភាគរយ)ទទួលបានពីបេឡាជាតិរបបសន្តិសុខសង្គម។
- ប្រាក់ឧបត្ថម្ភពីបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់ការសម្រាលកូនទោល ៤០០ ០០០ (បួនសែន)រៀល សម្រាលកូនភ្លោះពីរនាក់ចំនួន ៨០០ ០០០(ប្រាំបីសែន)រៀល និងសម្រាលកូនភ្លោះបីនាក់ចំនួន១ ២០០ ០០០(មួយលានពីរសែន)រៀល ទោះបីក្រោយការសម្រាលកូនទារករស់ ឬស្លាប់ក៏ដោយ[៣៤]។

## ផ្នែកទី៣៖ ប្រាក់វិភាជន៍ផ្តល់ដោយនិយោជក

ប្រាក់វិភាជន៍ គឺជាប្រាក់កម្រៃមួយប្រភេទដែលនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានផ្តល់អោយកម្មករនិយោជិតបន្ថែមលើប្រាក់ឈ្នួលគោល។ ប្រាក់វិភាជន៍នេះមានបែងចែកជាពីរប្រភេទ គឺប្រាក់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់ និង ប្រាក់វិភាជន៍ឈប់សម្រាក ឬប្រាក់បំណាច់សម្រាប់ទូទាត់ការឈប់សម្រាក។

### ៣.១ ប្រាក់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់

ប្រាក់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវច្បាប់ សំដៅដល់ទឹកប្រាក់ ឬកម្រៃ ឬភាគឈ្នួលដែលនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានផ្តល់ ឬឧបត្ថម្ភជារៀងរាល់ខែអោយក្រុមគ្រួសាររបស់កម្មករនិយោជិត ឬបុគ្គលិកដែលបានបម្រើការងារ ប៉ុន្តែជាក់ស្តែងយើងពុំមានបទប្បញ្ញត្តិណាមួយបានកំណត់ច្បាស់លាស់នោះទេ។ ជាទូទៅប្រាក់វិភាជន៍គ្រួសារសម្រាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់ និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ

[៣៣] យោងតាមប្រសាសន៍សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រកាសនៅចំពោះមុខកម្មករ-កម្មការិនីប្រមាណ១ម៉ឺននាក់ នៅរោងចក្រតំបន់កំបូល តាមផ្លូវជាតិលេខ៤ នាព្រឹកថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៧

[៣៤] ប្រកាសអន្តរក្រសួងលេខ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធមិសុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

សហគ្រាសជាអ្នកកំណត់នៅក្នុងអនុសញ្ញារួម។ ឧទាហរណ៍ **ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA Bank Plc)** បានផ្តល់ប្រាក់ឧបត្ថម្ភអោយកូនម្នាក់ៗ ១៥(ដប់ប្រាំ)ដុល្លារអាមេរិកក្នុងមួយខែចំពោះបុគ្គលិកពេញសិទ្ធិ។

## ៣.២ ប្រាក់វិភាជន៍ឈប់សម្រាក ឬប្រាក់បំណាច់សម្រាប់ទូទាត់ការឈប់សម្រាក

ប្រាក់វិភាជន៍ឈប់សម្រាក ឬប្រាក់បំណាច់សម្រាប់ទូទាត់ការឈប់សម្រាក គឺជាប្រាក់ដែលកម្មករនិយោជិតទទួលបានពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសនៅថ្ងៃឈប់សម្រាកដែលច្បាប់មានចែង ឬតាមប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារដែលបានកំណត់ថា កម្មករនិយោជិតដែលបំពេញការងារ មានសិទ្ធិទទួលបានប្រាក់ឈ្នួលនៅថ្ងៃឈប់សម្រាកពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស។ ប្រភេទនៃប្រាក់វិភាជន៍ឈប់សម្រាក ឬប្រាក់បំណាច់សម្រាប់ទូទាត់ការឈប់សម្រាកមានដូចជា ការឈប់សម្រាកថ្ងៃបុណ្យមានប្រាក់ឈ្នួល ការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល និងការឈប់សម្រាកពិសេសមានប្រាក់ឈ្នួល ឬប្រាក់ចំណាយពេលមានទស្សនកិច្ចម្តងៗ។

### ក. ការឈប់សម្រាកថ្ងៃបុណ្យមានប្រាក់ឈ្នួល

ជារៀងរាល់ចុងឆ្នាំក្រសួងទទួលបន្ទុកវិស័យការងារ (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) មានសមត្ថកិច្ចក្នុងការចេញសេចក្តីប្រកាសស្តីពី "ការឈប់បុណ្យដែលមានប្រាក់ឈ្នួលប្រចាំឆ្នាំ" សម្រាប់ឆ្នាំថ្មី ដោយបានអនុញ្ញាតអោយកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថាន ទាំងអស់ឈប់សម្រាកពីការងារដោយទទួលបានប្រាក់ឈ្នួល។ ជាក់ស្តែងនៅថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែធ្នូ គ.ស២០១៧ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញប្រកាសលេខ៤៩៣ ក.ប/ប្រ.ក.អ.ធ.ក ស្តីពី "ការឈប់បុណ្យដែលមានប្រាក់ឈ្នួលប្រចាំឆ្នាំ២០១៨" ដោយអនុញ្ញាតអោយកម្មករនិយោជិតនៃគ្រឹះស្ថាន រោងចក្រ សហគ្រាសទាំងអស់បានឈប់សម្រាកពីការងារដោយមានប្រាក់ឈ្នួល សរុបចំនួន២៧(ម្ភៃប្រាំពីរ)ថ្ងៃ សម្រាប់ឆ្នាំ២០១៨ ដោយអនុវត្តចាប់តាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ។ មួយវិញទៀត នៅថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ គ.ស២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញប្រកាសលេខ០៨៩/១៨ ក.ប/ប្រ.ក.អ.ធ.ក ស្តីពី "ការឈប់សម្រាកទិវាជាតិនៃការចងចាំ" ដោយបានអនុញ្ញាតអោយកម្មករនិយោជិតនៃគ្រឹះស្ថាន រោងចក្រ សហគ្រាសទាំងអស់ដែលបានកំណត់ក្នុងមាត្រា១នៃច្បាប់ស្តីពីការងារ បានឈប់សម្រាកពីការងារដោយមានប្រាក់ឈ្នួលចំនួន០១(មួយ)ថ្ងៃបន្ថែមគឺនៅថ្ងៃទី២០ ខែឧសភា ជារៀងរាល់ឆ្នាំ ស្របតាមអនុក្រឹត្យលេខ១៩ អនក្រ.បក. ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី "ទិវាជាតិនៃការចងចាំ"។ ដូចនេះនៅក្នុង

ឆ្នាំ២០១៨ កម្មករនិយោជិតទាំងអស់ត្រូវបានអនុញ្ញាតអោយឈប់សម្រាកដោយមានប្រាក់ឈ្នួលសរុបចំនួន២៨(ម្ភៃប្រាំបី)ថ្ងៃ។ ចំពោះថ្ងៃឈប់សម្រាកបុណ្យទាំងឡាយណា ដែលឈប់សម្រាកចំថ្ងៃអាទិត្យ ត្រូវលើកមួយថ្ងៃបន្តទៀតអោយកម្មករនិយោជិតឈប់សម្រាក (ជាក់ស្តែង បុណ្យចូលឆ្នាំប្រពៃណីខ្មែរឆ្នាំ២០១៨ គឺចាប់ពីថ្ងៃសៅរ៍ ទី១៤ រហូតដល់ ថ្ងៃច័ន្ទ ទី១៦ ខែមេសា ដែលប៉ះចំថ្ងៃអាទិត្យមួយថ្ងៃ ហេតុនេះបណ្តាលគ្រឹះស្ថាន រោងចក្រ សហគ្រាសបានអនុញ្ញាតអោយកម្មករនិយោជិតឈប់សម្រាកបានមួយថ្ងៃបន្តទៀតដោយតម្រូវអោយកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញនៅថ្ងៃពុធ ទី១៨ ខែមេសា ឆ្នាំ២០១៨)។

ចំពោះការឈប់សម្រាកថ្ងៃបុណ្យមានប្រាក់ឈ្នួលនេះមានន័យថា ទោះបីកម្មករនិយោជិតទាំងអស់បានឈប់សម្រាកនៅថ្ងៃបុណ្យក៏ដោយ ក៏កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឈ្នួលធម្មតាដូចថ្ងៃធ្វើការងារដែរ ហើយការឈប់សម្រាកថ្ងៃបុណ្យនេះមិនមែនជាមូលហេតុដែលបណ្តាលអោយនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស កាត់បន្ថយប្រាក់កម្រៃប្រចាំខែ ប្រចាំអឌ្ឍមាស ឬប្រចាំសប្តាហ៍របស់កម្មករនិយោជិតឡើយ។ កម្មករនិយោជិតទាំងឡាយណាដែលបំពេញការងារតាមម៉ោង ប្រចាំថ្ងៃ ឬតាមបរិមាណផលិតផល មានសិទ្ធិទទួលបានប្រាក់បំណាច់ស្មើនឹងប្រាក់ឈ្នួលដែលបានបង់ខាតមកពីការឈប់សម្រាកថ្ងៃបុណ្យ។ និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសជាអ្នកទទួលបន្ទុកទាំងស្រុងលើប្រាក់បំណាច់នេះ[៣៥]។ ម្យ៉ាងទៀតក្នុងករណីចាំបាច់ដែលគ្រឹះស្ថាន រោងចក្រ សហគ្រាសមិនអាចឈប់ដំណើរការបាននៅថ្ងៃឈប់បុណ្យ នោះនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសអាចធ្វើការពិភាក្សាជាមួយកម្មករនិយោជិតដើម្បីអោយនិយោជិតធ្វើការនៅថ្ងៃឈប់បុណ្យ ប៉ុន្តែការធ្វើការងារនៅថ្ងៃឈប់បុណ្យនេះត្រូវគោរពតាមគោលការណ៍ស្ម័គ្រចិត្ត និងនិយោជកត្រូវជូនដំណឹងទៅអធិការការងារដែរ។ ចំណែកឯកម្មករនិយោជិតទាំងឡាយណា ដែលបានយល់ព្រមបំពេញការងារនៅថ្ងៃឈប់បុណ្យនេះមានសិទ្ធិទទួលបានក្រៅពីប្រាក់ឈ្នួលនៃការងារដែលខ្លួនបានធ្វើ ប្រាក់បំណាច់ដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលប្រចាំថ្ងៃធ្វើការធម្មតា[៣៦]។

---

[៣៥] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១៦៣។

[៣៦] ប្រកាសលេខ១០ សកបយ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពី ប្រាក់បំណាច់នៃការងារដែលបានធ្វើក្នុងឱកាសថ្ងៃឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល។

### ខ. ការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល

យោងតាមច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១៦៥បានកំណត់ថា កម្មករនិយោជិតនៅតាមបណ្តាគ្រឹះស្ថាន រោងចក្រ សហគ្រាសទាំងឡាយណាដែលបានបំពេញការងារជាប់លាប់ ត្រូវបានអនុញ្ញាតអោយមានការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលដែលជាបន្ទុករបស់និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស មានន័យថាកម្មករនិយោជិតណាដែលបានធ្វើការងារជាមធ្យមចំនួន២១(ម្ភៃមួយ)ថ្ងៃក្នុងមួយខែ ទោះបីជាមិនបានធ្វើការងារទៀងទាត់ក្នុងមួយឆ្នាំក៏ដោយ ក៏មានសិទ្ធិទទួលបានការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួលសរុបចំនួន ១៨(ដប់ប្រាំបី)ថ្ងៃក្នុងមួយឆ្នាំ ឬស្មើនឹងមួយថ្ងៃកន្លះក្នុងមួយខែ។ ជាមួយគ្នានេះដែរចំពោះកម្មករនិយោជិតដែលបានបំពេញការងារនៅក្នុងគ្រឹះស្ថាន រោងចក្រ សហគ្រាសតែមួយចាប់ពី៣(បី)ឆ្នាំឡើងទៅនឹងទទួលបាន១(មួយ)ថ្ងៃបន្ថែមចំពោះថ្ងៃឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល ដែលស្មើនឹង១៩(ដប់ប្រាំបួន)ថ្ងៃក្នុងមួយឆ្នាំ មានន័យថា និយោជកត្រូវបន្ថែមថ្ងៃឈប់សម្រាកប្រចាំឆ្នាំ ១(មួយ)ថ្ងៃទៀត(ថ្ងៃធ្វើការ)ដោយគិតតាមអតីតភាពការងាររបស់កម្មករនិយោជិតសម្រាប់៣(បី)ឆ្នាំម្តង។ ប្រសិនបើកម្មករនិយោជិតនៅតាមបណ្តាគ្រឹះស្ថាន រោងចក្រ សហគ្រាសមិនបានបំពេញការងារចំនួន២(ពីរ)ខែជាប់គ្នា មានសិទ្ធិទទួលបានប្រាក់បំណាច់ឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល ដោយគិតសមាមាត្រនឹងពេលវេលាដែលបានបម្រើការងារ នៅពេលដែលកម្មករនិយោជិតនោះផ្តាច់កិច្ចសន្យាការងារ។

មួយវិញទៀត កម្មករនិយោជិតទាំងអស់មានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល លុះត្រាតែបានបំពេញការងារបានមួយឆ្នាំជាមុនសិន។ ចំពោះការពន្យារពេលឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលមិនអាចអោយលើសពី៣(បី)ឆ្នាំបន្តបន្ទាប់គ្នាបានទេ ហើយអាចអនុវត្តបានតែចំពោះភាគនៃការឈប់សម្រាកណាដែលហួសពី១២(ដប់ពីរ)ថ្ងៃ ដែលជាថ្ងៃធ្វើការក្នុងមួយឆ្នាំ។ ក្នុងករណីកម្មករនិយោជិតសុខចិត្តលើកសិទ្ធិឈប់សម្រាកខ្លះ ឬទាំងមូលទៅប្រើប្រាស់នៅពេលចប់កិច្ចសន្យាការងារ មិនត្រូវចាត់ទុកជាការលះបង់សិទ្ធិនោះទេ។ម្យ៉ាងវិញទៀតចំពោះអនុសញ្ញារួមទាំងឡាយណាដែលគ្រោងផ្តល់ប្រាក់បំណាច់ ដោយទូទាត់សម្រាប់ការជួសការឈប់សម្រាកប្រចាំឆ្នាំព្រមទាំងមានការព្រមព្រៀងស្តីពីការបោះបង់ ឬមិនព្រមប្រើសិទ្ធិឈប់សម្រាកប្រចាំឆ្នាំ ត្រូវចាត់ទុកជាមោឃៈ[៣៧]។ កម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឈ្នួលពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស នៅមុនថ្ងៃឈប់សម្រាក ប្រាក់វិភាជន៍យ៉ាងហោចណាស់ស្មើនឹងចំនួនមធ្យមនៃប្រាក់ឈ្នួលបុព្វលាភ ប្រាក់វិភាជន៍ ប្រាក់អត្ថប្រយោជន៍ ប្រាក់បំណាច់ ដោយមិនគិតពីប្រាក់

---

[៣៧] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១៦៧។

បំណាច់សោហ៊ុយដែលកម្មករនិយោជិតបើករួចហើយអោយក្នុងរយៈពេល ១២(ដប់ពីរ)ខែមុនថ្ងៃឈប់សម្រាកឡើយ។ ក្នុងករណីកម្មករនិយោជិតធ្វើការងារទៀងទាត់ ប្រាក់វិភាជន៍នេះមិនត្រូវទទួលបានតិចជាងប្រាក់វិភាជន៍ដែលកម្មករត្រូវបើកនោះទេ[៣៨]។

ចំពោះបទប្បញ្ញត្តិដែលមានចែងនៅក្នុងអនុសញ្ញារួម ឬកិច្ចសន្យាការងារទាំងឡាយណាដែលបានផ្តល់អត្ថប្រយោជន៍ដល់កម្មករនិយោជិតលើសពីបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ដូចដែលបានរៀបរាប់ខាងលើ កម្មករនិយោជិតមានសិទ្ធិទទួលបានអត្ថប្រយោជន៍ឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលស្របតាមអនុសញ្ញារួម ឬកិច្ចសន្យានោះ។ ជារួមគ្នានេះដែរ ក្នុងករណីដែលការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល មានថិរវេលាច្រើនជាង១៥(ដប់ប្រាំ)ថ្ងៃ និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសមានសិទ្ធិក្នុងការទុកថ្ងៃឈប់សម្រាក ដែលនៅសល់ទាំងប៉ុន្មានអោយឈប់ក្នុងពេលណាមួយផ្សេងទៀតក្នុងឆ្នាំនោះ លើកលែងតែមានការឈប់សម្រាកការងារក្មេង និងកូនជាងដែលមានអាយុតិចជាង ១៨(ដប់ប្រាំបី)ឆ្នាំ។

**គ. ការឈប់សម្រាកពិសេសមានប្រាក់ឈ្នួល**

ការឈប់សម្រាកពិសេសមានប្រាក់ឈ្នួលនេះ គឺជាការឈប់សម្រាកមួយបែបទៀតរបស់កម្មករនិយោជិតនៃគ្រឹះស្ថាន រោងចក្រ សហគ្រាសដែលកម្មករនិយោជិតនោះមានធុរៈផ្ទាល់ខ្លួន រួមទាំងត្រូវមានការអនុញ្ញាតដោយស្របច្បាប់ពីនិយោជក និងតម្រូវអោយកម្មករនិយោជិតបំពេញតាមលក្ខខណ្ឌមួយចំនួនដែរ។ នៅត្រង់ចំណុចនេះមានន័យថា និយោជកនៃគ្រឹះស្ថាន រោងចក្រ សហគ្រាសទាំងអស់ មានសិទ្ធិអនុញ្ញាតអោយកម្មករនិយោជិតរបស់ខ្លួនបានឈប់សម្រាកពិសេសមានប្រាក់ឈ្នួលមិនលើសពី០៧(ប្រាំពីរ)ថ្ងៃក្នុងមួយឆ្នាំ នៅពេលដែលកម្មករនិយោជិតនោះមានធុរៈផ្ទាល់ខ្លួន ឬមានព្រឹត្តិការណ៍កើតមានឡើងនៅក្នុងក្រុមគ្រួសាររបស់កម្មករនិយោជិតផ្ទាល់ដូចជាការរៀបអាពាហ៍ពិពាហ៍របស់បុគ្គល(កម្មករនិយោជិតផ្ទាល់) ឪពុក ម្តាយ ប្តី ប្រពន្ធ កូនមានជម្ងឺ ឬទទួលមរណភាព ប្រពន្ធសម្រាលកូន ការរៀបអាពាហ៍ពិពាហ៍របស់កូនជាដើម។ នៅក្នុងនោះដែរបើកម្មករនិយោជិតមិនទាន់បានអនុវត្ត ឬប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលទាំងអស់របស់ខ្លួន នោះនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសអាចធ្វើការទូទាត់ដោយកាត់កងការឈប់ពិសេសនេះ ពីការឈប់សម្រាកប្រចាំឆ្នាំរបស់កម្មករនិយោជិត។ មួយវិញទៀត បើកម្មករនិយោជិតបានអនុវត្ត ឬប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលទាំងអស់របស់ខ្លួន នោះនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសអាចតម្រូវអោយកម្មករនិយោជិតនោះធ្វើការងារ

[៣៨] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១៦៨។

សងចំពោះការឈប់សម្រាកពិសេសនេះ ក្នុងអំឡុងពេល៩០(កៅសិប)ថ្ងៃបន្ទាប់ពីថ្ងៃឈប់សម្រាកពិសេស ដោយកម្មករនិយោជិតត្រូវអនុវត្តក្នុងថ្ងៃធ្វើការងារធម្មតា និងត្រូវគោរពតាមលក្ខខណ្ឌថិរវេលាធ្វើការងារសរុបមិនលើសពី១០(ដប់)ម៉ោងក្នុងមួយថ្ងៃ ឬ៦០(ហុកសិប)ម៉ោងក្នុងមួយសប្តាហ៍ គិតទាំងម៉ោងបន្ថែម ឬម៉ោងសងជំនួស ហើយកម្មករនិយោជិតនោះត្រូវទទួលបានអត្រាប្រាក់ឈ្នួលតាមពេលម៉ោងធ្វើការងារធម្មតា[៣៩]។

## ផ្នែកទី៤៖ ប្រាក់មិនរាប់បញ្ចូលជាប្រាក់ឈ្នួល

នៅក្នុងច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ប្រាក់មិនរាប់បញ្ចូលជាប្រាក់ឈ្នួល គឺជាប្រាក់កម្រៃមួយប្រភេទដែលនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានផ្តល់អោយកម្មករនិយោជិតរបស់ខ្លួន ហើយប្រាក់កម្រៃក៏ពុំត្រូវបានរាប់បញ្ចូលជាប្រាក់បន្ទាប់បន្សំនោះមានដូចជា ប្រាក់ឧបត្ថម្ភសម្រាប់ការព្យាបាលសុខភាព វិភាជន៍គ្រួសារតាមច្បាប់ សោហ៊ុយធ្វើដំណើរ និងអត្ថប្រយោជន៍ដើម្បីសម្របសម្រួលការបំពេញមុខងារ។

### ៤.១ ការព្យាបាលសុខភាព

ចំពោះកម្មករនិយោជិតនៃគ្រឹះស្ថាន រោងចក្រ សហគ្រាសទាំងអស់មានសិទ្ធិទទួលប្រាក់ឧបត្ថម្ភសម្រាប់ការព្យាបាលសុខភាពរបស់ខ្លួនពេលដែលធ្លាក់ខ្លួនឈឺ ឬមានជម្ងឺ ពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស។ យោងតាមសេចក្តីជូនដំណឹងលេខ២០៦ កប/ស.ជ.ណា ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ដោយគោរពតាមប្រសាសន៍ជាគោលការណ៍ដល់ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុងវេទិការសម្រាប់វិស័យឯកជន និងរាជរដ្ឋាភិបាលលើកទី១៦ កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ និងលិខិតលេខ១៤៧៧ សជណ.អវ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងចំពោះអង្គការសហជីពគ្រប់ថ្នាក់ សមាគមនិយោជក កម្មករនិយោជិត និងនិយោជក នៃរោងចក្រ សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា សូមអនុវត្តរបៀបផ្តល់ប្រាក់ឧបត្ថម្ភថែទាំសុខភាពចំនួន ៥(ប្រាំ)ដុល្លារអាមេរិកក្នុងមួយខែសម្រាប់កម្មករនិយោជិតទាំងអស់ ដែលធ្វើការផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង។ ប្រាក់ឧបត្ថម្ភនេះមិនត្រូវបានបូករួមបញ្ចូលធ្វើជាប្រាក់ឈ្នួលសុទ្ធសាធនោះទេ(ប្រាក់ឈ្នួលគោល)។ បន្ថែមលើនេះចំពោះកម្មករនិយោជិតដែលចូល

---

[៣៩] ប្រកាសលេខ២៦៧ សកបយ. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ស្តីពីការឈប់សម្រាកពិសេស។

បម្រើការងារថ្មីក្នុងខែដំបូងមានរយៈពេលមិនគ្រប់ ២៦(ម្ភៃប្រាំមួយ)ថ្ងៃ នៃថ្ងៃធ្វើការក្នុងមួយខែ គិតត្រឹមថ្ងៃបើកប្រាក់ឈ្នួល ត្រូវទទួលបានប្រាក់ឧបត្ថម្ភថែទាំសុខភាពដូចជា កម្មករនិយោជិតធ្វើការបានរយៈពេល១៣(ដប់បី)ថ្ងៃចុះក្រោម ទទួលបានប្រាក់ឧបត្ថម្ភថែទាំសុខភាពចំនួន២,៥(ពីរក្បៀសប្រាំ)ដុល្លារសហរដ្ឋអាមេរិក ដែលស្មើនឹងពាក់កណ្ដាល។ កម្មករនិយោជិតធ្វើការបានរយៈពេល១៤(ដប់បួន)ថ្ងៃឡើង ទទួលបានប្រាក់ឧបត្ថម្ភថែទាំសុខភាពពេញចំនួន៥(ប្រាំ)ដុល្លារសហរដ្ឋអាមេរិក។ ចំណែកឯកម្មករនិយោជិតធ្វើការយកកម្រៃតាមថ្ងៃ ឬតាមសប្ដាហ៍ទទួលបានប្រាក់ឧបត្ថម្ភថែទាំសុខភាពដោយគណនាតាមអត្រាប្រចាំថ្ងៃ ស្មើនឹង០,២(សូន្យក្បៀសពីរ)ដុល្លារសហរដ្ឋអាមេរិកក្នុងមួយថ្ងៃ។

ដោយឡែកសេចក្ដីជូនដំណឹងលេខ១០៣ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ គោរពតាមប្រសាសន៍ជាគោលការណ៍ដល់ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** យោងតាមសេចក្ដីជូនដំណឹងរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ៥០៦ សជណ.អវ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ និងសេចក្ដីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាការងារ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សូមជូនដំណឹងចំពោះអង្គការសហជីពគ្រប់ថ្នាក់ សមាគមនិយោជក កម្មករនិយោជិត និងនិយោជក នៃរោងចក្រ សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ប្រាក់ឧបត្ថម្ភថែទាំសុខភាពចំនួន៥(ប្រាំ)ដុល្លារសហអាមេរិកក្នុងមួយខែ ដែលបានសម្រេចផ្ដល់អោយកាលពីឆ្នាំ២០១១ ត្រូវបញ្ចូលទៅក្នុងប្រាក់ឈ្នួលគោល របស់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងគ្រប់ៗគ្នា។

ជាមួយគ្នានេះដែរ ចំពោះកម្មករនិយោជិតជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម ទទួលបានសេវាពិនិត្យថែទាំ និងបង្ការសុខភាពដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម[៤០]។

## ៤.២ វិភាជន៍គ្រួសារតាមច្បាប់

វិភាជន៍គ្រួសារតាមច្បាប់ គឺជាប្រាក់ដែលច្បាប់តម្រូវផ្ដល់អោយដល់សមាជិកគ្រួសារនៅក្នុងបន្ទុករបស់កម្មករនិយោជិតជារៀងរាល់ខែ។ នាពេលបច្ចុប្បន្នយើងសង្កេតឃើញថាវិភាជន៍គ្រួសារតាមច្បាប់នេះមិនទាន់មានការអនុវត្តចំពោះកម្មករនិយោជិតទេ ប៉ុន្តែផ្ទុយទៅវិញវិភាជន៍គ្រួសារតាម

[៤០] អនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្ដីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ។

ច្បាប់នេះបានអនុវត្តចំពោះមន្ត្រីរាជការស៊ីវិល។ ប្រពន្ធរបស់មន្ត្រីរាជការស៊ីវិលទទួលបានវិភាជន៍គ្រួសារប្រចាំខែពី៦ ០០០(ប្រាំមួយពាន់)រៀល ទៅ១៥ ០០០(មួយម៉ឺនប្រាំពាន់)រៀលក្នុងមួយខែ ស្របពេលកូនម្នាក់ៗរបស់មន្ត្រីរាជការស៊ីវិលទទួលបានវិភាជន៍គ្រួសារប្រចាំខែពី៥ ០០០(ប្រាំពាន់)រៀល ទៅ១០ ០០០(មួយម៉ឺន)រៀលក្នុងមួយខែរហូតដល់កូនម្នាក់ៗមានអាយុ២១(ម្ភៃមួយ)ឆ្នាំ[៧]។

## ៤.៣ សោហ៊ុយធ្វើដំណើរ

យោងតាមសេចក្តីជូនដំណឹងលេខ២៣០ ក.ប/ស.ជ.ណ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ បានសម្រេចថា កម្មករនិយោជិតក្នុងព្រះរាជាណាចក្រកម្ពុជានៃគ្រឹះស្ថាន រោងចក្រ សហគ្រាសផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងទាំងអស់មានសិទ្ធិទទួលបានសោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន៧(ប្រាំពីរ)ដុល្លារអាមេរិកក្នុងមួយខែពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសរបស់ខ្លួន លើកលែងតែនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសនោះបានផ្តល់មធ្យោបាយធ្វើដំណើរ ឬកន្លែងស្នាក់នៅសម្រាប់កម្មករនិយោជិត។ ប៉ុន្តែបើមានអនុសញ្ញារួម ឬកិច្ចសន្យាមានការកំណត់ពីការផ្តល់សោហ៊ុយធ្វើដំណើរ ឬផ្តល់កន្លែងស្នាក់នៅប្រសើរជាងនេះ ត្រូវរក្សាទុកអោយនៅដដែល។ ជាក់ស្តែង **ក្រុមហ៊ុន ធី និង ខេ ហ្គាមេនអ៊ីនដាស្ទ្រី ២ (T & K GARMENT INDUSTRY 2)** បានផ្តល់សោហ៊ុយធ្វើដំណើរដល់កម្មករនិយោជិតក្នុងមួយខែចំនួន៧(ប្រាំពីរ)ដុល្លារអាមេរិក (**ឧបសម្ព័ន្ធទី១**)។

## ៤.៤ អត្ថប្រយោជន៍ដើម្បីសម្រួលការបំពេញការងារ

អត្ថប្រយោជន៍ដើម្បីសម្រួលការបំពេញការងារ គឺសំដៅដល់អត្ថប្រយោជន៍ជាវត្ថុដែលនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានផ្តល់អោយកម្មករនិយោជិតជារៀងរាល់ខែសម្រាប់យកមកសម្រួលដល់ការបំពេញការងាររបស់ខ្លួនដូចជា ការផ្តល់ប្រេងសាំង កាតទូរស័ព្ទជាដើម។ ក្រុមហ៊ុនលក់ឡានមួយកន្លែងបានផ្តល់កាតទូរស័ព្ទក្នុងមួយខែចំនួន១៥(ដប់ប្រាំ)ដុល្លារអាមេរិក និងប្រេងសាំង២០(ម្ភៃ)លីត្រដល់បុគ្គលិកបម្រើការងារ។

[៧] អនុក្រឹត្យលេខ២៧៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការដំឡើងប្រាក់វិភាជន៍គ្រួសាររបស់មន្ត្រីរាជការស៊ីវិល ប្រាក់បំណាច់ឧបត្ថម្ភគ្រួសារ និងកូនយោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិកម្ពុជា មន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

## ផ្នែកទី៥៖ ប្រាក់ឈ្នួលអប្បបរមាត្រូវធានា

ប្រាក់ឈ្នួលអប្បបរមាត្រូវបានធានា សំដៅដល់ប្រាក់កម្រៃ ឬប្រាក់ឈ្នួលដែលកម្មករនិយោជិតនៃគ្រឹះស្ថាន រោងចក្រ សហគ្រាសទទួលបានពីនិយោជករបស់ខ្លួនជារៀងរាល់ខែក្នុងតម្លៃសមរម្យមួយតាមរយៈការពិភាក្សា ចរចារវាងស្ថាប័នត្រីភាគី ដើម្បីធានាដល់អ្នកប្រកបការងារ ឬកម្មករនិយោជិតទាំងអស់អោយរស់នៅបានសមរម្យ និងថ្លៃថ្នូរ។

### ៥.១ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិត

ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិត ជាប្រាក់ខែទាបបំផុតកំណត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលអាចអោយអ្នកធ្វើការរស់នៅបានដោយសេចក្តីថ្លៃថ្នូរ(សិទ្ធិមនុស្ស)។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៨ អត្រាប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតពេញសិទ្ធិដែលត្រូវបានធានាស្មើនឹង១៧០(មួយរយចិតសិប)ដុល្លារអាមេរិកក្នុងមួយខែ[៤២] បើធៀបនឹងអត្រាប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតពេញសិទ្ធិត្រូវបានធានា នាឆ្នាំ២០១៤ស្មើនឹង១០០(មួយរយ)ដុល្លារអាមេរិកក្នុងមួយខែ[៤៣]។ ចំណែកអត្រាប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតសាកល្បងទទួលបានចំនួន១៦៥(មួយរយហុកសិបប្រាំ)ដុល្លារអាមេរិកក្នុងមួយខែ[៤៤] បើធៀបនឹងអត្រាប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតសាកល្បងត្រូវបានធានា នាឆ្នាំ២០១៤ទទួលបានចំនួន៩៥(កៅសិបប្រាំ)ដុល្លារអាមេរិកក្នុងមួយខែ[៤៥]។ សន្ទុះនៃការកើនឡើងអត្រាប្រាក់ឈ្នួលអប្បបរមាត្រូវបានធានាជារៀងរាល់ឆ្នាំនេះ សបញ្ជាក់អោយឃើញថា រាជរដ្ឋាភិបាលកម្ពុជា និងភាគីដែលពាក់ព័ន្ធខិតខំធ្វើយ៉ាង

[៤២] ប្រកាសលេខ៣៩៦ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨។

[៤៣] សេចក្តីណែនាំលេខ០០១/១៤ ក.ប/ស.ណ.ន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តប្រកាសលេខ៣១៧ ក.ប/ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗ។

[៤៤] ប្រកាសលេខ៣៩៦ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨។

[៤៥] សេចក្តីណែនាំលេខ០០១/១៤ ក.ប/ស.ណ.ន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តប្រកាសលេខ៣១៧ ក.ប/ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗ។

ណាអោយកម្មករនិយោជិត និងនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសទទួលបានផលប្រយោជន៍ដូចគ្នា រួមទាំងជម្រុញដល់ការអភិវឌ្ឍប្រទេសជាតិដែរ។

ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតនេះ ត្រូវបានចែងចែកតាមឋានានុក្រមដែលច្បាប់តម្រូវ។ ប្រាក់ឈ្នួលតាមឋានានុក្រម មានន័យថាប្រាក់ឈ្នួល ឬប្រាក់កម្រៃដែលកម្មករនិយោជិតទទួលបានពីនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសនានាតាមឋានានុក្រម ឬឋានៈ មុខងារដែលខ្លួនកំពុងបំពេញការងារជាប្រចាំ ពេលនិយោជកផ្តល់ប្រាក់ឈ្នួលអោយកម្មករនិយោជិតតាមមុខតំណែង តួនាទី ស្ថានភាពការងារដែលកម្មករនិយោជិតកំពុងតែអនុវត្ត។ ប្រាក់ឈ្នួលតាមឋានានុក្រមនេះត្រូវបានធ្វើការបែងចែកចំពោះការងារសាកល្បង កូនជាង និងកម្មករពេញសិទ្ធិ។

**ក. ការងារសាកល្បង**

ជាទូទៅក្នុងវិស័យការងារទាំងអស់គឺតម្រូវអោយបុគ្គលិក ឬនិយោជិតធ្វើការងារសាកល្បងជាមុនសិន ដើម្បីត្រួតពិនិត្យមើលគ្នាទៅវិញទៅមក និងសាកល្បងសមត្ថភាពថាតើខ្លួនអាចធ្វើការងារនេះបាន ឬមិនបានមុននឹងក្លាយជាបុគ្គលិក ឬកម្មករនិយោជិតពេញម៉ោង។ ក៏ដូចគ្នានឹងវិស័យការងារផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងដែរ ការងារសាកល្បង គឺសំដៅដល់ការងារដែលកម្មករនិយោជិតត្រូវធ្វើសាកល្បងក្នុងរយៈពេលកំណត់មួយច្បាស់លាស់ មុននឹងក្លាយជាកម្មករពេញសិទ្ធិនៅក្នុងគ្រឹះស្ថាន រោងចក្រ សហគ្រាស។ម្យ៉ាងទៀតការងារសាកល្បងនេះក៏ត្រូវបានបង្កើតឡើងតាមរយៈកិច្ចសន្យាការងាររវាងនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស និងកម្មករនិយោជិតដែរ ពោលគឺកម្មករនិយោជិតទាំងអស់ តម្រូវអោយធ្វើការងារសាកល្បងដោយធ្វើការងារនោះយ៉ាងប្រុងប្រយ័ត្ន ទៀងទាត់ ស្មោះត្រង់ ប្រកបដោយក្រមសីលធម៌ គោរពតាមលក្ខខណ្ឌការងារ និងត្រូវបញ្ចេញឲ្យអស់ពីសមត្ថភាពតាមវិជ្ជាជីវៈដែលខ្លួនមានជាដើម ដោយស្ថិតនៅក្រោមការឃ្លាំមើល ពិនិត្យពិច័យទាំងបញ្ញា អាកប្បកិរិយា ជាពិសេសសមត្ថភាពវិជ្ជាជីវៈក្នុងការធ្វើការងារ ពីសំណាក់និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស ហើយចំពោះថិរវេលាការងារសាកល្បងនេះ គឺមិនលើសពី៣(បី)ខែសម្រាប់និយោជិត ២(ពីរ)ខែសម្រាប់កម្មករជំនាញ និង ១(មួយ)ខែសម្រាប់កម្មករធម្មតា[៣]។ ការងារសាកល្បងធ្វើបានតែម្តងគត់ក្នុងមួយប្រភេទការងារ។ ចំណែកការកំណត់អត្រាប្រាក់ឈ្នួលការងារសាកល្បង គឺអាស្រ័យលើការកំណត់របស់ក្រសួងមានសមត្ថកិច្ចទទួលបន្ទុកវិស័យការងារ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានធ្វើការកំណត់

[៣] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៦៨ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

អត្រាប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតសាកល្បងពី១(មួយ)ខែ ទៅ៣(បី)ខែចំនួន ១៦៥(មួយរយហុកសិបប្រាំ)ដុល្លារអាមេរិកក្នុងមួយខែ[៤៧]។ ជាក់ស្តែង **ក្រុមហ៊ុន ធី និង ខេ ហ្គាមេនអ៊ីន ដាស្រ្ទី ២ (T & K GARMENT INDUSTRY 2)** បានផ្តល់ប្រាក់ឈ្នួលដល់កម្មការីសាកល្បងឈ្មោះ **ច្រឹក នាង** ក្នុងមួយខែចំនួន១៦៥(មួយរយហុកសិបប្រាំ)ដុល្លារអាមេរិក **(ឧបសម្ព័ន្ធទី១)**។

**ខ. កូនជាង**

កូនជាង សំដៅដល់ក្មេងមានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ ដែលបានព្រមព្រៀងចុះកិច្ចសន្យាជាមួយនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស ក្នុងការទទួលការសិក្សាពីមុខជំនាញដែលខ្លួនត្រូវយកមកប្រើប្រាស់ក្នុងវិស័យការងារ របស់រោងចក្រសហគ្រាសនោះក្នុងចិរវេលាណាមួយច្បាស់លាស់(មិនអោយលើសពីពីរឆ្នាំ) និងតាមលក្ខខណ្ឌការងារ ហើយនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសមានតួនាទីបង្រៀនកូនជាង ឬបញ្ជូនកូនជាងឲ្យទៅសិក្សាមុខជំនាញបច្ចេកទេស រួមទាំងបង់ថ្លៃសិក្សាអោយកូនជាង និងត្រូវទទួលយកកូនជាងនោះមកធ្វើការងារនៅក្នុងរោងចក្ររបស់ខ្លួនវិញបន្ទាប់ពីកូនជាងបានបញ្ចប់វគ្គបណ្តុះបណ្តាលពីគ្រូបង្រៀនវិជ្ជាជីវៈដោយជោគជ័យ[៤៨]។ គ្រូបង្រៀនសន្យាថានឹងធ្វើការបង្ហាត់ បង្វឹក បង្រៀន ឬផ្ទេរចំណេះដឹងដល់កូនជាងនោះនូវវិជ្ជាជីវៈដែលខ្លួនមាន ដើម្បីត្រូវឲ្យកូនជាងយកមកអនុវត្តនៅក្នុងវិស័យការងារ ឬតាមគ្រឹះស្ថាន រោងចក្រ សហគ្រាស។ ចំណែកឯកូនជាងក៏ត្រូវសន្យាជាមួយនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស និងគ្រូបង្រៀនថា នឹងខិតខំប្រឹងប្រែងរៀនសូត្រតាមសមត្ថភាព កម្លាំងរបស់ខ្លួន ស្តាប់បង្គាប់ គោរពគ្រូ ប្រកបដោយក្រមសីលធម៌ និងយកចំណេះជំនាញដែលបានទទួលការបណ្តុះបណ្តាលមកធ្វើការងារជូននិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសនោះវិញ រួមទាំងត្រូវរក្សាអាថិកំបាំងផ្សេងៗក្នុងវិជ្ជាជីវៈ។ ចំពោះការកំណត់អត្រាប្រាក់ឈ្នួលរបស់កូនជាងវិញ គឺអាស្រ័យលើការចរចា និងការព្រមព្រៀងគ្នារវាងនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស និងកម្មករនិយោជិតដែលមានចែងនៅក្នុងកិច្ចសន្យាហ្វឹកហ្វឺនកូនជាង មានន័យថានិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសត្រូវផ្តល់ប្រាក់កម្រៃដល់កូនជាងដែលខ្លួនបានបញ្ជូនទៅសិក្សាវិជ្ជាជីវៈ ឬកូនជាងដែលខ្លួនបានបង្រៀនផ្ទាល់តាមការព្រមព្រៀងរវាងភាគីទាំងសងខាង[៤៩]។ ជាក់

[៤៧] ប្រកាសលេខ៣៩៦ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៨។

[៤៨] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៨ មាត្រា៥១ និងមាត្រា៥៦ កថាខណ្ឌទី១។

[៤៩] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា៥៣ កថាខណ្ឌទី២ ចំណុចទី៥។

ស្តែងកន្លែងធ្វើគ្រឿងអលង្កាមួយកន្លែងបានផ្តល់ប្រាក់ឈ្នួលដល់កូនជាងទើបនឹងចូលបម្រើការងារចំនួន១៦០(មួយរយហុកសិប)ដុល្លារអាមេរិកក្នុងមួយខែ រួមទាំងកន្លែងស្នាក់នៅ និងអាហារបីពេល។

**គ. កម្មករពេញសិទ្ធិ**

បន្ទាប់ពីកម្មករនិយោជិតបានបញ្ចប់ការងារសាកល្បងរបស់ខ្លួន ដោយជោគជ័យតាមការព្រមព្រៀង ឬតាមលក្ខខណ្ឌការងារ និងតាមថិរវេលាដែលបានកំណត់ នោះពួកគេនឹងក្លាយជាកម្មករពេញសិទ្ធិ មានន័យថា កម្មករពេញសិទ្ធិ គឺជាកម្មករទាំងឡាយណាដែលបានបញ្ចប់ការងារសាកល្បងតាមការកំណត់របស់ច្បាប់ ឬតាមរយៈកិច្ចសន្យាការងារសាកល្បងរវាងនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស និងកម្មករនិយោជិត។ មួយវិញទៀត នៅពេលបញ្ចប់ការងារសាកល្បងនេះ កម្មករនិយោជិត(កម្មករពេញសិទ្ធិ)មានសិទ្ធិទទួលបានប្រាក់កម្រៃតាមអត្រាការកំណត់របស់ ក្រសួងមានសមត្ថកិច្ចទទួលបន្ទុកវិស័យការងារ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានធ្វើការកំណត់អត្រាប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករពេញសិទ្ធិ ចំនួន១៧០(មួយរយចិតសិប)ដុល្លារអាមេរិកក្នុងមួយខែ[៥០]។ ។ ជាក់ស្តែង **ក្រុមហ៊ុន ធី និង ខេ ហ្គាមេនអ៊ីនដាស្ទ្រី ២ (T & K GARMENT INDUSTRY 2)** បានផ្តល់ប្រាក់ឈ្នួលដល់កម្មការីពេញសិទ្ធិឈ្មោះ **រឿន សុធារ៉ា**ក្នុងមួយខែចំនួន១៧៧(មួយរយចិតសិបប្រាំពីរ)ដុល្លារអាមេរិក **(ឧបសម្ព័ន្ធទី១)**។

## ៥.២ ប្រាក់ឈ្នួលការងារម៉ៅការ ឬតាមបរិមាណផលិតផល

នៅក្នុងច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ត្រង់មាត្រា១០៨បានចែងថា ចំពោះការងារម៉ៅការ ឬតាមបរិមាណផលិតផល ទោះបីធ្វើនៅរោងជាង ឬនៅលំនៅក៏ដោយ និយោជក ឬម្ចាស់គ្រឹះស្ថានរោងចក្រ សហគ្រាសត្រូវបើកប្រាក់ឈ្នួលតាមការងារម៉ៅការ ឬតាមបរិមាណផលិតផលដែលខ្លួនបានដាក់អោយកម្មករនិយោជិតនោះ មានន័យថាកម្មករនិយោជិតដែលបំពេញការងារម៉ៅការ ឬតាមបរិមាណផលិតផលដែលមានការប៉ិនប្រសប់មធ្យមធ្វើការជាធម្មតា មានសិទ្ធិទទួលបានប្រាក់ឈ្នួលក្នុងថិរវេលាធ្វើការដដែល អត្រាប្រាក់ឈ្នួលយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានធានា។ ជាមួយគ្នានេះដែរ ប្រកាសលេខ៣៩៦ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៨ក៏បានកំណត់ថា ចំពោះកម្មករនិយោជិតដែលទទួលបានប្រាក់ឈ្នួលតាមបរិមាណផលិតផល(ដេរស៊ីប៉ុង) ត្រូវទទួលបានប្រាក់ឈ្នួលទៅតាមចំនួនដែលគេអាចធ្វើទៅ

[៥០] ប្រកាសលេខ៣៩៦ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៨។

បាន បើប្រាក់ដែលទទួលបានខ្ពស់ជាងប្រាក់ឈ្នួលគោល។ ប៉ុន្តែផ្ទុយមកវិញក្នុងករណីដែលកម្មករនិយោជិតទទួលបានប្រាក់ទាបជាងចំនួនប្រាក់ឈ្នួលគោល ភាគីនិយោជកត្រូវបន្ថែមប្រាក់ឈ្នួលអោយគ្រប់ចំនួន១៦៥(មួយរយហុកសិបប្រាំ)ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់កម្មករនិយោជិតធ្វើការងារសាកល្បង និងចំនួន១៧០(មួយរយចិតសិប)ដុល្លារអាមេរិកក្នុងមួយខែសម្រាប់កម្មករនិយោជិតពេញសិទ្ធិ ហើយប្រាក់អត្ថប្រយោជន៍ផ្សេងៗទៀតដែលកម្មករនិយោជិតធ្លាប់ទទួលបាននៅរក្សាទុកដដែល។ ជាក់ស្តែង កម្មករនិយោជិតធ្វើការគិតតាមបរិមាណផលិតផល ឬដេរស៊ីបុងនៃ **ក្រុមហ៊ុន ធី និង ខេ ហ្គាមេនអ៊ីនដាស្ទ្រី ២ (T & K GARMENT INDUSTRY 2)** ទទួលបានប្រាក់ឈ្នួលចំនួន ២២៣.០១៥(ពីររយម្ភៃបីក្បៀសមួយសេន)ដុល្លារអាមេរិកក្នុងមួយខែ **(ឧបសម្ព័ន្ធទី១)**។

## ជំពូក២ ៖ ការអនុវត្តប្រាក់ឈ្នួល

នៅក្នុងប្រទេសកម្ពុជាការអនុវត្តប្រាក់ឈ្នួល ត្រូវបានធ្វើឡើងនៅតាមបណ្តាលគ្រឹះស្ថាន រោងចក្រ សហគ្រាសនានា ដោយតម្រូវអោយនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស គោរពតាម ឬអនុវត្តតាមប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារ(ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) ដោយឆ្លងកាត់តាមការកំណត់ ការប្រជុំពិគ្រោះពិភាក្សា និងវិនិច្ឆ័យពីសំណាក់ត្រីភាគីជារៀងរាល់ឆ្នាំ ដើម្បីធានាដល់ការរស់នៅរបស់កម្មករនិយោជិតទាំងអស់ប្រកបដោយសេចក្តីថ្លៃថ្នូរ។ ការអនុវត្តប្រាក់ឈ្នួលនេះទៀត គឺកើតចេញពីការចរចាថាតើភាគីនិយោជក មានលទ្ធភាពផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតរបស់ខ្លួនក្នុងមួយខែចំនួនប៉ុន្មានដុល្លារអាមេរិក? ចំណែកភាគីកម្មករនិយោជិតមានសិទ្ធិទាមទារចំពោះប្រាក់ឈ្នួលក្នុងមួយខែប៉ុន្មានដុល្លារ? ដើម្បីអោយកម្មករនិយោជិតទាំងអស់អាចរស់នៅបានសមរម្យ។ ចំពោះការអនុវត្តប្រាក់ឈ្នួលនេះ ត្រូវបានធ្វើការបែងចែកជាច្រើនចំណុចដូចជា ការកំណត់ប្រាក់ឈ្នួល ការបើកប្រាក់ឈ្នួល និងសិទ្ធិ និងការធានាប្រាក់ឈ្នួល។

### ផ្នែកទី១ ៖ ការកំណត់ប្រាក់ឈ្នួល

ជារៀងរាល់ឆ្នាំប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតនៅក្នុងប្រទេសកម្ពុជា ត្រូវបានកំណត់តាមរយៈការដឹកនាំពិភាក្សា និងស្នើអត្រាប្រាក់ឈ្នួលដោយគណៈកម្មការក្រុមប្រឹក្សាការងារដែលមានសមាសភាពមកពីស្ថាប័នត្រីភាគីគឺ ភាគីរាជរដ្ឋាភិបាលចំនួន១៤រូប ភាគីតំណាងនិយោជកចំនួន០៧រូប និងភាគីតំណាងកម្មករនិយោជិតចំនួន០៧រូប។ ក្នុងករណីចាំបាច់គណៈកម្មការប្រឹក្សាការងារអាចបង្កើតក្រុមការងារបច្ចេកទេសត្រីភាគីមានដូចជា ក្រុមការងារបច្ចេកទេសតំណាងភាគីរាជរដ្ឋាភិបាលចំនួន១៦រូប ក្រុមការងារបច្ចេកទេសភាគីតំណាងនិយោជកចំនួន១៦រូប និងក្រុមការងារបច្ចេកទេសភាគីតំណាងកម្មករនិយោជិតចំនួន១៦រូប ដើម្បីពិភាក្សាលំអិតពីទិន្នន័យលក្ខណវិនិច្ឆ័យ និងអត្រាកំណើនប្រាក់ឈ្នួលអប្បបរមារួចបញ្ជូនទៅគណៈកម្មការប្រឹក្សាការងារដើម្បីប្រជុំពិភាក្សាបន្ត។ ចំពោះយន្តការក្នុងការកំណត់ប្រាក់ឈ្នួលមាន គោលការណ៍ទាំង៥ លក្ខណវិនិច្ឆ័យទាំង៧ និងកាលវិភាគសម្រាប់ការចរចាក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា[៥១]។

[៥១]ការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាឆ្នាំ២០១៦ ដោយលេខាធិការដ្ឋានគណៈកម្មការប្រឹក្សាការងារ សហការរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអន្តរជាតិខាងការងារ(ILO)។

- គោលការណ៍ទាំង៥ ក្នុងការកំណត់ប្រាក់ឈ្នួលមាន៖

១. ភាពញឹកញាប់ ៖ការពិភាក្សាកែសម្រួលត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ។

២. ភាពអាចព្យាករណ៍បាន ៖ ត្រូវកើនតាមលំដាប់បន្តបន្ទាប់។

៣. យន្តការនៃការចរចា ៖ គោលការណ៍ឈ្នះ-ឈ្នះ ក្នុងការដោះស្រាយបញ្ហា។

៤. គោលការណ៍សម្រេចចិត្ត ៖យកជម្រើសឯកច្ឆន្ទ(កុងសង់ស៊ីស)នៃសមាជិកដែលមានវត្តមានក្នុងកិច្ចប្រជុំ។ ក្នុងករណីមិនមានការឯកភាពជាឯកច្ឆន្ទលើចំណុចណាមួយ ចំនួន០២(ពីរ)ដងក្នុងកិច្ចប្រជុំ០២(ពីរ)ផ្សេងគ្នាត្រូវសម្រេចដោយសម្លេងភាគច្រើនតាមរយៈការបោះឆ្នោតជាសម្ងាត់ក្នុង កិច្ចប្រជុំលើកទី០២(ពីរ)។

៥.ការប្រើប្រាស់ទិន្នន័យនិងលក្ខណវិនិច្ឆ័យ៖យកទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ និងយកលក្ខណវិនិច្ឆ័យបែបសេដ្ឋកិច្ច និងសង្គមមកធ្វើជាមូលដ្ឋានក្នុងការពិភាក្សា។

- លក្ខណវិនិច្ឆ័យទាំង៧ ក្នុងការកំណត់ប្រាក់ឈ្នួលរួមមាន៖

១. ស្ថានភាពគ្រួសារ ៖ ផ្អែកលើការអង្កេតកម្លាំងពលកម្ម(កម្មករនិយោជិត) និងសមាជិកក្រុមគ្រួសាររបស់កម្មករនិយោជិត។

២. អត្រាអតិផរណា ៖ អត្រាប្រែប្រួលនៃសន្ទស្សន៍ថ្លៃទំនិញ និងចំនីអាហារ។

៣. ការចំណាយក្នុងការរស់នៅ៖ បន្ទាត់ភាពក្រីក្រជាមូលដ្ឋានគោលក្នុងការកំណត់ចំណាយអប្បបរមាក្នុងការរស់នៅប្រចាំថ្ងៃ។

៤. ផលិតភាព ៖ ផលធៀបរវាងតម្លៃបន្ថែម(ប្រាក់ចំណេញ) និងកម្លាំងពលកម្ម។

៥. ភាពប្រកួតប្រជែង ៖ ការវាស់វែងកត្តាសំខាន់ៗជាមួយប្រទេសដៃគូប្រកួតប្រជែងដូចជាការកម្រិតប្រាក់ឈ្នួល អត្រាប្តូរប្រាក់ ចំនួនម៉ោងធ្វើការងារ អត្រាភាគទានរបបបេឡាជាតិសន្តិសុខសង្គម សម្រាប់កម្មករនិយោជិត សន្ទុះនៃការនាំចេញ ប្រព័ន្ធឡូជីស្ទីក កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងបរិយាកាសវិនិយោគ។ល។

៦. ស្ថានភាពទីផ្សារការងារ ៖ ផលប៉ះពាល់នៃកំណើនប្រាក់ឈ្នួលអប្បបរមា លើល្បឿននៃការបង្កើតការងារថ្មី។

៧.កម្រិតចំណេញ ៖ តម្លៃនាំចេញទូទាត់ជាមួយធាតុចូលអន្តរការី និងការចំណាយលើកម្លាំងពលកម្ម។

- កាលបរិច្ឆេទសម្រាប់ការចរចាក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា

១. នៅខែកក្កដា រៀងរាល់ឆ្នាំ ចាប់ផ្តើមប្រជុំផ្ទៃក្នុងនៃភាគីនីមួយៗ។

២. នៅខែសីហា រៀងរាល់ឆ្នាំ ចាប់ផ្តើមប្រជុំពិភាក្សាទ្វេភាគី។

៣. នៅខែកញ្ញា រៀងរាល់ឆ្នាំ ចាប់ផ្តើមប្រជុំពិភាក្សាត្រីភាគី។

៤. នៅខែតុលា រៀងរាល់ឆ្នាំ ជាការប្រជុំសម្រេចតួលេខ ឬអត្រាកំណើនប្រាក់ឈ្នួលរបស់កម្មករនិយោជិត។ ប្រាក់ឈ្នួលអប្បបរមាថ្មី នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា នៃឆ្នាំបន្ទាប់។

យោងតាមច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ត្រង់មាត្រា១០៧ កថាខណ្ឌទី៣ ដែលស្របតាមមាត្រា៣ នៃអនុសញ្ញាលេខ១៣១ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមារបស់អង្គការអន្តរជាតិខាងការងារ(ILO)ឆ្នាំ១៩៧០ កំណត់ធាតុផ្សំដែលត្រូវយកមកគណនាប្រាក់ឈ្នួលមានកត្តាធំពីរគឺកត្តាសេដ្ឋកិច្ច និងកត្តាសង្គម។

### ១.១ កត្តាសេដ្ឋកិច្ច

ការកំណត់ប្រាក់ឈ្នួលដោយផ្អែកលើកត្តាសេដ្ឋកិច្ច សំដៅលើការកំណត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតថា នឹងមានការប្រែប្រួលជារៀងរាល់ឆ្នាំយោងតាមកំណើនសេដ្ឋកិច្ចប្រទេសជាតិនីមួយៗ។ ជាក់ស្តែងប្រមាណឆ្នាំចុងក្រោយនេះយើងសង្កេតឃើញថាសន្ទុះសេដ្ឋកិច្ចប្រទេសកម្ពុជាមានការកើនឡើងជាលំដាប់គ្រប់វិស័យ។ បើក្រឡេកមើលវិស័យកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើងវិញ ក្នុងអំឡុងពេលប្រមាណ៩ឆ្នាំចុងក្រោយនេះអត្រាប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង បានកើនឡើងចំនួន៧០(ចិតសិប)ដុល្លារអាមេរិកក្នុងមួយខែ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗទៀតដែលធ្លាប់ទទួលបាននៅរក្សាទុកដដែល។ ជាមួយគ្នានេះ ការកំណត់ប្រាក់ឈ្នួលដោយផ្អែកលើកត្តាសេដ្ឋកិច្ច ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវគិតគូ លើផលិតភាព ភាពប្រកួតប្រជែង និងទីផ្សារការងារដែរ ដែលកត្តាទាំងនេះ ក្រសួងត្រូវពិចារណាលើតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច និងផលប្រយោជន៍រវាងកម្មករនិយោជិត និងនិយោជកសមាមាត្រគ្នា។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក៏ត្រូវស្វែងរកចំណុចរួមមួយ ដែលត្រូវធានាពីកម្រិតជីវភាពរបស់កម្មករនិយោជិតតាមតែអាចធ្វើទៅបាន រួមទាំងធ្វើយ៉ាងណាត្រូវផ្តល់លទ្ធភាពឲ្យនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសទទួលបានផលចំណេញខាងសេដ្ឋកិច្ច។ មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងទទួលបន្ទុកវិស័យការងារ

ត្រូវរកវិធីសាស្ត្រយ៉ាងណាទាក់ទាញក្រុមហ៊ុនវិនិយោគ(វិនិយោគិន)ឲ្យបានច្រើន ដើម្បីដាក់ទុនវិនិយោគ និងជួយផ្តល់ការងារបន្ថែមសម្រាប់ប្រជាជន ឬកម្មករនិយោជិតនៅក្នុងប្រទេសកម្ពុជា។

### ១.២ កត្តាសង្គម

ការកំណត់ប្រាក់ឈ្នួលដោយផ្អែកលើកត្តាសង្គម គឺជាការកំណត់ប្រាក់ឈ្នួលឲ្យសមស្របតាមលក្ខខណ្ឌជីវភាពរស់នៅ របស់កម្មករនិយោជិតសម្រាប់តម្រូវការជាក់ស្តែងប្រចាំថ្ងៃ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវគិតគូ លើលក្ខណវិនិច្ឆ័យបែបសង្គម (ស្ថានភាពរស់នៅ អត្រាអតិផរណា និងការចំណាយក្នុងការរស់នៅ)ដូចជា ការចាយវាយប្រចាំថ្ងៃរបស់កម្មករនិយោជិតតម្រូវការសម្លៀកបំពាក់ ការបរិភោគចំនីអាហារ ការទិញថ្នាំសង្កូវសម្រាប់ព្យាបាលជម្ងឺ ការចំណាយលើការជួលផ្ទះស្នាក់នៅ និងផលប្រយោជន៍ជាច្រើនទៀត។ ជារួមការកំណត់ប្រាក់ឈ្នួលដោយផ្អែកលើកត្តាសង្គម គឺត្រូវធ្វើយ៉ាងណាធានាអោយបានថាកម្មករនិយោជិតគ្រប់រូបមានជីវភាពរស់នៅសមរម្យ ប្រកបដោយសេចក្តីថ្លៃថ្នូរ និងសមស្របតាមការរស់នៅដូចមនុស្សទូទៅក្នុងសង្គមកម្ពុជាដែរ។

### ១.៣ សមភាពប្រាក់ឈ្នួល

សមភាពប្រាក់ឈ្នួល សំដៅលើការទទួលបានប្រាក់ឈ្នួល ឬប្រាក់កម្រៃការងារស្មើៗគ្នាចំពោះលក្ខខណ្ឌការងារស្មើគ្នា ភាពប៉ិនប្រសប់ខាងវិជ្ជាជីវៈ អ្នកមានមុខតំណែងដូចគ្នាមិនថាបុរសឬស្ត្រីឡើយ មានន័យថាកម្មករនិយោជិតទាំងបុរស និងស្ត្រីដែលបានបម្រើការងារនៅក្នុងគ្រឹះស្ថានរោងចក្រ សហគ្រាសមានតួនាទីដូចគ្នា មានសិទ្ធិទទួលបានប្រាក់បំណាច់ស្មើៗគ្នាដោយមិនរើសអើងពីភេទឡើយ។ ក្នុងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៦ កថាខណ្ឌទី២ ក៏បានកំណត់ថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិទទួលបានប្រាក់បំណាច់ស្មើៗគ្នា។ ចំពោះគោលការណ៍នេះ គឺមិនចង់អោយមានការរើសអើងស្ត្រីភេទ ការប្រឆាំងនឹងច្បាប់ ដោយនិយោជកផ្តល់ប្រាក់បំណាច់ដល់កម្មករនិយោជិតជាស្ត្រីតិចជាងបុរស ឬបុរសទទួលបានប្រាក់បំណាច់តិចជាងស្ត្រីនោះទេ។ លើកលែងតែកម្មករនិយោជិតណាម្នាក់មានអតីតភាពការងារយូរជាង និងមានគុណសម្បត្តិផ្តល់ផលចំណេញដល់គ្រឹះស្ថាន រោងចក្រ សហគ្រាសនឹងត្រូវដំឡើងប្រាក់កម្រៃតាមនោះ។

## ផ្នែកទី២ ៖ ការបើកប្រាក់ឈ្នួល

នៅតាមបណ្តាគ្រឹះស្ថាន រោងចក្រ សហគ្រាសទាំងអស់ ការបើកប្រាក់ឈ្នួលដល់កម្មករនិយោជិត គឺជាកាតព្វកិច្ចរបស់និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសដោយត្រូវគោរព

តាមវិធាននៃការបើកប្រាក់ឈ្នួល។ និយោជកត្រូវជូនដំណឹងដល់កម្មករនិយោជិតអោយបានច្បាស់អំពីលក្ខខណ្ឌនៃប្រាក់ឈ្នួលដែលត្រូវអនុវត្តចំពោះកម្មករនិយោជិត មុននឹងចូលកាន់មុខតំណែងធ្វើការ ឬពេលផ្លាស់ប្តូរលក្ខខណ្ឌការងារផ្សេង និងរយៈពេលនៃការបើកប្រាក់ឈ្នួលការងារ។ ប្រាក់ឈ្នួលដែលកម្រិតឡើងដោយច្បាប់ត្រូវបិទជាអចន្ត្រៃយ៍នៅក្នុងបន្ទប់ធ្វើការ ឬការិយាល័យបើកប្រាក់ឈ្នួល និងនៅទីទទួលអោយធ្វើការ[៥២]។ ការបើកប្រាក់ឈ្នួលត្រូវបានកំណត់អំពីលក្ខខណ្ឌនៃការបើកប្រាក់ឈ្នួល ទីកន្លែងបើកប្រាក់ឈ្នួល និងពេលវេលានៃការបើកប្រាក់ឈ្នួល។

### ២.១ លក្ខខណ្ឌនៃការបើកប្រាក់ឈ្នួល

លក្ខខណ្ឌនៃការបើកប្រាក់ឈ្នួល បានកំណត់អោយនិយោជកបើកប្រាក់ឈ្នួលដោយផ្ទាល់ដៃដល់កម្មករនិយោជិត ឬតាមវិធីផ្សេងៗទៀត បើមានការយល់ព្រមពីកម្មករនិយោជិតដើម្បីធានាសុវត្ថិភាព និងផ្តល់ភាពងាយស្រួលដល់ភាគីទាំងសងខាង។ ប្រាក់ឈ្នួលត្រូវបើកជាលោហៈធាតុ ឬក្រដាសប្រាក់ដែលប្រើប្រាស់ស្របច្បាប់បានកំណត់មានតម្លៃជារូបិយប័ណ្ណ ឬជារូបិយវត្ថុ។ ហាមដាច់ខាតចំពោះការបើកប្រាក់ឈ្នួលជាគ្រឿងស្រវឹង ឬថ្នាំសង្កូវដែលនាំអោយប៉ះពាល់ ឬខូចសុខភាព សុខុមាលភាពកម្មករនិយោជិត។ ជាមួយគ្នានេះ បើដល់ថ្ងៃនៃការបើកប្រាក់ឈ្នួលត្រូវនឹងថ្ងៃដែលនិយោជិតឈប់សម្រាក និយោជកត្រូវធ្វើការបើកប្រាក់ឈ្នួលដល់កម្មករនិយោជិតមុនមួយថ្ងៃ[៥៣]។

### ២.២ ទីកន្លែងបើកប្រាក់ឈ្នួល

ការបើកប្រាក់ឈ្នួលត្រូវធ្វើឡើងនៅកន្លែងធ្វើការ ឬនៅការិយាល័យនិយោជកកាលណាការិយាល័យនោះនៅជិតផ្ទាល់ លើកលែងតែករណីមានប្រធានស័ក្តិ។ ហាមដាច់ខាតចំពោះការបើកប្រាក់ឈ្នួលនៅក្នុងតៀមលក់គ្រឿងស្រវឹង ភណ្ឌាគារលក់រាយ ឬទីកន្លែងកំសាន្តនានា លើកលែងតែកម្មករនិយោជិតនោះកំពុងបម្រើការងារនៅទីកន្លែងនោះផ្ទាល់តែម្តង[៥៤]។

### ២.៣ ពេលវេលាបើកប្រាក់ឈ្នួល

យោងតាមច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១១៦បានកំណត់ថា ពេលវេលានៃការបើកប្រាក់ឈ្នួលត្រូវធ្វើតាមកាលបរិច្ឆេទដូចជា៖

[៥២] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១០៩។

[៥៣] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១១៥ កថាខណ្ឌទី២ វាក្យខណ្ឌទី១ និងកថាខណ្ឌទី៣។

[៥៤] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១១៥ កថាខណ្ឌទី១ និងកថាខណ្ឌទី២ វាក្យខណ្ឌទី២។

- ចំពោះកម្មករ ប្រាក់ឈ្នួលត្រូវបើកយ៉ាងហោចណាស់ចំនួន២(ពីរ)ដងក្នុងមួយខែ។
- ចំពោះនិយោជិត ប្រាក់ឈ្នួលត្រូវបើកយ៉ាងហោចណាស់ចំនួន១(មួយ)ដងក្នុងមួយខែ។
- ចំពោះអ្នកដើរទាក់ទង និងអ្នកតំណាងពាណិជ្ជកម្ម ប្រាក់កម្រៃជើងសាត្រូវបើកយ៉ាងហោចណាស់៣(បី)ខែម្តង។
- ចំពោះការងារម៉ៅការ ឬតាមបរិមាណផលិតផល ដែលត្រូវការពេលវេលាបំពេញការងារលើសពី១៥(ដប់ប្រាំថ្ងៃ) កម្មករត្រូវទទួលបានប្រាក់រំលស់១០(ដប់)ថ្ងៃម្តង និងបន្ទាប់ពីបញ្ចប់ការងារ ត្រូវទទួលបានប្រាក់គ្រប់ចំនួនក្នុងរយៈពេលមួយសប្តាហ៍។
- ក្នុងករណីរំលាយកិច្ចសន្យាការងារ ប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗទៀតដែលកម្មករនិយោជិតត្រូវទទួលបានក្នុងរយៈពេល៤៨(សែសិបប្រាំបី)ម៉ោងបន្ទាប់ពីការបណ្តេញចេញពីការងារ។

## ផ្នែកទី៣៖ សិទ្ធិ និងការធានាប្រាក់ឈ្នួល

សិទ្ធិ និងការធានាប្រាក់ឈ្នួល សំដៅដល់ការការពារសិទ្ធិសេរីភាពដូចមានចែងក្នុងច្បាប់ និងការធានាការពារកម្មករនិយោជិត ឲ្យរួចផុតពីការរំលោភបំពាននានាដែលប្រុងនឹងកើតមានឡើង ឬដែលកើតមានឡើងលើខ្លួនទាក់ទងនឹងប្រាក់ឈ្នួលដូចជា ការកាត់ប្រាក់ឈ្នួល និងការទូទាត់ប្រាក់ឈ្នួល ការកាត់ប្រាក់ឈ្នួល និងភាគទានសហជីព ការរឹបអូស និងការផ្ទេរប្រាក់ឈ្នួល ឯកសិទ្ធិនៃប្រាក់ឈ្នួលដែលនៅជំពាក់ និងសិទ្ធិទាមទារបើកប្រាក់ឈ្នួល។ នៅក្នុងនោះដែរការធានាការបើកប្រាក់ឈ្នួល គឺជាការធានាសុវត្ថិភាពកម្មករនិយោជិតបន្ទាប់ពីបានទទួលប្រាក់ឈ្នួលពីនិយោជកដោយជៀសវាងការជ្រុះបាត់ ឬការបាត់បង់ណាមួយកើតមានឡើង ហើយនិយោជកក៏មិនមានសិទ្ធិក្នុងការហាមឃាត់កម្មករនិយោជិត ចំពោះការចំណាយប្រាក់ឈ្នួលតាមចិត្តរបស់ខ្លួនបានដែរ។

### ៣.១ ការកាត់ប្រាក់ឈ្នួល និងការទូទាត់ប្រាក់ឈ្នួល

ការកាត់ប្រាក់ឈ្នួលក្នុងគោលបំណងឲ្យអ្នកទទួលរកការងារធ្វើ ទោះបីចំពោះ ឬមិនចំពោះក្តី ឲ្យទៅនិយោជក ឬអ្នកតំណាងនិយោជក ឬអន្តរការីណាម្នាក់ ក៏ដូចជាភ្នាក់ងារទទួលជ្រើសរើសហត្ថពលករ ត្រូវបានច្បាប់ហាមឃាត់[៥៥]។ ក្នុងនោះដែរការទូទាត់ប្រាក់ឈ្នួលណាមួយមិនអនុញ្ញាតឲ្យធ្វើបានទេ ដើម្បីជាប្រយោជន៍ដល់និយោជករវាងប្រាក់ឈ្នួលដែលត្រូវបើកអោយកម្មករនិយោជិត និងប្រាក់ដែលកម្មករនិយោជិតត្រូវសងឲ្យនិយោជកវិញ ចំពោះការផ្តល់សម្ភារៈផ្សេងៗទោះជា

[៥៥] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១២៦។

ប្រភេទណាក៏ដោយ។ រាល់អនុសញ្ញារួម ដែលអនុញ្ញាតអោយដកហូតប្រាក់ឈ្នួលត្រូវចាត់ទុកជាមោឃៈ។ ការទូទាត់ប្រាក់ឈ្នួល និងប្រាក់ជំពាក់ដោយកម្មករនិយោជិតអាចធ្វើបានក្នុង៤ករណីគឺ[៥៦]៖

- គ្រឿងប្រដាប់ប្រដា និងឧបករណ៍ចាំបាច់សម្រាប់ការងារដែលកម្មករនិយោជិតមិនបានយកមកប្រគល់អោយវិញនៅពេលឈប់ធ្វើការ។
- វត្ថុធាតុ និងសម្ភារៈដែលកម្មករនិយោជិតទទួលបន្ទុក និងប្រើប្រាស់។
- ចំនួនប្រាក់ដែលបានបើកមុនដើម្បីទិញវត្ថុទាំងនោះ។
- ចំនួនប្រាក់ដែលនៅជំពាក់អាគារដ្ឋាន។

ការកាត់ប្រាក់ឈ្នួលពុំអាចធ្វើឡើងលើប្រាក់ឈ្នួលទាំងស្រុងនោះទេ គឺនិយោជកអាចធ្វើការទូទាត់ប្រាក់ឈ្នួលនោះបន្តិចម្តងៗ ដើម្បីធានាបានថាកម្មករនិយោជិតដែលជំពាក់ ឬខ្ចីប្រាក់អាចធ្វើការចិញ្ចឹមជីវិត និងគ្រួសារបានជាប្រចាំខែ។

### ៣.២ ការកាត់ប្រាក់ឈ្នួល និងភាគទានសហជីព

ក្រៅពីការកាត់ប្រាក់ឈ្នួលសងនិយោជកហើយ ចំពោះកម្មករនិយោជិតដែលជាសមាជិកសហជីពអាចអនុញ្ញាតអោយកាត់ប្រាក់ឈ្នួលរបស់ខ្លួនធ្វើជាលាយលក្ខណ៍អក្សរ ដើម្បីបង់ភាគទានសហជីព ប៉ុន្តែការអនុញ្ញាតនេះក៏អាចធ្វើការបដិសេធបានគ្រប់ពេលវេលាដែរ[៥៧]។

### ៣.៣ ការរឹបអូស និងការផ្ទេរប្រាក់ឈ្នួល

ការរឹបអូស និងការផ្ទេរប្រាក់ឈ្នួលមិនអាច និងអាចធ្វើទៅបានក្នុងកម្រិតដូចជា៖

- ប្រាក់ឈ្នួលដែលទទួលបានតិចជាង ឬស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានធានាមិនអាចធ្វើការរឹបអូស ឬផ្ទេរបានជាដាច់ខាត។
- ប្រាក់ឈ្នួលដែលទទួលបានលើសពីមួយដង ដល់បីដងនៃប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានាអាចធ្វើការរឹបអូស ឬផ្ទេរបាន២០%(ម្ភៃភាគរយ)នៃភាគប្រាក់ឈ្នួល។
- ប្រាក់ឈ្នួលដែលទទួលបានលើសពីបីដង ដល់ដប់ដងនៃប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានធានាអាចធ្វើការរឹបអូស ឬផ្ទេរបាន៣០%(សាមសិបភាគរយ)នៃភាគប្រាក់ឈ្នួល។
- ប្រាក់ឈ្នួលដែលទទួលបានលើសពីដប់ដង នៃប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានធានាអាចធ្វើការរឹបអូស ឬផ្ទេរបាន៥០%(ហាសិបភាគរយ)នៃភាគប្រាក់ឈ្នួល។

[៥៦] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១២៧។

[៥៧] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១២៩ កថាខណ្ឌទី២។

ប្រាក់ឈ្នួលប្រចាំខែ ត្រូវបានយកមកធ្វើជាមូលដ្ឋានសម្រាប់គិតពីការរឹបអូស និងការផ្ទេរ។ អត្រាកម្រិត ភាពរឹបអូស ឬការផ្ទេរប្រាក់ឈ្នួលដូចបានបញ្ជាក់ខាងលើ ពុំអាចយកទៅជំទាស់ ឬតតាំងជាមួយនឹងឥណទាយកអាហារកិច្ចទេ[៥៨] ព្រោះប្រាក់ឈ្នួលដែលមិនត្រូវរឹបអូសនេះត្រូវរក្សាទុកសម្រាប់យកចិញ្ចឹមសមាជិកគ្រួសាររបស់កម្មករនិយោជិត។ ដូចនេះមិនមានហេតុផលណាមួយដែលបដិសេធចំពោះការរឹបអូសប្រាក់ឈ្នួល ដោយឥណទាយកអាហារកិច្ចរបស់កម្មករនិយោជិតខ្លួនឯងបានទេ។ ប៉ុន្តែឥណទាយកអាហារកិច្ចនេះអាចទាមទារយកប្រាក់ឈ្នួលបាន សម្រាប់តែសោធនអាហារកិច្ចធម្មតាប្រចាំខែតែប៉ុណ្ណោះ ចំណែកឯសោធនអាហារកិច្ចដែលកម្មករនិយោជិតជំពាក់តាំងពីយូរមកហើយនោះ ឥណទាយកអាហារកិច្ចត្រូវរង់ចាំជាមួយឥណទាយកផ្សេងទៀតដើម្បីទទួលយកភាគដែលអាចរឹបអូស ឬផ្ទេរបានដោយគោរពតាមអត្រាកម្រិតពីភាពរឹបអូស ឬភាពផ្ទេរបាននៃប្រាក់ឈ្នួល[៥៩]។

## ៣.៤ ឯកសិទ្ធិនៃប្រាក់ឈ្នួលដែលនៅជំពាក់

កម្មករនិយោជិតនៃគ្រឹះស្ថាន រោងចក្រ សហគ្រាសទាំងអស់ត្រូវបានការពារប្រឆាំងនឹងការរំលោភបំពានចំពោះប្រាក់ឈ្នួលពីសំណាក់ម្ចាស់បំណុលរបស់និយោជក មានន័យថានិយោជកត្រូវបើកប្រាក់ឈ្នួលអោយកម្មករនិយោជិត មុននឹងទូទាត់សំណងឲ្យម្ចាស់បំណុលរបស់ខ្លួន(អ្នកផ្គត់ផ្គង់សម្ភារៈសំណង់)។ ដើម្បីធានាការសងប្រាក់ឈ្នួលដែលនិយោជកនៅជំពាក់កម្មករនិយោជិតមានឯកសិទ្ធិទូទៅលើចលនទ្រព្យ ឬអចលនទ្រព្យរបស់និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាស។ ឯកសិទ្ធិទូទៅមានអត្ថិភាពក្នុងរយៈពេល០៦(ប្រាំមួយ)ខែចុងក្រោយមុនការប្រកាសក្ស័យធន ឬការជំរះបញ្ជីតាមផ្លូវតុលាការ។ ចំណែកអ្នកដើរទាក់ទង និងអ្នកតំណាងពាណិជ្ជកម្ម ប្រាក់កម្រៃជើងសា និងកម្រៃដែលត្រូវបានជាស្ថាពរត្រូវទទួលបានឯកសិទ្ធិក្នុងរយៈពេល០៦(ប្រាំមួយ)ខែចុងក្រោយមុនការប្រកាសក្ស័យធន ឬការជំរះបញ្ជីតាមផ្លូវតុលាការ។ ជាមួយគ្នានេះឯកសិទ្ធិដូចបានរៀបរាប់ខាងលើនេះ ត្រូវបានយកមកអនុវត្តចំពោះឥណទេយ្យរបស់កម្មករនយោជិតដែលត្រូវបានសម្រាប់ការឈប់សម្រាកដោយមានប្រាក់ឈ្នួល ប្រាក់បំណាច់ទូទាត់ការមិនជូនដំណឹងមុន និងប្រាក់បំណាច់បណ្តេញចេញដែរ[៦០]។

---

[៥៨] ឥណទាយកខាងអាហារកិច្ច ជាបុគ្គលទាំងឡាយដែលកម្មករនិយោជិតត្រូវបំពេញកាតព្វកិច្ចអាហារកិច្ចជូនដូចជាកូនកំពុងស្ថិតក្នុងការសិក្សា ឬឪពុកម្តាយចាស់ជរាជាដើម។

[៥៩] សៀវភៅនីតិការងារ របស់សាស្ត្រាចារ្យ ហៃល ចំរើន ឆ្នាំ២០០៥។

[៦០] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១២១ និងមាត្រា១២២។

ម្យ៉ាងវិញទៀត ឥណទេយ្យឯកសិទ្ធិទាំងនេះអាចយកជំទាស់ ឬតតាំងបានជាមួយនឹងឯកសិទ្ធិទូទៅ និងឯកសិទ្ធិពិសេសផ្សេងទៀត ក្នុងនោះក៏មានឯកសិទ្ធិរតនាគារសាធារណៈផងដែរ។ ចំនួនប្រាក់ដែលរតនាគារសាធារណៈបានកាត់លើអាណត្តិរបស់និយោជក នៅពេលក្រោយកាលបរិច្ឆេទបញ្ឈប់ការសងបំណុលត្រូវប្រគល់ជូនក្រុមម្ចាស់បំណុលវិញទាំងអស់[៦១]។

កម្មករនិយោជិតត្រូវទទួលបានចំណាត់ថ្នាក់ខ្ពស់ជាងគេ ក្នុងចំណោមឥណទាយកនានា ឥណទេយ្យមួយភាគរបស់ខ្លួនដែលមិនអាចរឹបអូសបាន គឺប្រាក់ឈ្នួល១០(ដប់)ថ្ងៃចុងក្រោយរបស់កម្មករ ប្រាក់ឈ្នួល៣០(សាមសិប)ថ្ងៃចុងក្រោយរបស់និយោជិត ប្រាក់ឈ្នួល៩០(កៅសិប)ថ្ងៃរបស់អ្នកតំណាងពាណិជ្ជកម្មដែលត្រូវទទួលបានមុនការប្រកាសក្ស័យធន ឬការជម្រះបញ្ជីតាមផ្លូវតុលាការ។ ភាគនៃឥណទេយ្យទាំងនេះ ត្រូវបើកឲ្យកម្មករនិយោជិតមុនឥណទេយ្យឯទៀត ក្នុងរយៈពេល១០(ដប់)ថ្ងៃចាប់ពីថ្ងៃប្រកាសក្ស័យធន ឬការជំរះបញ្ជីតាមផ្លូវតុលាការ ហើយត្រូវមានដីកាបញ្ជាក់ពីចៅក្រមស្នងការដែរ កាលបើភាគនៃឥណទេយ្យនេះត្រូវបានប្រើមូលនិធិដែលមានក្នុងពេលចាប់ប្រកាសក្ស័យធន ឬការជម្រះបញ្ជីតាមផ្លូវតុលាការ ឬប្រើមូលនិធិដែលទើបនឹងចូលជាលើកដំបូងបង្អស់។ ចំណែកឯចំនួនប្រាក់ឈ្នួលដែលឥណទេយ្យ មានចំណាត់ថ្នាក់ខ្ពស់ជាងគេនេះ មិនមែនសំដៅតែប្រាក់ឈ្នួលសុទ្ធសាធនោះទេ តែបូករួមទាំងប្រាក់បន្ទាប់បន្សំ សោហ៊ុយជម្ងឺចិត្តដែលត្រូវបង់ជាយថាហេតុពីការផ្តាច់កិច្ចសន្យាការងារ[៦២]។

### ៣.៥ សិទ្ធិទាមទារបើកប្រាក់ឈ្នួល

កម្មករនិយោជិតនៅតាមបណ្តាគ្រឹះស្ថាន រោងចក្រ សហគ្រាសទាំងអស់មានសិទ្ធិទាមទារ ឬសិទ្ធិប្តឹងទាមទារបើកប្រាក់ឈ្នួល ក្នុងរយៈពេល០៣(បី)ឆ្នាំរាប់ចាប់ពីថ្ងៃកំណត់បើកប្រាក់ឈ្នួលមក។ សិទ្ធិលើឥណទេយ្យនៃប្រាក់ឈ្នួលដែលមានអាជ្ញាយុកាលកំណត់០៣(បី)ឆ្នាំនេះ គ្របដណ្តប់លើប្រាក់ឈ្នួលសុទ្ធសាធ ប្រាក់ឈ្នួលបន្ទាប់បន្សំ និងឥណទេយ្យទាំងអស់របស់កម្មករនិយោជិតដែលមានប្រភពចេញពីកិច្ចសន្យាការងារ ព្រមទាំងប្រាក់បំណាច់ដែលត្រូវបានក្នុងករណីបណ្តេញចេញពីការងារ។

---

[៦១] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១២៣។

[៦២] ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១២៤ និងមាត្រា១២៥។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការវិភាគស្វែងយល់ បទពិសោធន៍ស្រាវជ្រាវ និងការសរសេរបកស្រាយខាងលើនាងខ្ញុំឃើញថា ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ បានផ្តល់គុណសម្បត្តិជាច្រើនដល់ភាគីដែលពាក់ព័ន្ធ ជាពិសេសភាគីនិយោជក និងកម្មករនិយោជិតដោយមានគោលដៅធានាដល់សិទ្ធិ និងការការពារផ្នែកសង្គមដល់កម្មករនិយោជិត ព្រមទាំងផ្តល់សុវត្ថិភាព គតិយុត្តដល់និយោជក ឬវិនិយោគិនក្នុងការផ្តល់អត្រាប្រាក់ឈ្នួលដល់កម្មករនិយោជិតរបស់ខ្លួន។ ការជួយលើកស្ទួយ ការជ្រោមជ្រែងជីវភាពរស់នៅរបស់កម្មករនិយោជិតក្នុងប្រទេសកម្ពុជា អោយមានលក្ខណៈសមរម្យពីសំណាក់និយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសដូចជាការផ្តល់ប្រាក់ឈ្នួល ឬប្រាក់កម្រៃប្រាក់បន្ថែមម៉ោង ប្រាក់កម្រៃជើងសា ប្រាក់បុព្វលាភ ប្រាក់ធនានុគ្រោះ ប្រាក់បើកជារង្វាន់ ប្រាក់វិភាជន៍ ប្រាក់តម្លៃអត្ថប្រយោជន៍ ភាគកម្មក្នុងប្រាក់ចំណេញ សោហ៊ុយជម្ងឺចិត្ត សោហ៊ុយធ្វើដំណើរ អត្ថប្រយោជន៍ដើម្បីសម្រួលការបំពេញការងារជាដើម ស្របពេលដែលកម្មករនិយោជិតត្រូវបំពេញការងារតាមបទប្បញ្ញត្តិ តាមលក្ខខណ្ឌ ឬកិច្ចសន្យាការងារជាថ្នូរក្នុងការទទួលបានប្រាក់កម្រៃទាំងអស់នេះ។ ចំពោះប្រាក់ឈ្នួលគោលរបស់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយនេះ មានការវិវត្តពី៩៥(កៅសិបប្រាំ)ដុល្លារអាមេរិកក្នុងមួយខែ ដល់១៧០(មួយរយចិតសិប)ដុល្លារអាមេរិកក្នុងមួយខែ ដោយឆ្លងតាមការពិភាក្សាពីស្ថាប័នត្រីភាគី និងផ្អែកលើការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច។ ជាមួយគ្នានេះដែរ បេឡាជាតិរបបសន្តិសុខសង្គមត្រូវបានបង្កើតឡើង និងតម្រូវឱ្យនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសចុះបញ្ជិកាសម្រាប់ជាប្រយោជន៍ដល់កម្មករនិយោជិតនៅពេលជួបហានិភ័យការងារ ឬធ្លាក់ខ្លួនមានជម្ងឺ ដោយកម្មករនិយោជិតជាសមាជិកនោះទទួលការពិនិត្យព្យាបាលនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពេទ្យព្យាបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម។

មួយវិញទៀត ដោយសារតែច្បាប់ស្តីពីការងារឆ្នាំ១៩៩៧របស់កម្ពុជាត្រូវបានបង្កើតឡើងដោយយកលំនាំតាមច្បាប់ការងារបារាំង និងក្រមការងារចាស់របស់ខ្លួន ខ្ញុំសង្កេតឃើញថា ប្រាក់ឈ្នួលដែលមានចែងនៅក្នុងច្បាប់ការងារនេះ មានចំណុចមួយចំនួនដែលមិនបានបកស្រាយអោយបានពេញលេញ ឬច្បាស់លាស់នោះទេ។ ជាក់ស្តែងចំណុចទាក់ទងនឹង ភាគកម្មក្នុងប្រាក់ចំណេញ ប្រាក់បុព្វលាភ តម្លៃអត្ថប្រយោជន៍ជាវត្ថុ និងប្រាក់វិភាជន៍ជាដើម ដោយឆ្លងកាត់តាមការសិក្សាស្រាវជ្រាវ និងស្វែងរកឯកសារបានបង្ហាញពីការបកស្រាយ ការអោយនិយមន័យ ឬការកំណត់ន័យខុសៗគ្នា ស្របពេលដែលនៅក្នុងច្បាប់ស្តីពីការងារមិនបានចែងច្បាស់លាស់ពីចំណុចទាំងនេះ។ បើក្រឡេកមើលជ្រុងម្ខាងទៀតឃើញថា ថ្វីបើកត្តាសេដ្ឋកិច្ច និងកត្តាសង្គមកិច្ចមានការរីកចម្រើន

ហើយជាផ្នែកមួយធ្វើអោយប្រាក់ឈ្នួលរបស់កម្មករនិយោជិតមានការវិវត្តន៍ក៏ពិតមែន ប៉ុន្តែក្នុងអំឡុងពេលប្រមាណឆ្នាំចុងក្រោយនេះបានកត់សម្គាល់ឃើញថា គ្រឹះស្ថាន រោងចក្រ សហគ្រាសមួយចំនួនបានបិទទ្វារ ប្រកាសក្ស័យធន ឬនិយោជក ឬម្ចាស់គ្រឹះស្ថាន រោងចក្រ សហគ្រាសបានរត់ចោល ដោយមិនបានបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតរបស់ខ្លួនតាមការសន្យានោះទេ ដែលជាហេតុធ្វើអោយជីវភាពរស់នៅរបស់កម្មករនិយោជិតដែលជាជនរងគ្រោះនោះជួបការលំបាក។ អត្រាប្រាក់ឈ្នួលដែលទទួលបានជួនគ្រប់គ្រាន់ ជួនមិនគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ជីវភាពរស់នៅជាពិសេសកូនៗនៅក្នុងបន្ទុក ដែលអាចប៉ះពាល់ដល់ការសិក្សារៀនសូត្រ មិនតែប៉ុណ្ណោះការចាយវាយទំនិញមានតម្លៃខ្ពស់ និងការទទួលទានចំណីអាហារប្រចាំថ្ងៃមិនមានប្រូតេអ៊ីនគ្រប់គ្រាន់ធ្វើអោយប៉ះពាល់សុខភាពរបស់កម្មករនិយោជិត រួមទាំងអាចជាហេតុបង្ករ ឬបង្អាក់ដំណើរការគ្រឹះស្ថាន រោងចក្រ សហគ្រាសដែរ។ ជាមួយគ្នានេះ រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ក៏បានចែងទាក់ទងនឹងសមភាពប្រាក់ឈ្នួល ថាប្រជាពលរដ្ឋទាំងពីរភេទមានសិទ្ធិទទួលបានប្រាក់បំណាច់ស្មើៗគ្នាចំពោះការងារដូចគ្នា ជៀសវាងការរើសអើងស្ត្រីភេទ ប៉ុន្តែនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ជាពិសេសការដ្ឋានសាងសង់មួយចំនួនធំ ដោយឆ្លងតាមការបញ្ជាក់របស់កម្មករសំណង់បានថ្លែងថា ទោះបីជាស្ត្រីធ្វើការងារដូចបុរស ឬធ្វើការបន្ថែមម៉ោង ក៏កម្មករជាស្ត្រីទទួលបានប្រាក់ឈ្នួលតិចជាងបុរស នេះសបញ្ជាក់ពីការអនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ដែលបានចងក្រងឡើង។

សរុបសេចក្តីមក យោងតាមការបកស្រាយចងក្រងសារណាក្រោមប្រធានបទ **"ប្រាក់ឈ្នួលរបស់កម្មករនិយោជិតនៅក្នុងប្រទេសកម្ពុជា"** សង្កេតឃើញថា ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧មានវិសាលភាពគ្រប់ដណ្តប់លើភាគីដែលពាក់ព័ន្ធក្នុងវិស័យការងារ ជាពិសេសនិយោជក និងកម្មករនិយោជិត។ មួយវិញទៀតទោះបីមានបទប្បញ្ញត្តិច្បាប់ចែង និងបានចូលជាធរមានក៏ពិតមែន ប៉ុន្តែនាងខ្ញុំសង្កេតឃើញមានចំណុចខ្វះខាតមួយចំនួនដែលបណ្តាលអោយមានការរំលោភបំពាន និងវិវាទកើតមានឡើងជារឿយៗ។ ដូចនេះ ភាគីដែលពាក់ព័ន្ធទាំងអស់គួរតែចូលរួមសហការគ្នាគោរពប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ដែលបានចែង។

## អនុសាសន៍

ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើង និងមិនទាន់កើតមានឡើងនៅក្នុងវិស័យការងារ ជាពិសេសទាក់ទងនឹងប្រាក់ឈ្នួលរបស់កម្មករនិយោជិតនៅក្នុងប្រទេសកម្ពុជា នាងខ្ញុំសូមសំណូមពរដល់៖

- ប្រមុខរាជរដ្ឋាភិបាលកម្ពុជាគួរតែពង្រឹងវិធានការណ៍ និងឃ្លាំមើលភាគីដែលពាក់ព័ន្ធក្នុងវិស័យការងារឲ្យអនុវត្តគោរពតាមបទប្បញ្ញត្តិ ឬប្រកាសដែលបានចែងអោយបានខ្ជាប់ខ្ជួន។
- រាជរដ្ឋាភិបាលកម្ពុជា ឲ្យស្វែងរកវិនិយោគិនមកវិនិយោគនៅក្នុងប្រទេសកម្ពុជាឲ្យបានច្រើន និងស្វែងរកទីផ្សារលក់ផលិតផលដើម្បីជាឱកាសក្នុងការបង្កើនការងារ និងដំឡើងប្រាក់ឈ្នួលសម្រាប់ធានាដល់ការរស់នៅរបស់កម្មករនិយោជិតឲ្យសមាមាត្រនឹង សេដ្ឋកិច្ច តម្លៃទីផ្សារ និងជីវភាពរស់នៅរបស់ប្រជាជនដទៃទៀតក្នុងសង្គមកម្ពុជា។
- ក្រសួង ស្ថាប័នមានសមត្ថកិច្ចចុះត្រួតពិនិត្យស្តង់ដារគ្រឹះស្ថាន រោងចក្រ សហគ្រាសដើម្បីធានាសុវត្ថិភាពដល់កម្មករនិយោជិត និងបញ្ចៀសពីគ្រោះថ្នាក់ផ្សេងៗ។
- អធិការការងារគួរតែចុះពង្រឹង និងត្រួតពិនិត្យឡើងវិញបញ្ហាដែលកើតមានឡើងនៅតាមបណ្តាគ្រឹះស្ថាន រោងចក្រ សហគ្រាស ជាពិសេសការដ្ឋានសំណង់ទាក់ទងនឹងបរិយាកាសកន្លែងធ្វើការងារ សមភាពប្រាក់ឈ្នួល ក៏ដូចជាម៉ោងធ្វើការងារ។
- ស្ថាប័នរាជរដ្ឋាភិបាល និងភាគីនិយោជកត្រូវតែធានាដល់សិទ្ធិ និងការធានាលើប្រាក់ឈ្នួលរបស់កម្មករនិយោជិត រួមទាំងធានាសុខសុវត្ថិភាព សុខុមាលភាពរបស់កម្មករនិយោជិត ដើម្បីប្រការ ការពារបញ្ហាជាយថាហេតុណាមួយ។

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

### ក.ច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ២៤ កញ្ញា ១៩៩៣
- ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ១០ មករា ១៩៩៧

### ខ. អនុក្រឹត្យ

- អនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- អនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- អនុក្រឹត្យលេខ២៧៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការដំឡើងប្រាក់វិភាជន៍គ្រួសាររបស់មន្ត្រីរាជការស៊ីវិល ប្រាក់បំណាច់ឧបត្ថម្ភគ្រួសារ និងកូនឃោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិកម្ពុជា មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ

### គ.ប្រកាស

- ប្រកាសលេខ១០ សកបយ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីប្រាក់បំណាច់នៃការងារដែលបានធ្វើក្នុងឱកាសថ្ងៃឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល
- ប្រកាសលេខ២៦៧ សកបយ. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ស្តីពីការឈប់សម្រាកពិសេស
- ប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- ប្រកាសលេខ២៣៣ កប.ប្រ.ក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- ប្រកាសលេខ៣១៧ ក.ប/ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗ
- ប្រកាសលេខ៣៩៦ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៨

- ប្រកាសអន្តរក្រសួងលេខ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធមិសុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន
- ប្រកាសលេខ៤៤៩ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ប្រកាសលេខ៤៩៣ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួលប្រចាំឆ្នាំ២០១៨
- ប្រកាសលេខ០៨៤/១៨ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការឈប់សម្រាកទិវាជាតិនៃការចងចាំ

**ឃ.សារាចរ/សេចក្តីណែនាំ**

- សារាចរលេខ១៨៥ កប/សរ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីប្រាក់ឈ្នួលការងារពេលយប់
- សេចក្តីណែនាំលេខ០០១/១៤ ក.ប/ស.ណ.ន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តប្រកាសលេខ៣១៧ ក.ប/ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗ

**ង.សេចក្តីជូនដំណឹង**

- សេចក្តីជូនដំណឹងលេខ០៦ សកអ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៧
- សេចក្តីជូនដំណឹងលេខ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១
- សេចក្តីជូនដំណឹងលេខ២០៦ កប/ស.ជ.ណ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១
- សេចក្តីជូនដំណឹងលេខ២៣០ ក.ប/ស.ជ.ណ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២
- សេចក្តីជូនដំណឹងលេខ១០៣ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣
- សេចក្តីជូនដំណឹងលេខ០១៤/១៧ ក.ប/ស.ជ.ណ.ក.ប.ក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការផ្តល់ប្រាក់ឈ្នួល និងប្រាក់បំណាច់ប្រចាំថ្ងៃចំពោះកម្មករនិយោជិតជាស្ត្រីសម្រាប់រយៈពេលនៃការឈប់សម្រាកមាតុភាព

## ២. សៀវភៅ

- សៀវភៅនីតិការងារ របស់សាស្ត្រាចារ្យ ហ៊ែល ចំរើន ឆ្នាំ២០០៥

## ៣. សារពត៌មាន និងគេហទំព័រ

- កាសែតភ្នំពេញប៉ុស្ត៍ ចេញផ្សាយថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧
- ពិធីសំណេះសំណាល និងផ្សព្វផ្សាយរបបថែទាំសុខភាព ដល់កម្មករ-កម្មការីនីដែលបម្រើការងារនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ចេញផ្សាយថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧
- មេគង្គប៉ុស្ត៍ចេញផ្សាយថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ (http://mekong-post.com/33091)

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ ក្រុមហ៊ុន ធី និង ខេ ហ្គាមេនអ៊ីនដាស្ទ្រី ២ (T & K GARMENT INDUSTRY 2)

ឧបសម្ព័ន្ធទី២ ៖ សារព័ត៌មាន

ផ្សេងៗ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ......១០៥........កប/ប្រ.ក

# ប្រកាស
# ស្តីពី
# តាងកាលិកហានិភ័យការងារ

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

### ប្រការ ១.- សិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ

១.១ កម្មករនិយោជិតទាំងអស់នៃសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម មានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ នៅពេលដែលសាមីជនទទួលរងនូវហានិភ័យការងារ ។

១.២ ហានិភ័យការងារ រួមមាន គ្រោះថ្នាក់ការងារ គ្រោះថ្នាក់នៅពេលធ្វើដំណើរដោយត្រង់ទៅកន្លែងធ្វើការ ឬមកពីកន្លែងធ្វើការឆ្ពោះទៅលំនៅស្ថាន និងជំងឺវិជ្ជាជីវៈ ។

១.៣ តាវកាលិកដែលកំណត់ក្នុងប្រកាសនេះត្រូវនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។

១.៤ មន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ឬគ្រូពេទ្យព្យាបាល ត្រូវមានការទទួលស្គាល់ពីបេឡាជាតិរបបសន្តិសុខសង្គម ។

### ប្រការ ២.- ការជូនដំណឹងហានិភ័យការងារ

២.១ បន្ទាប់ពីបានទទួលដំណឹងពីកម្មករនិយោជិតដែលជាអ្នករងនូវហានិភ័យការងារ ឬអ្នកតំណាងអ្នករងគ្រោះ និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលបានចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងអំពីឧបទ្ទវហេតុនោះទៅបេឡាជាតិរបបសន្តិសុខសង្គមក្នុងរយៈពេលយ៉ាងយូរបំផុត ៤៨ (សែសិបប្រាំបី) ម៉ោងនៃថ្ងៃធ្វើការ ។

២.២ ការជូនដំណឹងហានិភ័យការងារត្រូវធ្វើតាមទម្រង់បែបបទដែលមានកំណត់នៅក្នុងប្រកាសរួមរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល ។

### ប្រការ ៣.- ការអង្កេតហានិភ័យការងារ

៣.១ បន្ទាប់ពីទទួលបានរបាយការណ៍ហានិភ័យការងារ ការិយាល័យតាវកាលិក ឬការិយាល័យខេត្តក្រុងនៃបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងជាបន្ទាន់ទៅអធិការ ឬអភិបាលសន្តិសុខសង្គម ។

អធិការ ឬអភិបាលសន្តិសុខសង្គម ត្រូវធ្វើអង្កេត និងផ្តល់លទ្ធផលលើករណីនីមួយៗមកការិយាល័យតាវកាលិកឱ្យបានយ៉ាងឆាប់បំផុត។

៣.២ ចំពោះករណីដែលមានលក្ខណៈស្មុគស្មាញ អធិការ ឬអភិបាលសន្តិសុខសង្គមអាចស្នើសុំជំនួយពីអ្នកឯកទេស ឬសុំកិច្ចសហការពីអធិការ ឬអភិបាលការងារ។ ការចំណាយសម្រាប់ផ្នែកនេះ គឺជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។

៣.៣ ចំពោះគ្រោះថ្នាក់ពេលធ្វើដំណើរ អធិការ ឬអភិបាលសន្តិសុខសង្គមត្រូវស្នើសុំព័ត៌មានដែលទាក់ទងនឹងទីកន្លែង ពេលវេលា មូលហេតុនៃគ្រោះថ្នាក់ពីសាក្សី ឬអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែងកើតហេតុ។

## ប្រការ ៤.- ការផ្តល់សេវាសង្គ្រោះបន្ទាន់

ក្នុងករណីដែលគ្រោះថ្នាក់កើតនៅនឹងកន្លែងធ្វើការ និយោជកត្រូវផ្តល់ការសង្គ្រោះបន្ទាន់ ដែលនៅកន្លែងដែលជិតបំផុត និងបន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ ការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនខាងលើត្រូវស្ថិតនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។ ក្នុងករណីដែលគ្រោះថ្នាក់នៅពេលធ្វើដំណើរ សាមីជន ឬនិយោជកអាចទាមទារការទូទាត់សង លើការចំណាយសម្រាប់ការសង្គ្រោះនេះពីបេឡាជាតិរបបសន្តិសុខសង្គម។

## ប្រការ ៥.- ការផ្តល់សេវាថែទាំ និងព្យាបាល

៥.១ ការព្យាបាលចំពោះកម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារត្រូវតែប្រព្រឹត្តទៅនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

៥.២ កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ មានសិទ្ធិទទួលបាន ការពិនិត្យព្យាបាល ការសម្រាកព្យាបាល នៅតាមបណ្តាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ផ្អែកលើកិច្ចព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គមជាមួយនឹងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលសាមី។

៥.៣ ក្នុងករណីដែល គ្រូពេទ្យព្យាបាលតម្រូវឱ្យទិញឱសថ ឬ សំភារៈឧបករណ៍ដែលចាំបាច់សម្រាប់ការថែទាំ និងព្យាបាលដែលពុំមានចែងនៅក្នុងកិច្ចព្រមព្រៀង បេឡាជាតិរបបសន្តិសុខសង្គមអាចទូទាត់សងទៅជនរងគ្រោះ ឬអ្នកតំណាងវិញបាន លុះណាតែមានវេជ្ជបញ្ជា និងវិក្កយបត្រត្រឹមត្រូវ។

៥.៤ នាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំបញ្ជីមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលមានលក្ខណៈសម្បត្តិសមស្របតាមបទដ្ឋានបច្ចេកទេសវេជ្ជសាស្ត្រ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលនៃបេឡា

ជាតិរបបសន្តិសុខសង្គមអនុម័តយល់ព្រម ។

## **ប្រការ ៦.- ការគណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ**

៦.១ ប្រាក់ឈ្នួលមធ្យម គឺជាផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ មុនកាលបរិច្ឆេទនៃគ្រោះថ្នាក់ ។ ប្រាក់ឈ្នួលជាប់ភាគទាន ត្រូវបានកំណត់ក្នុងតារាងដូចមានចែងក្នុង**ឧបសម្ព័ន្ធ ១** នៃប្រកាសនេះ ។

៦.២ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែកនៃប្រាក់ឈ្នួលមធ្យមដូចមានចែងក្នុងចំណុច ៦.១ នឹង ៣០ (សាមសិប) ថ្ងៃ ។

៦.៣ ការគណនាប្រាក់ឈ្នួលមធ្យម ដែលកំណត់នៅក្នុងប្រកាសនេះមានអានុភាពចំពោះតែការគណនាតាវកាលិកសន្តិសុខសង្គមប៉ុណ្ណោះ ។

## **ប្រការ ៧.-ការផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន**

៧.១ រយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវបានកំណត់ដូចតទៅ:

- រយៈពេលនៃការសម្រាកព្យាបាលមុខរបួស ឬជំងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល
- រយៈពេលនៃការសម្រាកក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា ។

៧.២ ក្នុងរយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ដូចមានចែងក្នុងវាក្យខ័ណ្ឌ ៧.១ ខាងលើ កម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារមានសិទ្ធិទទួលបានតាវកាលិកពីបេឡាជាតិរបបសន្តិសុខសង្គម ដូចតទៅ:

- ប្រាក់បំណាច់ប្រចាំថ្ងៃ ដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការកើតឧបទ្ទវហេតុបណ្តាលឱ្យទទួលរងនូវហានិភ័យការងារ
- ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំអ្នករងគ្រោះពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ក្នុងករណី ដែលស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរតម្រូវឱ្យមានអ្នកនៅចាំថែទាំ តាមសំណើសុំរបស់គ្រូពេទ្យព្យាបាល ។

៧.៣ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវផ្តល់ចំពោះតែហានិភ័យការងារ ដែលតម្រូវឱ្យមានការសម្រាកព្យាបាលលើសពី ០៤(បួន) ថ្ងៃឡើងទៅ ។

៧.៤ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវស្មើនឹង ៧០ (ចិតសិប) ភាគរយ នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ។ ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំនៅមន្ទីរពេទ្យ ត្រូវស្មើនឹង ៥០ (ហាសិប) ភាគរយនៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ ។

៧.៥ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្ន អាចផ្ដល់ជូនជនរងគ្រោះដោយហានិភ័យការងារ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៨០ (មួយរយប៉ែតសិប) ថ្ងៃ។

**ប្រការ ៨.- គោលការណ៍សម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍**

៨.១ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង ២០ ភាគរយ មានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ។ ប្រាក់វិភាជន៍នេះត្រូវផ្ដល់ជូនអ្នករងគ្រោះតែម្ដងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម:

**វបក = បឈម x ៧០% x កបក x ២០%មគប**

- **វបក:** វិភាជន៍បាត់បង់សមត្ថភាពការងារ
- **បឈម:** ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ
- **កបក:** កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ
- **មគប:** មេគុណតម្លៃបច្ចុប្បន្ន

៨.២ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារចាប់ពី ២០ ភាគរយឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍។ប្រាក់ធនលាភសរុបសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានគិតតាមរូបមន្តដូចខាងក្រោម:

**ធល = បឈម x ៧០ % x [កបក − ១/៥ កបក] x មគប**

- **ធល:** ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ

៨.៣ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្ដោះអាសន្នជានិច្ច។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឱ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារអ្នករងគ្រោះឡើងវិញក្នុងរយៈពេល ១ (មួយ) ឆ្នាំយ៉ាងយូរ។ ជនរងគ្រោះដែលទទួលបានប្រាក់ធនលាភត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាពតាមការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម។

៨.៤ កម្រិតនៃការបាត់បង់សមត្ថភាពការងារ ត្រូវបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ ២** នៃប្រកាសនេះ។ មេគុណតម្លៃបច្ចុប្បន្ន ត្រូវបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ ៣**។

**ប្រការ ៩.- ប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាជនរងគ្រោះ**

កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ក្នុងកម្រិត ១០០ ភាគរយ មានសិទ្ធិទទួលបានប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាដល់ខ្លួន។ ប្រាក់បន្ថែម

សម្រាប់អ្នកចាំថែរក្សាត្រូវស្មើ ៥០ ( ហាសិប) ភាគរយនៃប្រាក់ធនលាភរបស់ជនរងគ្រោះ ។

## ប្រការ ១០.- ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព

ក្នុងករណីដែលមានការទទួលរងនូវហានិភ័យការងាររបួសបណ្តាលឱ្យបាត់បង់ជីវិត អ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព ត្រូវបានផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព ដែលមានចំនួន ១.០០០.០០០ ( មួយលាន) រៀល ។ ប្រាក់វិភាជន៍នេះ ត្រូវតែផ្តល់ជូនទៅជន ដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ ។

## ប្រការ ១១.- តាវកាលិកឧត្តរជីវី

១១.១ ឧត្តរជីវីនៃជនរងគ្រោះដោយហានិភ័យការងារដូចមានចែងនៅក្នុងមាត្រា ៣៤ នៃអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមមានសិទ្ធិទទួលបានតាវកាលិកឧត្តរជីវី ។

១១.២ តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្តល់ឱ្យសិទ្ធិវន្តនៃជនរងគ្រោះ តាមអត្រាដូចខាងក្រោម:

ក. ក្នុងករណីសិទ្ធិវន្ត មានរួមទាំងប្រពន្ធ ឬប្តី កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក

- ប្រពន្ធ ឬប្តី = ៣/៥ x ៦៣% បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក= ២/៥ x ៦៣% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ៧% បឈម

ខ. ក្នុងករណីសិទ្ធិវន្ត មានតែប្រពន្ធ ឬប្តី និង/ឬ កូន

- ប្រពន្ធ ឬប្តី = ៣/៥ x ៧០%បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៧០%បឈម

គ. ក្នុងករណីសិទ្ធិវន្តមានតែឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

ឃ. ក្នុងករណីសិទ្ធិវន្ត មានតែកូន និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨%បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

ង. ក្នុងករណីសិទ្ធិវន្តមានតែ ប្រពន្ធ ឬប្តី និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ប្រពន្ធ ឬប្តី = ២៨%បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

១១.៣ សិទ្ធិវន្ត ជាប្រពន្ធ ឬប្តីនៃជនរងគ្រោះ ត្រូវមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ សិទ្ធិទទួលធនលាភចំពោះសិទ្ធិវន្តដែលជាប្រពន្ធ ឬប្តី ត្រូវបានរំលាយនៅពេលដែលសាមីជនរៀបអាពាហ៍ពិពាហ៍ជាថ្មី។ ក្នុងករណីនៃការរៀបអាពាហ៍ពិពាហ៍ជាថ្មី សាមីជនត្រូវជូនដំណឹងមកបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរបំផុត ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ ការខកខានមិនបានជូនដំណឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន សាមីជននឹងត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

១១.៤ សិទ្ធិវន្តជា កូនត្រូវមានស្ថានភាពស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងចំណុច ៣៤.១ ខ មាត្រា ៣៤ នៃអនុក្រឹត្យលេខ១៦ អនក្រ/បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧។

១១.៥ សិទ្ធិទទួលធនលាភនៃសិទ្ធិវន្ត ត្រូវបានរំលាយនៅពេលដែលសាមីជនទទួលមរណភាព។

## ប្រការ ១២.- សេវាបុនរីតិសម្បទា

១២.១កម្មករនិយោជិតដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានឧបករណ៍ ឬអវៈយវៈសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យផ្លូវការឬគ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

១២.២កម្មករនិយោជិតដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ស្របតាមលក្ខខណ្ឌដែលនឹងកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ប្រការ ១៣.- ការទាមទារតាវកាលិក

១៣.១ ការទាមទារតាវកាលិកសម្រាប់ការថែទាំ និងព្យាបាល អាចត្រូវបានធ្វើឡើងដោយមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលព្យាបាលជនរងគ្រោះ ឬនិយោជក ឬក៏កម្មករនិយោជិតជាជនរងគ្រោះផ្ទាល់តាមទម្រង់ "**តាវកាលិកថែទាំ និងព្យាបាល** " ឬហៅថាទម្រង់ " **៣.០២** "ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៤** នៃប្រកាសនេះ។

១៣.២ ការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវធ្វើដោយជនរងគ្រោះ ឬតំណាងតាមទម្រង់ "**តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន** " ឬហៅថាទម្រង់ "**៣.០៣** " ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៥** នៃប្រកាសនេះ។ បែបបទ នៃការទាមទារនេះត្រូវមានភ្ជាប់ជាមួយនូវវេជ្ជបញ្ជា និងលិខិតបញ្ជាក់ពីគ្រូពេទ្យព្យាបាលផ្លូវការ។

១៣.៣ ការទាមទារតាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវធ្វើឡើងដោយជនរងគ្រោះតាមទម្រង់ "**តាវកាលិកបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍** " ឬហៅថាទម្រង់

"៣.០៤ " ដូចមានចែងក្នុង**ឧបសម្ព័ន្ធ ៦** នៃប្រកាសនេះ។ ក្នុងករណីដែល ជនរងគ្រោះមិនអាចមានសមត្ថភាព ក្នុងការទាមទារតាវកាលិកបាន ដោយសារស្ថានភាពនៃការបាត់បង់សមត្ថភាពការងារធ្ងន់ធ្ងរ ការទាមទារនេះអាចត្រូវធ្វើដោយអ្នកតំណាងជនរងគ្រោះ។ អ្នកតំណាងជនរងគ្រោះ អាចជាប្តី ប្រពន្ធ កូន ឬជន ដែលមានភារៈចិញ្ចឹមដោយផ្ទាល់ចំពោះជនរងគ្រោះ។

១៣.៤ ការទាមទារតាវកាលិកឧត្តរជីវី និងសោហ៊ុយបូជាសព ត្រូវធ្វើដោយសិទ្ធិវន្តនៃជនរងគ្រោះ ឬអ្នកតំណាង តាមទម្រង់ "**តាវកាលិកឧត្តរជីវី**" ឬហៅថាទម្រង់ " **៣.០៥** " និងទម្រង់ " **វិភាជន៍បូជាសព**" " ឬហៅថា ទម្រង់ "**៣.០៦**" ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៧ និង ៨** នៃប្រកាសនេះ។

១៣.៥ សិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសព ត្រូវអស់សុពលភាពត្រឹមរយៈពេល ១ (មួយ) ឆ្នាំ។ ចំពោះសិទ្ធិក្នុងការទាមទារប្រាក់ធនលាភ ត្រូវអស់សុពលភាពត្រឹមរយៈពេល ៥ (ប្រាំ) ឆ្នាំ។

១៣.៦ ការបើកប្រាក់ធនលាភ ត្រូវធ្វើប្រចាំត្រីមាស។

## ប្រការ ១៤.- ការយល់ព្រមចំពោះការទាមទារតាវកាលិក

១៤.១ តាវកាលិកថែទាំ និងព្យាបាល ដែលត្រូវបានទទួលការយល់ព្រមពីបេឡាជាតិរបបសន្តិសុខសង្គម លុះណាតែការថែទាំនិងព្យាបាលនោះធ្វើនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

ប្រសិនបើការថែទាំ និងព្យាបាលធ្វើនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលផ្សេងក្រៅពីការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម ការទូទាត់សងវិញត្រូវធ្វើតាមអត្រាតម្លៃដែលបេឡាជាតិរបបសន្តិសុខសង្គមបានកំណត់។

តារាងតម្លៃសម្រាប់ការថែទាំ និងព្យាបាល ត្រូវបានកំណត់តាមកិច្ចព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គម និងបណ្តាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល។

១៤.២ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ដែលត្រូវបានទទួលការយល់ព្រមពីបេឡាជាតិរបបសន្តិសុខសង្គម លុះណាតែការទាមទារនោះស្របនឹងលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧ វាក្យខ័ណ្ឌ ៧.១, ៧.២ និង ៧.៣ នៃប្រកាសនេះ។

១៤.៣ តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានយល់ព្រម លុះត្រាតែការបាត់បង់សមត្ថភាពនោះត្រូវបានវាយតម្លៃពីគ្រូពេទ្យផ្លូវការ ឬ គណកម្មការវេជ្ជសាស្ត្រនៃបេឡាជាតិរបបសន្តិសុខសង្គម ស្របតាមតារាងនៃកម្រិតបាត់បង់សមត្ថភាពការងារដូចមានចែងក្នុង**ឧបសម្ព័ន្ធ ២** នៃប្រកាសនេះ។ក្នុងករណីដែល កម្រិតបាត់បង់សមត្ថភាពការងារពុំមានចែងនៅក្នុងតារាងខាងលើ គណកម្មការ

វេជ្ជសាស្ត្រ ត្រូវវាយតម្លៃកម្រិតបាត់បង់សមត្ថភាពតាមបច្ចេកទេសវេជ្ជសាស្ត្រ ដោយមានការចូលរួមពីគ្រូពេទ្យឯកទេសតាម ស្ថានភាពជាក់ស្តែងនីមួយៗ។

**ប្រការ ១៥.- អន្តរប្បញ្ញត្តិ**

ចំពោះសហគ្រាស គ្រឹះស្ថានដែលពុំទាន់ត្រូវបានចុះបញ្ជីកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គមការផ្តល់តាវកាលិកសម្រាប់ហានិភ័យការងារ ត្រូវបន្តអនុវត្តតាមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ ១៦.- អវសានប្បញ្ញត្តិ**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ[illegible] ឆ្នាំ២០០៨

រដ្ឋមន្ត្រី

វង សូត

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជូនជ្រាប "
- កាលប្បវត្តិ និងឯកសារ

## តារាងប្រាក់ឈ្នួលជាប់ភាគទាន

| ថ្នាក់ | ចំនួនប្រាក់ឈ្នួលសរុប ( រៀល) | ប្រាក់ឈ្នួលជាប់ភាគទាន( រៀល) |
|---|---|---|
| ១ | តិចជាង ២០០.០០០ | ២០០.០០០ |
| ២ | ២០០.០០១ -២៥០.០០០ | ២២៥.០០០ |
| ៣ | ២៥០.០០១-៣០០.០០០ | ២៧៥.០០០ |
| ៤ | ៣០០.០០១-៣៥០.០០០ | ៣២៥.០០០ |
| ៥ | ៣៥១.០០១-៤០០.០០០ | ៣៧៥.០០០ |
| ៦ | ៤០០.០០១-៤៥០.០០០ | ៤២៥.០០០ |
| ៧ | ៤៥០.០០១-៥០០.០០០ | ៤៧៥.០០០ |
| ៨ | ៥០០.០០១-៥៥០.០០០ | ៥២៥.០០០ |
| ៩ | ៥៥០.០០១-៦០០.០០០ | ៥៧៥.០០០ |
| ១០ | ៦០០.០០១-៦៥០.០០០ | ៦២៥.០០០ |
| ១១ | ៦៥០.០០១-៧០០.០០០ | ៦៧៥.០០០ |
| ១២ | ៧០០.០០១-៧៥០.០០០ | ៧២៥.០០០ |
| ១៣ | ៧៥០.០០១-៨០០.០០០ | ៧៧៥.០០០ |
| ១៤ | ៨០០.០០១-៨៥០.០០០ | ៨២៥.០០០ |
| ១៥ | ៨៥០.០០១-៩០០.០០០ | ៨៧៥.០០០ |
| ១៦ | ៩០០.០០១-៩៥០.០០០ | ៩២៥.០០០ |
| ១៧ | ៩៥០.០០១-១.០០០.០០០ | ៩៧៥.០០០ |
| ១៨ | ១.០០០.០០១ ឡើង | ១.០០០.០០០ |

## តារាងកម្រិតនៃការបាត់បង់សមត្ថភាពការងារ

### ផ្នែកទី ១

### បញ្ជីគ្រោះថ្នាក់ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ទាំងស្រុង

| ល.រ | ការបរិយាយអំពីគ្រោះថ្នាក់ | ភាគរយនៃការបាត់បង់សមត្ថភាពការងារ |
|---|---|---|
| ១ | បាត់បង់ប្រអប់ដៃទាំងពីរ ឬកាត់នៅផ្នែកខាងលើ | ១០០ |
| ២ | បាត់ប្រអប់ដៃមួយ និងប្រអប់ជើងមួយ | ១០០ |
| ៣ | កាត់ជើងឬភ្លៅ ឬកាត់ជើង ឬភ្លៅម្ខាង និងបាត់ប្រអប់ជើងម្ខាងទៀត | ១០០ |
| ៤ | បាត់បង់ចក្ខុប្រសាទនៅកំរិតណាមួយដែលមិនអាចឱ្យអ្នកទាមទារបំពេញការងារដែលប្រើប្រាស់ក្រសែភ្នែកជាសំខាន់ (ខ្វាក់មើលមិនឃើញ) | ១០០ |
| ៥ | ការខូចទ្រង់ទ្រាយមុខធ្ងន់ធ្ងរ | ១០០ |
| ៦ | ថ្លង់ទាំងស្រុង | ១០០ |

### ផ្នែកទី ២

### បញ្ជីគ្រោះថ្នាក់ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដោយផ្នែក

| ល.រ | ការបរិយាយអំពីគ្រោះថ្នាក់ | ភាគរយនៃការបាត់បង់សមត្ថភាពការងារ |
|---|---|---|
| | **ការកាត់អវៈយវៈផ្នែកខាងលើ (ដៃមួយណាក៏ដោយ)** | |
| ១ | កាត់សន្លាក់ស្មា | ៩០ |
| ២ | កាត់ក្រោមស្មាដែលគល់នៅតិចជាង ៨ " ពីចុងនៃ acromion | ៨០ |
| ៣ | កាត់ ៨ " ពីចុងនៃ acromion ទៅតិចជាង 4" ក្រោមចុងនៃ olecranon | ៧០ |
| ៤ | បាត់ប្រអប់ដៃ ឬមេដៃ និងម្រាម ៤ នៃប្រអប់ដៃមួយ ឬកាត់ពី 4 1/2" ក្រោមចុងនៃ olecranon | ៦០ |
| ៥ | បាត់មេដៃ | ៣០ |
| ៦ | បាត់មេដៃ និងឆ្អឹង metacarpal | ៤០ |
| ៧ | បាត់ម្រាមបួននៃប្រអប់ដៃមួយ | ៥០ |
| ៨ | បាត់ម្រាមបីនៃប្រអប់ដៃមួយ | ៣០ |
| ៩ | បាត់ម្រាមពីរនៃប្រអប់ដៃមួយ | ២០ |
| ១០ | បាត់ថ្នាំងចុងក្រោយនៃមេដៃ | ២០ |

| ការកាត់អវៈយវៈផ្នែកក្រោម | | |
|---|---|---|
| ១១ | កាត់ប្រអប់ជើងទាំងពីរបណ្តាលឱ្យដើរខ្វិច | ៩០ |
| ១២ | កាត់តាម feet proximal ទាំងពីរទៅ metatarso-phalangeal joint | ៨០ |
| ១៣ | បាត់ម្រាមជើងទាំងអស់នៃប្រអបជើងទំងពីរតាម metatarso-phalangeal joint | ៤០ |
| ១៤ | បាត់ម្រាមជើងទាំងអស់នៃ feet proximal ទាំងពីរទៅ proximal inter-phalangeal joint | ៣០ |
| ១៥ | បាត់ម្រាមជើងទាំងអស់នៃ feet distal ទាំងពីរទៅ proximal inter-phalangeal joint | ២០ |
| ១៦ | កាត់ត្រគាក | ៩០ |
| ១៧ | កាត់ក្រោមត្រគាកដែលសល់គល់ប្រវែងមិនលើស 5" ដែលវាស់ពីចុង នៃ great trenchanter | ៨០ |
| ១៨ | កាត់ក្រោមត្រគាកដែលសល់គល់ប្រវែងមិនលើស 5" ដែលវាស់ពីចុង នៃ great trenchanter ប៉ុន្តែមិនហួសពីពាក់កណ្តាលភ្លៅ | ៧០ |
| ១៩ | កាត់ក្រោមពាក់កណ្តាលភ្លៅទៅ 3 1/2" ក្រោមជង្គង់ | ៦០ |
| ២០ | កាត់ក្រោមជង្គង់ដែលនៅសល់គល់លើស 3 1/2" ប៉ុន្តែមិនលើស 5" | ៥០ |
| ២១ | កាត់ក្រោមជង្គង់ដោយសល់គលលើសពី 5" | ៤០ |
| ២២ | កាត់ប្រអប់ជើងមួយបណ្តាលឱ្យដើរទប់ខាងចុង | ៣០ |
| ២៣ | កាត់ពី foot proximal មួយទៅ meta torso phalangeal joint | ៣០ |
| ២៤ | បាត់ម្រាមជើងទាំងអស់នៃប្រអបជើងមួយតាម meta torso phalangeal joint | ២០ |
| ២៥ | បាត់ភ្នែកម្ខាងដោយគ្មានភាពស្មុគស្មាញ ហើយម្ខាងទៀតនៅធម្មតា | ៤០ |
| ២៦ | បាត់ចក្ខុវិញ្ញាណនៃភ្នែកម្ខាងដោយគ្មានភាពស្មុគស្មាញ ឬដោយគ្មានការខូចទ្រង់ទ្រាយនៃគ្រាប់ភ្នែក ហើយម្ខាងទៀតនៅធម្មតា | ៣០ |
| ២៧ | ត្រចៀកម្ខាងថ្លង់ទាំងស្រុង | ២០ |
| ***ក- ម្រាមដៃឆ្វេង ឬស្តាំ*** | | |
| ***ចង្អុលដៃ*** | | |
| ២៨ | ទាំងមូល | ១៤ |
| ២៩ | ពីរថ្នាំងដៃ | ១១ |
| ៣០ | មួយថ្នាំងដៃ | ៩ |
| ៣១ | កាត់ចុងដោយម៉ាស៊ីនដោយមិនបាត់ឆ្អឹង | ៥ |
| ***ម្រាមកណ្តាល*** | | |
| ៣២ | ទាំងមូល | ១២ |
| ៣៣ | ពីរថ្នាំងដៃ | ៩ |

| | | |
|---|---|---|
| ៣៤ | មួយថ្នាំងដៃ | ៧ |
| ៣៥ | កាត់ចុងដោយម៉ាស៊ីនដោយមិនបាត់ឆ្អឹង | ៤ |
| ***នាងដៃ និងកូនដៃ*** | | |
| ៣៦ | ទាំងមូល | ៧ |
| ៣៧ | ពីរថ្នាំងដៃ | ៦ |
| ៣៨ | មួយថ្នាំងដៃ | ៥ |
| ៣៩ | កាត់ចុងដោយម៉ាស៊ីនដោយមិនបាត់ឆ្អឹង | ២ |
| ***ខ-ម្រាមជើងឆ្វេង ឬស្តាំ*** | | |
| ***មេជើង*** | | |
| ៤០ | Through metatarso-phalangeal joint | ១៤ |
| ៤១ | Part, with some loss of bone | ៣ |
| ***ម្រាមជើងដទៃទៀត*** | | |
| ៤២ | Through metatarso-phalangeal joint | ៣ |
| ៤៣ | Part, with some loss of bone | ១ |
| ***ម្រាមពីរនៃប្រអប់ជើងមួយ មិនគិតមេជើង*** | | |
| ៤៤ | Through metatarso-phalangeal joint | ៥ |
| ៤៥ | Part, with some loss of bone | ២ |
| ***ម្រាមបីនៃប្រអប់ជើងមួយ មិនគិតមេជើង*** | | |
| ៤៦ | Through metatarso-phalangeal joint | ៦ |
| ៤៧ | Part, with some loss of bone | ៣ |
| ***ម្រាមបួននៃប្រអប់ជើងមួយ មិនគិតមេជើង*** | | |
| ៤៨ | Through metatarso-phalangeal joint | ៩ |
| ៤៩ | Part, with some loss of bone | ៣ |

(សំគាល់: ការបាត់បង់ទាំងស្រុង និងអចិន្ត្រៃយ៍នៃការប្រើប្រាស់អវៈយវៈណាមួយដែលយោងតាមតារាងនេះ ត្រូវ ចាត់ទុកថាមាន តំលៃស្មើគ្នា "សមមូល"នៃការបាត់បង់អវៈយវៈនោះ) ។

ឧបសម្ព័ន្ធ ៣នៃប្រកាសលេខ ១០៩ បក/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ

## តារាងមេគុណតម្លៃបច្ចុប្បន្ន

| អាយុ | មេគុណ |
|---:|---:|
| 0 | 12,222 |
| 1 | 12,305 |
| 2 | 12,364 |
| 3 | 12,398 |
| 4 | 12,408 |
| 5 | 12,398 |
| 6 | 12,369 |
| 7 | 12,324 |
| 8 | 12,263 |
| 9 | 12,189 |
| 10 | 12,104 |
| 11 | 12,010 |
| 12 | 11,910 |
| 13 | 11,806 |
| 14 | 11,700 |
| 15 | 11,593 |
| 16 | 11,485 |
| 17 | 11,376 |
| 18 | 11,266 |
| 19 | 11,156 |
| 20 | 11,045 |
| 21 | 10,932 |
| 22 | 10,818 |
| 23 | 10,704 |
| 24 | 10,587 |
| 25 | 10,470 |
| 26 | 10,351 |
| 27 | 10,230 |
| 28 | 10,108 |
| 29 | 9,983 |
| 30 | 9,857 |
| 31 | 9,728 |
| 32 | 9,596 |
| 33 | 9,462 |
| 34 | 9,326 |
| 35 | 9,188 |
| 36 | 9,048 |
| 37 | 8,906 |
| 38 | 8,762 |
| 39 | 8,616 |
| 40 | 8,468 |
| 41 | 8,317 |
| 42 | 8,164 |
| 43 | 8,009 |
| 44 | 7,852 |

| | |
|---|---|
| 45 | 7,692 |
| 46 | 7,530 |
| 47 | 7,366 |
| 48 | 7,200 |
| 49 | 7,032 |
| 50 | 6,862 |
| 51 | 6,690 |
| 52 | 6,516 |
| 53 | 6,341 |
| 54 | 6,164 |
| 55 | 5,986 |
| 56 | 5,807 |
| 57 | 5,627 |
| 58 | 5,447 |
| 59 | 5,265 |
| 60 | 5,083 |
| 61 | 4,900 |
| 62 | 4,717 |
| 63 | 4,534 |
| 64 | 4,350 |
| 65 | 4,169 |
| 66 | 3,990 |
| 67 | 3,817 |
| 68 | 3,648 |
| 69 | 3,481 |
| 70 | 3,316 |
| 71 | 3,153 |
| 72 | 2,996 |
| 73 | 2,842 |
| 74 | 2,693 |
| 75 | 2,547 |
| 76 | 2,406 |
| 77 | 2,270 |
| 78 | 2,138 |
| 79 | 2,011 |
| 80 | 1,888 |
| 81 | 1,771 |
| 82 | 1,658 |
| 83 | 1,550 |
| 84 | 1,447 |
| 85 | 1,348 |
| 86 | 1,255 |
| 87 | 1,166 |
| 88 | 1,081 |
| 89 | 1,001 |
| 90 | 926 |
| 91 | 854 |
| 92 | 787 |
| 93 | 723 |
| 94 | 664 |
| 95 | 608 |
| 96 | 555 |

| | |
|---|---|
| 97 | 505 |
| 98 | 459 |
| 99 | 415 |
| 100 | 374 |
| 101 | 333 |
| 102 | 293 |
| 103 | 246 |
| 104 | 174 |
| 105 | 0 |

## ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗនៅក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៩៧ ដល់២០១៧ (គិតជាដុល្លារអាមេរិក)

| ឆ្នាំ | ប្រាក់ឈ្នួលអប្បបរមា | | | អត្ថប្រយោជន៍ដទៃ | | | | | ប្រាក់រង្វាន់អតីតភាព (ដុល្លារ/ខែ) | | | | | | | | | | | ថ្ងៃចាប់អនុវត្ត | ប្រកាស/សេចក្តីជូនដំណឹង | ប្រាក់ឈ្នួល អប្បបរមា និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | កិច្ចសន្យាហ្វឹកហ្វឺនកូនជាង | រយៈពេលសាកល្បង | កិច្ចសន្យាធម្មតា | ប្រាក់សោហ៊ុយធ្វើដំណើរ & ថ្លៃស្នាក់នៅ | ប្រាក់ឧបត្ថម្ភថែទាំសុខភាព | ប្រាក់រង្វាន់ធ្វើការទៀងទាត់ | ប្រាក់ឧបត្ថម្ភថ្លៃអាហារចំពោះអ្នកធ្វើការថែម ម៉ោង * | ប្រាក់ឧបត្ថម្ភជីវភាព | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | | | |
| 1997 | 30 | 40 | 40 | | | | | | | | | | | | | | | | | | ស.ជ.ណ លេខ 06/97 | 40 |
| 1998 | 30 | 40 | 40 | | | | | | | | | | | | | | | | | | \| | 40 |
| 1999 | 30 | 40 | 40 | | | | | | | | | | | | | | | | | | \| | 40 |
| 2000 | 30 | 40 | 45 | | | 5 | 0.25 | | 0 | 2 | 3 | 4 | 5 | 5 | 5 | 5 | 5 | 5 | 5 | 01.08.2000 | ស.ជ.ណ លេខ 017/00 | 50 |
| 2001 | 30 | 40 | 45 | | | 5 | 0.25 | | 0 | 2 | 3 | 4 | 5 | 5 | 5 | 5 | 5 | 5 | 5 | \| | \| | 50 |
| 2002 | 30 | 40 | 45 | | | 5 | 0.25 | | 0 | 2 | 3 | 4 | 5 | 5 | 5 | 5 | 5 | 5 | 5 | \| | \| | 50 |
| 2003 | 30 | 40 | 45 | | | 5 | 0.25 | | 0 | 2 | 3 | 4 | 5 | 5 | 5 | 5 | 5 | 5 | 5 | \| | \| | 50 |
| 2004 | 30 | 40 | 45 | | | 5 | 0.25 | | 0 | 2 | 3 | 4 | 5 | 5 | 5 | 5 | 5 | 5 | 5 | \| | \| | 50 |
| 2005 | 30 | 40 | 45 | | | 5 | 0.25 | | 0 | 2 | 3 | 4 | 5 | 5 | 5 | 5 | 5 | 5 | 5 | \| | \| | 50 |
| 2006 | 30 | 40 | 45 | | | 5 | 0.25 | | 0 | 2 | 3 | 4 | 5 | 5 | 5 | 5 | 5 | 5 | 5 | \| | \| | 50 |
| 2007 | 30 | 45 | 50 | | | 5 | 0.25 | | 0 | 2 | 3 | 4 | 5 | 5 | 5 | 5 | 5 | 5 | 5 | 01.01.2007 | ស.ជ.ណ លេខ 745/06 | 55 |
| 2008 | 30 | 45 | 50 | | | 5 | 0.25 | 6 | 0 | 2 | 3 | 4 | 5 | 5 | 5 | 5 | 5 | 5 | 5 | 01.04.2008 | ស.ជ.ណ លេខ 32/08 | 61 |
| 2009 | 30 | 45 | 50 | | | 5 | 0.25 | 6 | 0 | 2 | 3 | 4 | 5 | 5 | 5 | 5 | 5 | 5 | 5 | \| | \| | 61 |
| 2010 | 30 | 56 | 61 | | | 5 | 0.25 | | 0 | 2 | 3 | 4 | 5 | 5 | 5 | 5 | 5 | 5 | 5 | 01.10.2010 | ស.ជ.ណ លេខ 049/10 | 66 |
| 2011 | 30 | 56 | 61 | | | 5 | 0.25 | | 0 | 2 | 3 | 4 | 5 | 5 | 5 | 5 | 5 | 5 | 5 | \| | \| | 66 |
| | 30 | 56 | 61 | | | 7 | 0.5 | | 0 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 01.03.2011 | ស.ជ.ណ លេខ 041/11 | 68 |
| 2012 | 30 | 56 | 61 | | 5 | 7 | 0.5 | | 0 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 01.01.2012 | ស.ជ.ណ លេខ 206/11 | 73 |
| | 30 | 56 | 61 | 7 | 5 | 10 | 0.5 | | 0 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 01.09.2012 | ស.ជ.ណ លេខ 230/12 | 83 |
| 2013 | 30 | 75 | 80 | 7 | | 10 | 0.5 | | 0 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 01.05.2013 | ស.ជ.ណ លេខ 103/13 | 97 |
| 2014 | 30 | 95 | 100 | 7 | | 10 | 0.5 | | 0 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 01.02.2014 | ប្រកាសលេខ 317/13 & ស.ណ.ន លេខ 001/14 | 117 |
| 2015 | 30 | 123 | 128 | 7 | | 10 | 0.5 | | 0 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 01.01.2015 | ប្រកាសលេខ 283/14 | 145 |
| 2016 | 30 | 135 | 140 | 7 | | 10 | 0.5 | | 0 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 01.01.2016 | ប្រកាសលេខ 409/15 | 157 |
| 2017 | 30 | 148 | 153 | 7 | | 10 | 0.5 | | 0 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 01.01.2017 | ប្រកាសលេខ 414/16 | 170 |

*អត្រាប្តូរប្រាក់: ១$=៤០០០៛

ប្រភព៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៧

# ការកំណត់
# ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា



២០១៦

សហការរៀបចំដោយ៖

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

អង្គការអន្តរជាតិខាងការងារ

លេខាធិការដ្ឋានគណៈកម្មការប្រឹក្សាការងារ

# តើនរណា ជាអ្នកកំណត់ប្រាក់ឈ្នួលអប្បបរមានៅប្រទេសកម្ពុជា?

យោងតាមមាត្រា ៣៥៧ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ គណៈកម្មការប្រឹក្សាការងារ គឺជាអ្នកដឹកនាំពិភាក្សា និងស្នើនូវអត្រាប្រាក់ឈ្នួលអប្បបរមា។ គណៈកម្មការប្រឹក្សាការងារ មានសមាសភាពមកពី ៣ភាគី៖

**ប្រាក់ឈ្នួលអប្បបរមា**

ភាគីតំណាងនិយោជក
ចំនួន ៧រូប
(សមាគមនិយោជក)

ភាគីតំណាងកម្មករនិយោជិត
ចំនួន ៧រូប
(សហជីព)

ភាគីរាជរដ្ឋាភិបាលចំនួន ១៤រូប

# តើនរណា ជាអ្នកកំណត់ប្រាក់ឈ្នួល អប្បបរមានៅប្រទេសកម្ពុជា?



គណៈកម្មការប្រឹក្សាការងារ អាចបង្កើតក្រុមការងារបច្ចេកទេស ត្រីភាគី ស្របតាមភាពចាំបាច់។ ក្រុមការងារបច្ចេកទេសត្រីភាគី ដែលមានសមាជិកស្មើៗគ្នាមកពីភាគីទាំងបី ត្រូវបានបង្កើតឡើងដើម្បីពិភាក្សាលម្អិតអំពីទិន្នន័យ លក្ខណវិនិច្ឆ័យ និងអត្រាកំណើនប្រាក់ឈ្នួលអប្បបរមា និងលើកយោបល់ជូនគណៈកម្មការប្រឹក្សាការងារដើម្បីប្រជុំពិភាក្សាបន្ត។

## ប្រាក់ឈ្នួលអប្បបរមា



ក្រុមការងារបច្ចេកទេស
តំណាងភាគីនិយោជក
ចំនួន ១៦រូប



ក្រុមការងារបច្ចេកទេស
តំណាងភាគីកម្មករនិយោជិត
ចំនួន ១៦រូប



ក្រុមការងារបច្ចេកទេស
តំណាងភាគីរាជរដ្ឋាភិបាលចំនួន ១៦រូប

# តើអ្វីខ្លះជាលក្ខណៈវិនិច្ឆ័យក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមានៅប្រទេសកម្ពុជា?



កថាខណ្ឌទី**៣** នៃមាត្រា **១០៧** នៃច្បាប់ស្តីពីការងារ ដែលស្របតាមមាត្រា **៣** នៃអនុសញ្ញាលេខ **១៣១** ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមារបស់អង្គការអន្តរជាតិខាងការងារ (ILO) ឆ្នាំ ១៩៧០ កំណត់ថា ធាតុផ្សំដែលត្រូវយកមកគណនាប្រាក់ឈ្នួលអប្បបរមា ត្រូវមានយ៉ាងហោចណាស់កត្តាធំពីរគឺ **កត្តាសង្គម** និង**កត្តាសេដ្ឋកិច្ច**។ ក្រោយសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិស្តីពីការពង្រឹងដំណើរការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា ដែលប្រព្រឹត្តិទៅក្រោមជំនួយបច្ចេកទេសរបស់អង្គការ ILO កាលពីថ្ងៃទី ២៤-២៥ ខែមេសា ឆ្នាំ ២០១៤ **ភាគីទាំងបី** បានសម្រេចយកលក្ខណវិនិច្ឆ័យចំនួន **៧** ដែលស្របតាមអនុសញ្ញាខាងលើសម្រាប់ការកំណត់ប្រាក់ឈ្នួលអប្បបរមា ដែលរួមមាន៖

លក្ខណវិនិច្ឆ័យបែបសង្គម
- ១ ស្ថានភាពគ្រួសារ
- ២ អត្រាអតិផរណា
- ៣ ការចំណាយក្នុងការរស់នៅ

លក្ខណវិនិច្ឆ័យបែបសេដ្ឋកិច្ច
- ៤ ផលិតភាព
- ៥ ភាពប្រកួតប្រជែងរបស់ប្រទេស
- ៦ ស្ថានភាពទីផ្សារការងារ
- ៧ កម្រិតចំណេញរបស់វិស័យ

# តើអ្វីខ្លះជាគោលការណ៍គ្រឹះក្នុងការចរចាប្រាក់ឈ្នួលអប្បបរមា?



ក្រោយសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិស្តីពីការពង្រឹងដំណើរការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា ដែលប្រព្រឹត្តិទៅក្រោមជំនួយបច្ចេកទេសរបស់អង្គការ ILO កាលពីថ្ងៃទី ២៤-២៥ ខែមេសា ឆ្នាំ២០១៤ **ភាគីទាំងបី** បានព្រមព្រៀងជាឯកច្ឆន្ទនូវគោលការណ៍ចំនួនប្រាំ៖

**ប្រាក់ឈ្នួលអប្បបរមា**

១ ការពិភាក្សាប្រាក់ឈ្នួលអប្បបរមាត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ

២ ប្រាក់ឈ្នួលអប្បបរមាត្រូវតែជាតួលេខឬអត្រាកំណើនដែលអាចព្យាករណ៍បានពោលគឺត្រូវកើនតាមលំដាប់បន្តបន្ទាប់

៣ ប្រកាន់យកគោលការណ៍ឈ្នះ-ឈ្នះក្នុងការចរចា

៤ ត្រូវយកគោលការណ៍ឯកភាពជាឯកច្ឆន្ទ (កុងសង់ស៊ីស) នៃសមាជិកដែលមានវត្តមានក្នុងកិច្ចប្រជុំក្នុងការសម្រេចចិត្ត។ ក្នុងករណីមិនមានការឯកភាពជាឯកច្ឆន្ទលើចំណុចណាមួយ ចំនួន២ (ពីរ)ដង ក្នុងកិច្ចប្រជុំ ចំនួន២ (ពីរ) ផ្សេងគ្នា ត្រូវសម្រេចដោយសម្លេងភាគច្រើនតាមរយៈការបោះឆ្នោតជាសម្ងាត់ក្នុងកិច្ចប្រជុំលើកទី២(ពីរ)

៥ ត្រូវប្រើប្រាស់ទិន្នន័យផ្លូវការ របស់ស្ថាប័នឬអង្គភាពជាតិដែលទទួលបន្ទុកផលិតស្ថិតិ និងយកលក្ខណវិនិច្ឆ័យបែបសង្គម និងសេដ្ឋកិច្ចមកធ្វើជាមូលដ្ឋានក្នុងការពិភាក្សា

# តើគណៈកម្មការប្រឹក្សាការងារ ចាប់ផ្តើមប្រជុំកំណត់ប្រាក់ឈ្នួលអប្បបរមានៅពេលណា?

នៅខែ**កក្កដា** រៀងរាល់ឆ្នាំ
ភាគីនីមួយៗ ចាប់ផ្តើម
**ប្រជុំពិភាក្សាផ្ទៃក្នុង**
**របស់ខ្លួន**





# តើគណៈកម្មការប្រឹក្សាការងារ ចាប់ផ្តើមប្រជុំកំណត់ប្រាក់ឈ្នួលអប្បបរមានៅពេលណា?

នៅខែ**សីហា** រៀងរាល់ឆ្នាំ
ភាគីនីមួយៗ ចាប់ផ្តើម
**ប្រជុំទ្វេភាគី**





# តើគណៈកម្មការប្រឹក្សាការងារ ចាប់ផ្តើមប្រជុំកំណត់ប្រាក់ឈ្នួលអប្បបរមានៅពេលណា?

នៅខែ**កញ្ញា** រៀងរាល់ឆ្នាំ
ភាគីទាំងបី ចាប់ផ្តើម
**ប្រជុំពិភាក្សាជាត្រីភាគី**



ការប្រជុំសម្រេច
តួលេខឬអត្រាកំណើនប្រាក់
ឈ្នួលអប្បបរមានឹងប្រព្រឹត្តិទៅ
នៅ ខែតុលា នៃឆ្នាំនីមួយៗ។
ចំណែកប្រាក់ឈ្នួលអប្បបរមា
ថ្មី នឹងចាប់ផ្តើមអនុវត្តចាប់ពី
**ថ្ងៃទី១ ខែមករា នៃឆ្នាំបន្ទាប់**



# ការវិភាគសង្ខេបសម្រាប់ការចរចាកំណត់ប្រាក់ឈ្នួលអប្បបរមា




យោងតាមសេចក្តីថ្លែងការរបស់គណៈកម្មការប្រឹក្សាការងារ ឆ្នាំ២០១៤

# តើប្រាក់អត្ថប្រយោជន៍ផ្សេងៗមានអ្វីខ្លះ?

គិតត្រឹមឆ្នាំ២០១៦ ប្រាក់អត្ថ-
ប្រយោជន៍ផ្សេងៗ រួមមាន៖
ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន
១០ដុល្លារអាមេរិកក្នុងមួយខែ
និងប្រាក់សោហ៊ុយធ្វើដំណើរ និង
ស្នាក់នៅចំនួន ៧ដុល្លារអាមេរិក
ក្នុងមួយខែ។



លើសពីនេះទៅទៀត កម្មករនិយោជិតក៏ទទួល
បាននូវ ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដោយ
ស្ម័គ្រចិត្តចំនួន ២ ០០០ រៀលក្នុងមួយថ្ងៃ ឬ
ទទួលបាន បាយមួយពេលដោយឥតគិតថ្លៃ
និងប្រាក់រង្វាន់អតីតភាពការងារចំនួន
ពី ២ដុល្លារអាមេរិក ដល់ ១១ដុល្លារអាមេរិក
ក្នុងមួយខែសម្រាប់ កម្មករនិយោជិតដែលបាន
ធ្វើការចាប់ពីឆ្នាំទី២ ដល់ឆ្នាំទី១១។

# បេឡាជាតិរបបសន្តិសុខសង្គម

(ប.ស.ស)

**ខិត្តបណ្ណ សម្រាប់កម្មករនិយោជិត**

**ផ្នែកហានិភ័យការងារ (គ្រោះថ្នាក់ការងារ)**

ទំនាក់ទំនងមកប.ស.ស៖

- ទូរស័ព្ទមកលេខ ១២៨៦ ( Call ចូលគ្រប់ប្រព័ន្ធដោយមិនកាត់លុយ) ករណីសង្គ្រោះបន្ទាន់ គ្រោះថ្នាក់ចរាចរណ៍ ដួលសន្លប់...

-Facebook ប.ស.ស៖ បេឡាជាតិរបបសន្តិសុខសង្គម

## ដើម្បីជួយសម្រួលការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ

បេឡាជាតិរបបសន្តិសុខសង្គម ក៏មានគណៈកម្មការ និងក្រុមការងារជំនាញមួយចំនួនដើម្បីជួយកម្មករនិយោជិត រួមមាន៖

- គណៈកម្មការដោះស្រាយវិវាទ ឬបណ្ដឹងនៃ ប.ស.ស ជួយផ្សះផ្សាវិវាទដែលទាក់ទងនឹងការអនុវត្តរបស់ប.ស.ស។

- ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ជួយទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ដែលអាចកើតមានក្នុងពេលកម្មករនិយោជិតធ្វើដំណើរ។

- ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត ជួយកែលំអលក្ខខណ្ឌអនាម័យ និងសុវត្ថិភាពការងារ និងលក្ខខណ្ឌការងារ ឲ្យកាន់តែល្អនៅកន្លែងការងារ។

**បញ្ជាក់៖ សូមទំនាក់ទំនង ប.ស.ស ករណីមានវិវាទ ឬបណ្ដឹងលើបញ្ហារបស់ ប.ស.ស ករណីមានគ្រោះថ្នាក់ចរាចរណ៍ របស់កម្មករនិយោជិត និងកម្មករសន្លប់ តាមរយៈលេខទូរស័ព្ទបន្ទាន់ ១២៨៦។**

## និយមន័យ៖ ផ្នែកហានិភ័យការងារ (គ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ)

### កន្លែងការងារ

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិត ដោយធ្វើការ ឬក្នុងពេលធ្វើការទោះដោយហេតុយ៉ាង ណាក៏ដោយ ហើយទោះមាន កំហុស ពីកម្មករ និយោជិត ឬ គ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើ រូបកាយកម្មករនិយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬនាយក សហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈ មានឈ្នួលក្ដី ឥតឈ្នួលក្ដីកាន់មុខងារអ្វីនៅទីកន្លែង ណាក៏ដោយ ។

### ពេលធ្វើដំណើរ

ត្រូវចាត់ទុជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើរូប កាយ ក ម្មក រនិយោជិត ក្នុងពេលដែលសាមី ខ្លួនធ្វើដំណើរ ពីលំនៅស្ថាន ខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការឬវិល មកវិញ ដោយ គ្មាន វាង ទៅកន្លែងផ្សេង ជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការ ងារ ដែល គេត ម្រូវ ឱ្យទៅ ។







**គ្រោះថ្នាក់ការងារ**



### ជំងឺវិជ្ជាជីវៈ

ជំងឺដែលបណ្ដាលមកវិជ្ជាជីវៈ រួមមានមុខរបរប្រើកំលាំងកាយ មុខរបរដែលប៉ះពាល់ដោយជាតិពុល និងមុខរបរដែលត្រូវអនុវត្តនៅក្នុងលក្ខខណ្ឌ ឬតំបន់មានលក្ខណៈមិនប្រក្រតី ដែលនាំឱ្យអ្នកធ្វើការ កើតជំងឺផ្សេងៗ។



## និយមន័យតាវកាលិក

តាវកាលិក គឺជាប្រាក់ វត្ថុ ឬសេវាដែលត្រូវផ្ដល់ឱ្យដល់សមាជិក ប.ស.ស នៅពេលចាស់ជរា ទុព្វលភាព និងនៅពេលទទួលរងហានិភ័យការងារទៅតាមកាលកំណត់មួយ។

## ការជូនដំណឹងហានិភ័យការងារ

**+ កម្មករនិយោជិត៖**

-ត្រូវជូនដំណឹងទៅរដ្ឋបាលរោងចក្រ

-ឬជូនដំណឹងមក ប.ស.ស តាមលេខទូរស័ព្ទបន្ទាន់ ១២៨៦ (មិនគិតថ្លៃសេវាគ្រប់ប្រព័ន្ធ) ។

**+ និយោជក ឬអ្នកតំណាងបន្ទាប់ពីទទួលបានព័ត៌មានករណីកម្មករនិយោជិត៖**

-ជូនដំណឹងបន្ទាន់មក ប.ស.ស តាមរយៈលេខ១២៨៦ ដើម្បីជួយសម្របសម្រួលជនរងគ្រោះទៅមន្ទីរពេទ្យ

-ផ្ញើរបាយការណ៍ជាបឋមមក ប.ស.ស តាមរយៈ

Email address:**benefit@nssf.gov.kh**

-ត្រូវបញ្ជូនរបាយការណ៍ហានិភ័យការងារ និង ឯកសារពាក់ព័ន្ធមក ប.ស.ស ក្នុងរយៈពេលយ៉ាងយូរ ៤៨ម៉ោង នៃថ្ងៃធ្វើការ ។

## សិទ្ធិទទួលបានតាវកាលិក

កម្មករនិយោជិតទាំងអស់នៃសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាក្នុង ប.ស.ស មានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ នៅពេលដែលសាមីជន ទទួលរងហានិភ័យការងារ ។

# តាវកាលិក (អត្ថប្រយោជន៍) ហានិភ័យការងារដែលកម្មករនិយោជិតទទួលបាន៖

## ១. ការផ្តល់សេវាសង្គ្រោះបន្ទាន់

ត្រូវបានផ្តល់ការសង្គ្រោះបន្ទាន់ ដែលនៅកន្លែងដែលជិតបំផុត និងបន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយ ប.ស.ស ។ ការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនខាងលើត្រូវស្ថិតនៅក្នុងបន្ទុករបស់ ប.ស.ស ។



## ២-ការផ្តល់សេវាថែទាំ និងការព្យាបាល

- ត្រូវតែប្រព្រឹត្តទៅនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយ ប.ស.ស
- ក្នុងករណីដែលគ្រូពេទ្យព្យាបាលតម្រូវឱ្យទិញឱសថ ឬសំភារៈឧបករណ៍ ដែលចាំបាច់សម្រាប់ការថែទាំ និងព្យាបាល ជនរងគ្រោះ ឬអ្នកតំណាង អាចទាមទារមក ប.ស.ស ដើម្បីធ្វើការទូទាត់សងវិញបាន លុះត្រាណាតែមានវេជ្ជបញ្ជា និងវិក្ក័យបត្រត្រឹមត្រូវ។



## ៣-បាត់បង់សមត្ថភាពការងារបណ្តោះអាសន្នទទួលបាន៖

- ប្រាក់បំណាច់ប្រចាំថ្ងៃ៧០% នៃប្រាក់ឈ្នួលមធ្យម ប្រចាំថ្ងៃគិតចាប់ពីថ្ងៃទី២ទៅរហូតដល់ជាសះស្បើយ។
- ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំនៅមន្ទីរពេទ្យ ស្មើនឹង ៥០% នៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ។



## ៤- បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ទទួលបាន

- ប្រាក់វិភាជន៍ (ប្រាក់ឧបត្ថម្ភ)

ចំពោះការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង២០% ប.ស.ស ផ្តល់ជូនជនរងគ្រោះតែម្តងគត់។

- ប្រាក់ធនលាភ

ចំពោះការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ចាប់ពី ២០%ឡើង ប.ស.ស ផ្តល់ជូនជនរងគ្រោះរៀងរាល់៣ខែម្តង បើកឱ្យជនរងគ្រោះអស់មួយជីវិត ករណីតម្រូវមានអ្នកចាំថែរក្សា មានសិទ្ធិទទួលបាន៥០% នៃប្រាក់ធនលាភរបស់ជនរងគ្រោះ។



## ៥-សេវាបុននីតិសម្បទា

ផ្តល់ឧបករណ៍ ឬអវៈយវៈសិប្បនិម្មិតស្របតាមការកំណត់របស់គ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យទទួលស្គាល់ដោយ ប.ស.ស នឹងទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាល

## ៦-អ្នកទទួលរងហានិភ័យការងាររហូតដល់ស្លាប់

+ សោហ៊ុយដឹកសពដល់ផ្ទះជនរងគ្រោះ



+ អ្នកទទួលរាប់រងក្នុងការចាត់ចែងបូជាសព ត្រូវបានផ្តល់ប្រាក់វិភាជន៍សោហ៊ុយបូជាសពដែលមានចំនួន ៤.០០០.០០០ (បួនលាន)រៀល។ ប្រាក់វិភាជន៍នេះ ត្រូវផ្តល់ជូនទៅជនដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ។



+ សម្រាប់អ្នកនៅក្នុងបន្ទុកនៃជនរងគ្រោះរហូតដល់ស្លាប់៖

- ករណីនៅលីវ ផ្តល់ប្រាក់ឧបត្ថម្ភជូនឪពុកម្តាយ ឬចាស់ជរានៅក្នុងបន្ទុករបស់ជនរងគ្រោះ ត្រូវមានសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ (មានអាយុចាប់ពី ៥៥ឆ្នាំឡើងទៅ)
- ករណីមិនមានសំបុត្រអាពាហ៍ពិពាហ៍ មិនផ្តល់ប្រាក់ឧបត្ថម្ភជូនប្តី ឬប្រពន្ធ និងកូនឡើយ (ប៉ុន្តែផ្តល់ជូនដូចករណីនៅលីវ) ។
- ករណីមានសំបុត្រអាពិហ៍ពិពាហ៍ផ្តល់ប្រាក់ឧបត្ថម្ភជូន ប្តី ឬប្រពន្ធមួយជីវិតប្រសិនជាមិនមានចំណងអាពាហ៍ពិពាហ៍ជាថ្មីនិងកូនឧបត្ថម្ភដល់អាយុ១៨ឆ្នាំ បើនៅរៀនឧបត្ថម្ភដល់អាយុ២១ឆ្នាំ និងផ្តល់ជូនឪពុកម្តាយ ឬចាស់ជរា(អាយុចាប់ពី៥៥ឆ្នាំឡើងទៅនៅក្នុងបន្ទុករបស់ជនរងគ្រោះត្រូវមានសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ ។

